## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការលើកកម្ពស់ប្រាក់រៀល

ចុះកម្មសិក្សាពីថ្ងៃទី ០៣ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន ៖ **ធនាគារជាតិ នៃ កម្ពុជា**


គាត់តែងឡើងដោយ

និស្សិតឈ្មោះ ៖ **តេង សុធារិទ្ធ**
**ភាំង សៀកវ័ង**

សាស្ត្រាចារ្យណែនាំ
**លោកស្រី ឡុង ម៉ាមីឌី**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេររបាយការណ៍ ២០១៧

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតឈ្មោះ តេង សុធារិទ្ធ និង កាំង សៀកជ័ង ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងធុរៈកិច្ច ជំនាន់ទី ១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណចំពោះអ្នកដែលពាក់ព័ន្ធមានដូចតទៅៈ

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សាយ៉ាងយកចិត្តទុកដាក់ ផ្តល់ការរៀនសូត្រ ការទូន្មានប្រៀនប្រដៅ ព្រមទាំងបានផ្តល់កម្លាំងចិត្ត និងថវិការគ្រប់កាលៈទេសៈ ដើម្បីឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹងតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់បរិញ្ញាបត្រ ប្រកបដោយ ភាពរលូន។

លោកព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្រៀន ណែនាំយ៉ាងយកចិត្តទុកដាក់ និងផ្តល់នូវគំនិតល្អៗសម្រាប់ការងារនេះ។

សាស្ត្រាចារ្យ **ឡុង ម៉ាមីឌី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងចែករំលែកបទពិសោធន៍ដើម្បីយកមកបង្ហាត់បង្រៀន ថែមទាំងផ្តល់យោបល់មកយើងខ្ញុំតាំងពីដើមរហូតដល់ចប់។

លោកទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ដែលបានអនុញ្ញាតឲ្យក្រុមយើងខ្ញុំបានធ្វើការចុះកម្មសិក្សានៅ ធនាគារជាតិនៃកម្ពុជា ជាពិសេស នាយកដ្ឋានបុគ្គលិក នាយកដ្ឋានស្ថិតិ និង នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្រៀន ព្រមទាំងបានផ្តល់នូវគំនិតនិងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទរបស់យើងខ្ញុំ ។

ជាចុងក្រោយ យើងខ្ញុំសូមអរគុណដល់អ្នកអានទាំងអស់ដែលបានចំណាយពេលអាននូវការចងក្រងឯកសារស្រាវជ្រាវមួយនេះ។

# អារម្ភកថា

ប្រទេសកម្ពុជាបច្ចុប្បន្ន កំពុងមានការរីកចម្រើនទៅលើគ្រប់វិស័យ ដូចជាវិស័យហិរញ្ញវត្ថុ ធនាគារ និងការវិនិយោគ មានភាពរីកលូតលាស់គួរឲ្យកត់សម្គាល់។ ក្នុងនោះដែរ វិស័យធនាគារ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យកាន់តែរីកចម្រើនថែមទៀតផង ទាំងនេះក៏ ដោយសារ ប្រព័ន្ធធនាគារបានជួយសម្រួលដល់អ្នកវិនិយោគគិនក្នុងនិងក្រៅប្រទេស ក្នុងការបង្វិល សាច់ប្រាក់ ក៏ដូចជាការផ្ដល់កម្ចីឲ្យកាន់តែឆាប់រហ័ស និងមានសុវត្ថិភាព។ កន្លងមក យើងឃើញថា មានអ្នកវិនិយោគជាច្រើន បានមកវិនិយោគនៅកម្ពុជាដោយនាំមកនូវដុល្លារូបនីយកម្ម ហើយក៏បាន បញ្ជាក់ឲ្យឃើញអំពីលំហូរនៃសាច់ប្រាក់ដុល្លាក្នុងទីផ្សារ ដែលធ្វើឲ្យប្រាក់ដុល្លាត្រូវបានចាយយ៉ាង ទូលំទូលាយនៅក្នុងប្រទេសកម្ពុជា ។ ម៉្យាងទៀត វត្តមានរបស់រូបិយប័ណ្ណបរទេសគឺ បានធ្វើឲ្យប្រជា ជនកម្ពុជាមានទំនោរប្រើប្រាស់នូវរូបិយប័ណ្ណដុល្លា ជាងប្រាក់រៀលខ្មែរក្នុងការទូទាត់ទំនិញ។ ជា ឧទាហរណ៍៖ នៅក្នុងប្រទេសកម្ពុជាក៏មានការចាយវាយនូវប្រាក់ដុល្លាតាមកន្លែងមួយចំនួន ដូចជា នៅតាមហាងទំនើប ហាងកាហ្វេ និងតាមផ្សារមួយចំនួនតូច។ ដូចនេះ ដោយមើលឃើញថា បញ្ហា ដុល្លារូបនីយកម្មនៅកម្ពុជាបង្កជាភាពលំបាក ទើបក្រុមយើងខ្ញុំបានជ្រើសរើសយកនូវប្រធានមួយស្ដី ពី "ការលើកកម្ពស់ប្រាក់រៀល" ចង់ដឹងថាតើធនាគារជាតិនៃកម្ពុជានិងអ្នកពាក់ព័ន្ធនានាមានវិធី សាស្ត្រអ្វីខ្លះក្នុងលើកកម្ពស់រូបិយវត្ថុជាតិ។

ចំពោះកំណើននៃតម្រូវការប្រាក់រៀល ក៏បានផ្ដល់សុទិដ្ឋិនិយមលើការលើកកម្ពស់ការប្រើ ប្រាស់ប្រាក់រៀល ឲ្យកាន់តែទូលំទូលាយបន្ថែមទៀតនាពេលអនាគត។ តាមរយៈការលើកកម្ពស់ ប្រាក់រៀលនេះ អាចធ្វើបានដោយសារធនាគារជាតិនៃកម្ពុជា បានសម្រេចក្នុងការដាក់ឲ្យអនុវត្តន៍ គោលនយោបាយ និងវិធានការនានាដូចជា ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងជំនឿ ទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល និងជាពិសេសការគាំទ្រប្រាក់រៀលរបស់សាធារណ ជន ស្របពេលដែលរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវវិធានការជម្រុញ ការប្រើប្រាស់ប្រាក់រៀលជាបន្តបន្ទាប់។ តាមរយៈរបាយការណ៍ស្រាវជ្រាវនេះផងដែ បានរួមបញ្ចូល នូវមូលហេតុនៃដុល្លារូបនីយកម្ម វិធានការពង្រឹងប្រាក់រៀល ប្រវត្តិរូបិយវត្ថុ និងការស្រាវជ្រាវ ធនាគារជាតិនៃកម្ពុជា ដូចជាJICA ធនាគារជាតិជាដើម ដែលបានលើកយកបញ្ហានៃការប្រើប្រាស់ ប្រាក់ដុល្លា មកធៀបជាមួយនឹងប្រាក់រៀលខ្មែរ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថា សៀវភៅមួយក្បាលនេះអាចជាប្រយោជន៍ដល់អ្នកអាន ដើម្បីយល់ដឹងកាន់តែច្បាស់នូវគុណសម្បត្តិ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលចំពោះ សេដ្ឋកិច្ចប្រទេសជាតិទាំងមូល។

# មាតិកា


បញ្ជីអក្សរកាត់ .......... iv
បញ្ជីរូបភាព .......... v
បញ្ជីក្រាហ្វិក .......... vi


## សេចក្តីផ្តើម


១.លំនាបញ្ហានៃការស្រាវជ្រាវ .......... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ .......... ២
៣. គោលបំណងនៃការស្រាវជ្រាវ .......... ២
៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ .......... ៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ .......... ៣
៦. វិធីសាស្រ្តនៃការស្រាវជ្រាវ .......... ៣
៧. រចនាសម្ព័ន្ធនៃនៃការស្រាវជ្រាវ .......... ៤


## ជំពូកទី១

## រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ


១.១. អំពីប្រាក់រៀល .......... ៦
១.២. និយមន័យរូបិយវត្ថុ .......... ៦
១.៣. ការបង្កើតប្រាក់រៀល .......... ៧
១.៤. ការជ្រាបចូលរូបិយប័ណ្ណនៅកម្ពុជា .......... ៨
១.៥. ប្រភេទនៃរូបិយវត្ថុ .......... ១០
១.៦. និយមន័យនិងប្រភេទនៃដុល្លារូបិយនីយកម្ម .......... ១១
១.៧. សារតា និងមូលហេតុនៃដុល្លារូបនីយកម្ម .......... ១៣
១.៨. ស្ថានភាពអត្រាប្តូរប្រាក់ .......... ១៥
១.៨.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀននឹងដុល្លារ .......... ១៥
១.៨.២. អត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណនៃប្រទេសនាំចូលចម្បងរបស់កម្ពុជា .......... ១៥
១.៩. ស្ថានភាពរូបិយវត្ថុ .......... ១៦
១.៩.១ រូបិយវត្ថុទូទៅ .......... ១៦
១.១០. គុណសម្បត្តិនិងគុណវិបត្តិនៃការប្រើប្រាក់ដុល្លារូបនីយកម្មនៅកម្ពុជា .......... ១៩
១.១០.១ គុណសម្បត្តិ .......... ១៩

១.១០.២ គុណវិបត្តិ .......... ២០

## ជំពូកទី២

## ស្ថានភាពទូទៅនៃធនាគារជាតិ នៃ កម្ពុជា

២.១. ប្រវត្តិសង្ខេបរបស់ធនាគារជាតិនៃកម្ពុជា .......... ២២
២.២. អាគាររបស់ធនាគារជាតិនៃកម្ពុជា .......... ២៤
២.៣. ទីតាំងនិងភូមិសាស្ត្ររបស់ធនាគារជាតិនៃកម្ពុជា .......... ២៥
២.៤. រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា .......... ២៦
២.៤.១. រចនាសម្ព័ន្ធនិងមុខងារភារៈកិច្ចរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ .......... ២៨
២.៤.២. រចនាសម្ព័ន្ធនិងមុខងារភារៈកិច្ចរបស់នាយកដ្ឋានសិត្ថិ .......... ២៩
២.៥. មុខងារនិងភារៈកិច្ចរបស់ធនាគារជាតិនៃកម្ពុជា .......... ៣១
២.៦. ប្រព័ន្ធធនាគារ .......... ៣២
២.៦.១. ធនាគារជាតិនៃកម្ពុជា .......... ៣២
២.៦.២. ធនាគារឯកជន .......... ៣៣
២.៧. ស្លាកសញ្ញារបស់ធនាគារជាតិនៃកម្ពុជា .......... ៣៤

## ជំពូកទី៣

## ការលើកកម្ពស់ប្រាក់រៀល

៣.១. សារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀល .......... ៣៦
៣.២. ចក្ខុវិស័យនិងក្របខណ្ឌនយោបាយ .......... ៣៧
៣.៣. ការពិភាក្សាលើគោលនយោបាយជាតិនិងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល .......... ៣៩
៣.៣.១. គោលនយោបាយរូបិយវត្ថុនិងអត្រាការប្រាក់ .......... ៤០
៣.៣.២. គោលនយោបាយសារពើពន្ធ .......... ៤០
៣.៣.៣.គោលនយោបាយពាណិជ្ជកម្ម .......... ៤១
៣.៣.៤. គោលនយោបាយហិរញ្ញវត្ថុនិងក្របខណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន .......... ៤៤
៣.៣.៥. គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ .......... ៤៥
៣.៣.៦. ការអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ .......... ៤៦
៣.៣.៧. ការលើកកម្ពស់ការយល់ដឹង និងការចូលរួម .......... ៤៨
៣.៣.៨. កិច្ចសហប្រតិបត្តិការដើម្បីអនុវត្តវិធានការប្រកបដោយប្រសិទ្ធិភាព .......... ៤៨

៣.៣.៩. គោលនយោបាយគាំទ្រនានា ....................................................................................................៤៩
៣.៤. វិធានការលើកកម្ពស់ប្រាក់រៀល ....................................................................................................៥០
៣.៤.១. វិធានការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ...........................................................................៥០
៣.៤.២. វិធានការរបស់ក្រសួងពាណិជ្ជកម្ម.........................................................................................៥១
៣.៤.៣. វិធានការរបស់ធនាគារជាតិនៃកម្ពុជា .....................................................................................៥១

## ជំពូកទី៤

## ការពិភាក្សា

៤.១. លទ្ធផលនៃវិធានការនៃការពង្រឹងការប្រើប្រាស់ប្រាក់រៀល..........................................................៥៤
៤.២. វិធានការចម្បងនៃការធ្វើបដិដុល្លារូបនីយកម្ម ...........................................................................៥៩
៤.៣. លទ្ធផលអង្កេតស្តីពីការប្រើប្រាស់ប្រាក់រៀលនិងប្រាក់ដុល្លារ ...........................................................៦១
៤.៣.១. ចំពោះអង្គភាពគ្រួសារ...................................................................................................៦១
៤.៣.២. ចំពោះក្រុមហ៊ុន-សហគ្រាស ........................................................................................... ៦២
៤.៣.៣. ចំពោះគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ........................................................................៦៣
៤.៣.៤. ចំពោះអាជីវកម្មប្តូរប្រាក់...............................................................................................៦៤
៤.៤. ការវិភាគ SWOT ....................................................................................................................៦៥
៤.៤.១. ចំណុចខ្លាំង ..................................................................................................................៦៥
៤.៤.២ ចំណុចខ្សោយ................................................................................................................៦៥

## សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..........................................................................................................................៦៦
២. ការផ្តល់អនុសាន៍..........................................................................................................................៦៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

UNTAC: The United National Transitional Authority in Cambodia
ATM: Asset and Investment Manager
AMRO: ASEEAN+3 Macroeconomic Research Office
JICA: Japanese International Cooperation Agency
SWOT: Strengths, Weaknesses, Opportunities, Threats)
AEC: ASEAN Economics Community
GDP: Gross Domestic Product
NEER: Nominal Effective Exchange Rate
REER: Real Effective Exchange Rate

# បញ្ជីរូបភាព

រូបភាពទី១: អាគាររបស់ធនាគាជាតិនៃកម្ពុជា........................................................................... ២៥
រូបភាពទី២: ទីតាំងភូមិសាស្រ្ត និងផែនទីរបស់ធនាគារជាតិនៃកម្ពុជា ........................................ ២៦
រូបភាពទី៣: រចនាសម្ព័ន្ធនៃក្រុមប្រឹក្សាភិបាល ........................................................................... ២៨
រូបភាពទី៤: ស្លាកសញ្ញារបស់ធនាគារជាតិ..................................................................................៣៥

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១: Dollarization in Cambodian ..... ១៤
ក្រាហ្វិកទី២: អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារ ..... ១៥
ក្រាហ្វិកទី៣: អត្រាប្តូរប្រាក់កម្ពុជា ..... ១៦
ក្រាហ្វិកទី៤: កំណើនរូបិយវត្ថុទូទៅ ឥណទាន ប្រាក់បញ្ញើជារូបិយប័ណ្ណ និងកម្ចីពីបរទេស ..... ១៧
ក្រាហ្វិកទី៥: កំណើន និងសមាសធាតុរូបិយទូទៅ ..... ១៧
ក្រាហ្វិកទី៦: ផ.ស.ស រូបិយវត្ថុសរុប និងឥណទាន ..... ១៨
ក្រាហ្វិកទី៧: ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុនិងកម្រិតដុល្លារូបនីយកម្ម ..... ១៨
ក្រាហ្វិកទី៨: ចំនួនមន្ត្រី-បុគ្គលិក និងកំរិតសមត្ថភាព (ខែមិថុនា ឆ្នាំ២០១៥) ..... ៣៥
ក្រាហ្វិកទី៩: Cambodian’s Real GDP Growth Rate ..... ៥៤
ក្រាហ្វិកទី១០: Cambodian YOY Inflation Rate (%) ..... ៥៥
ក្រាហ្វិកទី១១: Cambodian Riel/US Dollar ..... ៥៦
ក្រាហ្វិកទី១២: Ratio off Foreign Currency ..... ៥៧
ក្រាហ្វិកទី១៣: កម្រិតដុល្លារូបនីយកម្ម និងសមាសភាគនៃរូបិយប័ណ្ណ ..... ៦២
ក្រាហ្វិកទី១៤: កម្រិតដុល្លារូបនីយកម្មធៀបនឹងទ្រព្យសកម្មនិងអកម្មសរុប ..... ៦៣

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

រូបិយវត្ថុសំដៅលើក្រដាសប្រាក់ ឬកាសដែលបានបោះពុម្ពផ្សាយ និងដាក់ឲ្យដំណើរការដោយធនាគារកណ្តាលនៃប្រទេសមួយ ។ ប្រទេសកម្ពុជាក៏មានរូបិយវត្ថុរបស់ខ្លួនផងដែរ ដោយយោងតាមគេហទំព័ររបស់ធនាគាជាតិនៃកម្ពុជា ធនាគាជាតិនៃកម្ពុជាដែលជាអាជ្ញាធររូបិយវត្ថុជាតិត្រូវបានបង្កើតឡើងជាលើកដំបូង នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៥៤ ហើយរូបិយវត្ថុជាតិ " ប្រាក់រៀល " ក៏ត្រូវបានបង្កើតឡើងផងដែរ ។ ប្រជាជនកម្ពុជាបានទទួលស្គាល់យ៉ាងទូលំទូលាយលើប្រាក់រៀល ក្រោយពីការដាក់ឲ្យចរាចរ ក៏ប៉ុន្តែទំនុកចិត្តលើប្រាក់រៀល ត្រូវបានបំផ្លាញទាំងស្រុង នៅអំឡុងពេលសង្គ្រាមស៊ីវិល ដែលអូសបន្លាយអស់ជិត ៣០ ឆ្នាំ ។

បន្ទាប់ពីមានរដ្ឋប្រហារ លន់ ណុល នៅឆ្នាំ ១៩៧០ កម្ពុជាបានធ្លាក់ក្នុងអស្ថេរភាពនយោបាយ និងសេដ្ឋកិច្ច ដែលធ្វើឲ្យសាធារណជនបាត់បង់ជំនឿទុកចិត្តលើរដ្ឋាភិបាល សេដ្ឋកិច្ច និងរូបិយវត្ថុជាតិ។ សង្គ្រាមបានកើតឡើងនៅគ្រប់ទីកន្លែង ប្រទេសត្រូវបានកាត់ផ្តាច់ជាកង់ៗ ហើយផលិតកម្មបានថយចុះជាលំដាប់ ។ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះដុនដាបជាខ្លាំង ប្រទេសទាំងមូលត្រូវពឹងផ្អែកលើជំនួយបរទេស។ អតិផរណាបានកើនឡើងកាន់តែខ្លាំងឡើងៗ ដោយសារកង្វះខាតការផ្គត់ផ្គង់ក្នុងស្រុក។ ធនាគាជាតិនៃកម្ពុជានាពេលនោះបានបោះពុម្ពប្រាក់ជាច្រើនបន្ថែមទៀតដើម្បីបំពេញឱនភាពថវិការដ្ឋ ពិសេសសម្រាប់បើកប្រាក់ខែឲ្យមន្ត្រីរាជការ ។ ដោយយោងតាមការសិក្សាលើអតិផរណាសម័យនោះបានបង្ហាញថា ថ្លៃទំនិញនានាបានឡើងថ្លៃ ជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស ឧទាហរណ៍ដូចជា ថ្លៃគុយទាវមួយចាន ដែលមាន តម្លៃ ៥០ រៀលឡើងថ្លៃដល់ទៅ៥០០ រៀលរួចឡើងដល់ ១០០០រៀល ហើយថ្លៃមេជ្រូកមួយ បានកើនថ្លៃដល់ មួយលានរៀល គឺស្មើនឹងប្រាក់បៀវត្សរ៍មន្ត្រីថ្នាក់មធ្យមម្នាក់ក្នុងពេលពីរឆ្នាំ ។ ភាពមិនច្បាស់លាស់ នៃស្ថានភាពនយោបាយ និង អស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទាំងក្នុងនិងក្រៅប្រទេស បានធ្វើអោយប្រជាជនបាត់បង់ជំនឿទុកចិត្តលើរូបិយវត្ថុជាតិ ។ ហើយប្រាក់ដុល្លារបានហូរចូលកាន់តែច្រើនតាមរយៈជំនួយអាមេរិច ។ លើសពីនេះទៅទៀតរូបិយវត្ថុជាតិត្រូវបានបាត់បង់ទាំងស្រុងក្នុងសម័យ ប៉ុល ពត (១៩៧៥-១៩៧៩) ។ គ្មានទីផ្សារ គ្មានការជួញដូរ គ្មានរូបិយវត្ថុ នេះជាបទពិសោធន៍យ៉ាងខ្លាចផ្សារនិងជាឬសគល់នៃការបាត់បង់ជំនឿចិត្តលើរូបិយវត្ថុជាតិ ។

ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ ប្រទេសកម្ពុជា ក៏ចាប់ផ្តើមមានសកម្មភាពសេដ្ឋកិច្ចឡើងវិញ ។ ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញ នៅថ្ងៃទី ២០ ខែ តុលា ១៩៧៩ ។ នៅ

ថ្ងៃទី២០ មីនា ឆ្នាំ ១៩៨០ ប្រាក់រៀលត្រូវបានដាក់អោយចរាចរឡើងវិញ ។ ក្នុងបរិយាកាសដែលសេដ្ឋ-កិច្ចនៅមានភាពទន់ខ្សោយការពង្រឹងជំនឿចិត្តលើរូបិយប័ណ្ណវត្ថុជាតិជារឿងដ៏លំបាក់មួយ ។

នៅពាក់កណ្តាលសវត្សរ៍ ១៩៨០ រដ្ឋបានចាប់ផ្តើមធ្វើកំណែទម្រង់ពីសេដ្ឋកិច្ចទៅជាសេដ្ឋ-កិច្ចទីផ្សារសេរី ហើយអនុញ្ញាតអោយមានជំនួយបែបមនុស្សធម៌ ពីអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងជំនួយហិរញ្ញវត្ថុពីគ្រួសារខ្មែរនៅបរទេស នេះជាមូលហេតុដែលមានការហូរចូលយ៉ាងសន្ធឹមៗនៃដុល្លាអាមេរិច ។ ចាប់តាំងពីប្រទេសកម្ពុជាទទួលបានសន្តិភាព ១០០%នៅឆ្នាំ១៩៩៨ មក ការប្រើប្រាស់រូបិយវត្ថុជាតិនៅតែមានកម្រិតទាបនៅឡើយ យើងឃើញថាដោយយោងទៅតាមគេហទំព័ររបស់ធនាគាជាតិនៃ កម្ពុជាបានលើកឡើងថា ការហូរចូលរូបិយប័ណ្ណ (ប្រាក់ដុល្លារ) ជាបន្តបន្ទាប់មកក្នុងសេដ្ឋកិច្ចកម្ពុជាបានធ្វើឲ្យកម្រិត ដុល្លាររូបនីយកម្មមានការកើនឡើងជាលំដាប់គឺ ប្រមាណ ៦០% នៅក្នុងទសវត្សឆ្នាំ ១៩៩០ មក ៨០%ក្នុង ទសវត្សរ៍ឆ្នាំ ២០០០ ហើយបានរក្សាក្នុងកំរិតនេះរហូតមកដល់បច្ចុបន្ន ។ ហើយបើដុល្លារូបនីយកម្មនៅតែបន្តការកើនឡើងដូច្នេះថ្ងៃណាមួយប្រទេសកម្ពុជា និងក្លាយជាប្រទេសដុល្លារូបនីយកម្មទាំងស្រុង ។ ដោយមើលឃើញនៅចំណុចនៃការបាត់បង់ទំនុកចិត្តលើរូបិយវត្ថុជាតិ និងការហូរចូលនៃរូបិយប័-ណ្ណបរទេសមកលើប្រទេសកម្ពុជា ទាំងនេះហើយជាមូលហេតុដែលធ្វើអោយប្រធានបទប្រធានបទ **ការលើកម្ពស់ប្រាក់រៀល** ត្រូវបានលើកយកមកសិក្សាស្រាវជ្រាវ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយយល់ឃើញថា ទីផ្សារបច្ចុប្បន្នមានការប្រើប្រាស់ប្រាក់រូបិយប័ណ្ណ ជាពិសេសប្រាក់ដុល្លារច្រើនជាងគេ ព្រមទាំងមានកត្តាផ្សេងៗដែលជះឥទ្ធិពលដល់តម្លៃប្រាក់រៀល ដែលជាបញ្ហាមួយសម្រាប់ធនាគារជាតិនៃកម្ពុជា និងអ្នកដែលពាក់ព័ន្ធត្រូវដោះស្រាយ ។ យើងខ្ញុំជ្រើសរើសប្រធានបទនេះគឺដើម្បីស្វែងយល់បន្ថែមអំពីស្ថានភាពទូទៅនៃះ

- តើដុល្លារូបនីយកម្មនៅកម្ពុជាមានគុណសម្បត្តិនិងគុណវិបត្តិអ្វីខ្លះ?
- តើធនាគារជាតិនៃកម្ពុជាមាបទប្បញ្ញត្តិ និងវិធានការអ្វីខ្លះក្នុងការលើកកម្ពស់ប្រាក់រៀល ?
- តើធនាគារជាតិនៃកម្ពុជាទទួលបានលទ្ធផលយ៉ាងដូចម្តេចក្រោយពីអនុវត្តវិធានការនេះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់ៗនៃការស្រាវជ្រាវទៅលើប្រធានបទ "ការលើកកម្ពស់ប្រាក់រៀល" មានដូចជាៈ

- ជាទុនមួយដ៏សំខាន់សម្រាប់បង្កើនសមត្ថភាពយល់ដឹងទៅលើការលើកកម្ពស់ប្រាក់រៀលជាតិ ។
- ស្វែងយល់ពីមូលហេតុនៃការហូរចូលនៃរូបិយប័ណ្ណបរទេសមកក្នុងប្រទេសកម្ពុជា ។
- ស្វែងយល់ពីប្រវត្តិរូបិយវត្ថុជាតិ ។
- ដើម្បីជាឯកសារ និងអនុសាសន៍ក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺបានសំខាន់ទៅលើដំណើរវិវត្តន៍របស់ប្រាក់រៀល នៅក្នុងសេដ្ឋ-កិច្ចកម្ពុជា និងវិធានការរបស់ធនាគាជាតិនៃកម្ពុជាព្រមទាំងអ្នកពាក់ព័ន្ធនានា ក្នុងការលើកកម្ពស់ប្រាក់រៀលដែលវិធានការនេះសិក្សាចន្លោះពីឆ្នាំ (២០១២-២០១៦) ដែលចេញ ដោយធនាគារជាតិនៃកម្ពុជាស្ថិតក្នុងផ្នែកស្រាវជ្រាវសេដ្ឋកិច្ច ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

- ផ្តល់ចំណេះដឹងដល់អ្នកអាន ឲ្យយល់កាន់តែយល់ច្បាស់ពីការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុរបស់ធនាគាជាតិនៃកម្ពុជា ។
- ជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ ឬបុគ្គលដែលមានបំណងចង់សិក្សាពីវិធានការនៃការលើកម្ពស់ប្រាក់រៀល ។
- រួមចំណែកជួយជំរុញវិធានការដែលបានដាក់ចេញអោយខិតទៅរកភាពជោគជ័យ ។
- យល់ដឹងពីចំណុចខ្វះខាតរបស់ធនាគាជាតិនៃកម្ពុជាទៅលើការដាក់ចេញ នូវវិធានការលើកកម្ពស់ប្រាក់រៀលនេះ ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះ បានជ្រើសរើសយកវិធីសាស្ត្រនៃការស្រាវជ្រាវគឺបែប Quality (គុណវិស័យ) ដោយផ្តោតសំខាន់លើទិន្នន័យបន្ទាប់បន្សំឬ ( Secondary Data ) ។ ទិន្ន័យបន្ទាប់បន្សំគឺជាទិន្នន័យដែលមានឯកសារច្បាស់លាស់ ដូចជារបាយការណ៍ និងការសិក្សាស្រាវជ្រាវផ្សេងៗដែលបោះពុម្ពឯកសារដោយធនាគារជាតិនៃកម្ពុជា សៀវភៅសេដ្ឋកិច្ចផ្សេងៗដែលបោះពុម្ពជាអន្តរជាតិជាភាសាអង់គ្លេសដោយសាស្ត្រាចារ្យល្បីល្បាញ ឯកសារពី Internet សៀវភៅសារណា និងរបាយ-ការណ៍បញ្ចប់កម្មសិក្សារបស់និស្សិតជំនាន់មុនៗ និងឯកសារពាក់ព័ន្ធមួយចំនួនជច្រើនទៀតនៅតាមបណ្ណាល័យនានា ។

ប្រភពទិន្នន័យ៖

- សៀវភៅរបាយការណ៍របស់ធនាគារជាតិ អត្ថបទពិភាក្សារបស់ធនាគារជាតិ។
- អត្ថបទស្រាវជ្រាវដែលមានពីមុន។
- ឯកសារបានពី Website របស់ធនាគាជាតិ និងអត្ថបទពីប្រព័ន្ធអ៊ីនធឺណែត។

យើងបានប្រមូលយកទិន្នន័យ និងឯកសារមួយចំនួនដែលពាក់ព័ន្ធយកមកចងក្រងជាសៀវភៅ ហើយរាល់ចំនុចខ្វះខាតយើងបានពិភាក្សាជាមួយនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចរបស់ធនាគារជាតិនៃកម្ពុជាដើម្បីផ្តល់ពត៌មានបន្ថែម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ ត្រូវបានបែងចែកជាបួន ជំពូកធំៗ គឺ

- សេចក្តីផ្តើម ៖ ក្នុងផ្នែកនេះបង្ហាញពី លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ទំហំនិងដែនកំណត់ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។
- ជំពូកទី ១ ៖ ការវិលឹកទ្រឹស្តី: នៅក្នុងផ្នែកនេះបានបង្ហាញអំពីរូបិយវត្ថុនានាដែលរៀបរាប់ចាប់ពីការកកើតនៃរូបិយវត្ថុយុគដំបូងរហូតមកដល់បច្ចុប្បន្ន មុខងារនិងតួនាទីរបស់រូបិយ-វត្ថុ ការជ្រាបចូលរូបិយវត្ថុ ការប្រែប្រួលនៃអត្រាប្តូរប្រាក់ ការហូរចូលនៃដុល្លាររូបនីយកម្ម ព្រម ទាំងមានគុណសម្បត្តិ និងគុណវិបត្តិមួយចំនួននៃការប្រើប្រាស់ប្រាក់ដុល្លារ។
- ជំពូកទី ២ ៖ ស្ថានភាពទូទៅនៃធនាគាជាតិនៃកម្ពុជា: សិក្សាទៅលើបរិយាកាសទូទៅនៅក្នុងធនាគារជាតិនៃកម្ពុជា មានដូចជា ប្រវត្តិសាស្ត្រ ទីតាំងភូមិសាស្ត្រ រចនាសម្ព័ន្ធគ្រប់គ្រង និងមុខងាររបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងមានសាខាគ្រប់បណ្តាខេត្តនានា និងក្រុងផងដែរ។
- ជំពូកទី ៣ ៖ ការលើកម្ពស់ប្រាក់រៀល: ក្នុងផ្នែកនេះបានបង្ហាញពី សារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀល ចក្ខុវិស័យនិងក្របខណ្ឌគោលនយោបាយ ការពិភាក្សាលើគោលនយោបាយជាតិ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល បូករួមទាំងវិធានការនានារបស់ធនាគារជាតិនៃកម្ពុជា និងអ្នកដែលពាក់ព័ន្ធក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។
- ជំពូកទី ៤ ៖ ក្នុងជំពូកនេះបង្ហាញ អោយឃើញពី លទ្ធផលនៃការពង្រឹងការប្រើប្រាស់រូបិយ-វត្ថុជាតិចេញដោយធនាគារជាតិនៃកម្ពុជា វិធានការចម្បងៗនៃការធ្វើបដិដុល្លាររូបនី

យកម្ម និងការសហការណ៍របស់ JICA ជាមួយធនាគារជាតិនៃជាតិកម្ពុជា ស្តីពីលទ្ធផលអង្កេតស្តីពីការប្រើប្រាស់ប្រាក់រៀលនិងប្រាក់ដុល្លារ។

- សេចក្តីសន្និដ្ឋាននិងអនុសាសន៍: ក្នុងផ្នែកនេះបង្ហាញពីការសរុបសេចក្តីលើរបាយការណ៍កម្មសិក្សា និងផ្តល់ជាគំនិតយោបល់ ។
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី១
# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ

## ១.១. អំពីប្រាក់រៀល

[1]ត្រីរៀល គឺជាត្រីតូចមួយនៅក្នុងទន្លេមេគង្គនិងទន្លេសាប ដែលគេយកមកធ្វើប្រហុក មាំទឹកត្រី ត្រីឆ្អើរដែលប្រជានេសាទនៅតាមស្ទឹងនិងស្រែចម្ការ ក៏ដូចជាអ្នកទីក្រុងតែងតែយកមកប្រើប្រាស់នៅក្នុងការហូបចុករបស់គេដែលមានតែបាយនិងបន្លែប៉ុណ្ណោះ ហើយក្លិនឆ្ងុលរបស់វាបានអណ្តែតនៅតាមដងស្ទឹងនិងទីផ្សារនានា។ គេនេសាទត្រីរៀល ដោយប្រើប្រាស់ឧបករណ៍គ្រប់ប្រភេទតាំងពីរសំណាញ់រហូតដល់អួនដែលមានរាងដូចជាឆត្រយោងធំមួយ ដែលមានចងសំណរនៅចុងសងខាង ហើយដែលមានទូកទាញចាប់ពីពាក់កណ្តាលទន្លេមករកច្រាំងដោយប្រើខ្សែពួរប្រវែងជិត១០០ម៉ែត្រ។ ត្រីដែលនៅក្នុងអួនរត់ចូលទៅក្នុងថ្នក់ខាងក្រោម។ ត្រីរៀល ច្រើនលោតចេញផុតពីទឹកទាំងហ្វូងៗ ហើយទស្សនីយភាពនេះល្អមើលខ្លាំងណាស់ពេលលោតចេញផុតពីទឹកមកត្រូវថ្ងៃត្រីដែលមានរាងទ្រវែង និងមានស្រកាចាំងផ្លេកមើលទៅឃើញដូចជាកាំជ្រួច។ គេមើលទៅឃើញដូចជាក្បាលម៉ាស៊ីនដែលបាញ់ចេញពីទឹកប្រាក់អញ្ចឹង។ ដោយមានការចាប់អារម្មណ៍ខ្លាំងជាមួយហេតុការណ៍នេះ អភិបាលបារាំងម្នាក់ដែលធ្វើដំណើរក្នុងទន្លេសាបបានស្នើសុំឲ្យគេយកឈ្មោះត្រីរៀលនេះមកហៅថា ប្រាក់រៀលឬរូបិយវត្ថុជាតិ។ ត្រីរៀល គឺជាសន្យាដល់ការការហូបចុកគ្រប់គ្រាន់និងល្អថែមទៀតផង។ គេយកវាធ្វើជារបស់សម្រាប់ហូបចុកផ្សេងៗតាំងពីសម័យអាចារ្យធម៌ខ្មែរមករហូតមកដល់សព្វនេះ ហើយបានផ្តល់រសជាតិទៅដល់គ្រប់អ្វីៗដែលគេហូប។ ត្រីរៀល អាចជារូបតំណាងខាងសិល្បៈខាងម្ហូបអាហាររបស់កម្ពុជា ហើយក៏អាចជាតំណាងរូបភាពនៃការរស់នៅតាមស្រុកស្រែចម្ការដ៏សាមញ្ញ តែសម្បូរសប្បាយ និងមានសុភមង្គល ។

## ១.២. និយមន័យរូបិយវត្ថុ[2]

រូបិយវត្ថុ (National Current) សំដៅលើក្រដាសប្រាក់ឬកាស ដែលបានបោះផ្សាយនិងដាក់ឲ្យដំណើរការដោយធនាគារកណ្តាលជាតិនៃប្រទេសមួយ។ នៅកម្ពុជារូបិយវត្ថុគឺប្រាក់រៀល ដែលបានបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលតែមួយគត់របស់ជាតិ។

[1] ហ្សង់ដានីញ៉ែលហ្គារខែរ *រូបិយវត្ថុនិងអធិបតេយ្យភាព ដំណើរវែងឆ្ងាយនៃធនាគារជាតិនៃកម្ពុជា"* (ភាគ១) , ធនាគារជាតិនៃកម្ពុជា, ឆ្នាំ២០០៩

[2] ធនាគារជាតិនៃកម្ពុជា *យុទ្ធសាស្ត្រនៃការលើកកម្ពស់ប្រាក់រៀល* , (បោះពុម្ពលើកទី២,២០១៥) ទំព័រ២

រូបិយប័ណ្ណ (Foreign Currency) សំដៅលើក្រដាសប្រាក់ឬកាក់ ដែលបោះផ្សាយដោយធនាគារកណ្តាលបរទេស។ ឧទាហរណ៍ ប្រាក់ដុល្លាអាមេរិកគឺជារូបិយប័ណ្ណនៅកម្ពុជា។ ប្រាក់ដុល្លារអាមេរិកត្រូវបានបោះផ្សាយ ដោយធនាគារកណ្តាលសហរដ្ឋអាមេរិក។

## ១.៣.ការបង្កើតប្រាក់រៀល[3]

➢ ប្រាក់រៀលដំបូងឆ្នាំ១៩៥៣-១៩៧៥

នៅឆ្នាំ ១៩៥៣ សាខាស្ថាប័នបេសកម្មប្រចាំកម្ពុជា ឡាវ វៀតណាម បានចេញផ្សាយនូវក្រដាសប្រាក់ព្យាស្ត និងក្រដាសប្រាក់រៀល។ ស្របពេលជាមួយគ្នាដែរ សាខារបស់ស្ថាប័ននេះនៅវៀតណាមខាងត្បូង និងឡាវក៏បានធ្វើដូចគ្នាដែរដោយបានចេញផ្សាយរៀងគ្នានូវប្រាក់ដុងនិងប្រាក់គីប។ ប្រាក់កាក់រួមមាន១០ ២០ និង ៥០ សេន នៅឆ្នាំ១៩៥៣ ផលិតឡើងពីអាលុយមីញ៉ូម។ រីឯក្រដាសប្រាក់ដំបូងរួមមានក្រដាសប្រាក់ព្យាស្រ្ត និងក្រដាស ប្រាក់រៀលត្រូវបានប្រើព្រមគ្នា។ តែដល់ឆ្នាំ១៩៥៥ ធនាគារជាតិនៃកម្ពុជាបានប្រកាសឲ្យប្រើប្រាស់តែក្រដាសប្រាក់រៀល។ នៅពេលនោះមានក្រដាសប្រាក់ប្រភេទ ១ ៥ ១០ ២០ ៥០ ១០០ និង៥០០រៀល។ ក្រដាសប្រាក់ប្រភេទ១០០០ និង៥០០០រៀលត្រូវបានបោះពុម្ពតែមិនត្រូវបានដាក់ឲ្យប្រើប្រាស់ទេ។ ការរចនានៅលើក្រដាសប្រាក់គឺនិយាយអំពីជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ប្រវត្តិសាស្ត្រ និងរឿងទេវកថា។

➢ សម័យខ្មែរក្រហមឆ្នាំ១៩៧៥-១៩៨០

ទោះបីជាខ្មែរក្រហមបានបោះពុម្ពក្រដាសប្រាក់ (០,១ ០,៥ ១ ៥ ១០ ៥០ និង១០០រៀលដែលចុះកាលបរិច្ឆេទឆ្នាំ១៩៧៥) ក៏ដោយក៏ក្រដាសប្រាក់នេះមិនត្រូវបានដាក់ឲ្យប្រើប្រាស់ទេដោយសារគោលការណ៍បំបាត់ប្រាក់កាលនៅសម័យខ្មែរក្រហម។

➢ ប្រាក់រៀលក្រោយឆ្នាំ១៩៨០

ប្រាក់រៀលត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៨០។ នៅពេលនោះ៤៛ ស្មើនឹង១$។ ១៛ ស្មើ ១០កាក់ និងស្មើនឹង ១០០សេន។ ដោយគ្មានក្រដាសប្រាក់ដែលត្រូវជំនួសរដ្ឋាភិ-បាលបានចែកប្រាក់រៀលទាំងនោះដល់ប្រជាពលរដ្ឋ។ នៅតំបន់ជនបទ ប្រាក់រៀលត្រូវបានប្រើដើម្បីទិញនូវទំនិញគ្រប់សព្វ ហើយបើនៅទីក្រុង និងតំបន់ទេសចរណ៍គេនិយមចាយប្រាក់ដុល្លារ រីឯនៅតំបន់ក្បែរព្រំដែនថៃដូចជា ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងក្រុងប៉ៃលិន គេក៏ឃើញមានការចាយនូវប្រាក់បាតថៃផងដែរ។ ចំណែកឯប្រាក់កាក់ ដំបូងជាកាក់៥សេន ដែលត្រូវបាន

[3] ដកស្រង់ចេញពី https://www.nbc.org.kh (ចូលថ្ងៃទី ១២ មិថុនា)

ផលិតពីអាលុយមីញ៉ូមនៅឆ្នាំ១៩៧៩។ កាក់នេះមិនត្រូវបានគេបោះពុម្ពទៀតទេ រហូតដល់ឆ្នាំ ១៩៩៤ ទើបគេឃើញមានការបោះពុម្ពកាក់ឡើងវិញដែលមានប្រភេទ ៥០ ១០០ ២០០និង៥០០ រៀល ក៏ប៉ុន្តែដោយកាក់មិនមានការពេញនិយមក្នុងការចាយវាយ ហើយវាក៏បានបាត់ស្រមោលបន្តិចម្តងៗពីលើទីផ្សារ។

ក្រដាសប្រាក់ត្រូវបានផលិតនៅឆ្នាំ១៩៨០ ដែលមានប្រភេទ ១ ២ និង៥កាក់ ១ ៥ ១០ ២០ និង៥០ រៀល។ ដោយសារមានវិបត្តិសេដ្ឋកិច្ចអាស៊ីនៅឆ្នាំ១៩៩០ គេក៏បានបោះពុម្ពក្រដាសប្រាក់ប្រភេទថ្លៃជាង មានដូចជាប្រភេទ ៥០ ១០០ ២០០ ៥០០ ១០០០ និង២០០០រៀល។ ក្រោយមកនៅឆ្នាំ១៩៩៥ ក្រដាសប្រាក់ប្រភេទពី១០០ ទៅ១០០០០០ត្រូវបានចេញផ្សាយ។ ក្រដាសប្រាក់ប្រភេទលើ១០០០០រៀលមិនសូវឃើញមានគេចាយទេ។ ក្រដាសប្រាក់ប្រភេទថ្មីនេះត្រូវបានគេដាក់ឲ្យប្រើប្រាស់ជាបន្តបន្ទាប់តាំងពីឆ្នាំ២០០១ ដល់២០០៧។ ក្រដាសប្រាក់ស្ថិតនៅក្នុងចរាចរមាន៖[4]

- មួយរយរៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ ២០០១)
- ពីររយរៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ និង២០០៣)
- ប្រាំរយរៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ និង២០០៣)
- មួយពាន់រៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ ឆ្នាំ១៩៩៩)
- ពីរពាន់រៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ និង២០០៨)
- ប្រាំពាន់រៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ និង២០០១)
- មួយម៉ឺនរៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ និង២០០១)
- ពីរម៉ឺនរៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ និង២០០៨)
- ប្រាំម៉ឺនរៀល (បោះផ្សាយក្នុងឆ្នាំ១៩៩៥ និង២០០១ )
- មួយសែនរៀល (បោះផ្សាយក្នុងឆ្នាំ ១៩៩៥)

## ១.៤ ការជ្រាបចូលរូបិយប័ណ្ណនានានៅក្នុងសេដ្ឋកិច្ចកម្ពុជា

ក្នុងរយៈពេល១៧ ឆ្នាំនៃរបបសង្គមរាស្ត្រនិយម រូបិយវត្ថុរៀលបានបំពេញមុខងារបានយ៉ាងល្អទាំងខាងប្រតិបត្តិការហិរញ្ញវត្ថុ និងមុខងាររក្សាតម្លៃ ។ ក្រោយមកក្រោមរដ្ឋប្រហាររបស់សេនាបតី លន់ នុល ដែលមានការគាំទ្ររបស់កងទ័ពសហរដ្ឋអាមេរិច ប្រទេសកម្ពុជាបានបែរ

[4] សូមមើលឧបសម្ព័ន្ធទី១

ក្លាយជាសារធារណៈរដ្ឋកម្ពុជា ហើយពេលនោះគេឃើញមានចរាចរក្រដាសប្រាក់ដុល្លារ ជាលើកដំបូងក្នុងបរិមាណតិចតួច ។

កងទ័ពរណសិរ្សសង្គ្រោះជាតិនៃកម្ពុជាបានរំដោះប្រជាជន ប្រទេសជាតិ និងអ្វីទាំងអស់ឲ្យរួចផុតពីរបបប្រល័យ ពូជសាសន៍ខ្មែរក្រហម ។ ក្រោមការជួយជ្រោមជ្រែង និងការគ្រប់គ្រងនយោបាយ សង្គម និងសេដ្ឋកិច្ចពីសំណាក់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជាបានធ្វើអោយប្រទេសមានស្ថេរភាពឡើងវិញបានបន្តិច ។ ពេលនោះគេឃើញមានអង្គការមនុស្សធម៌ ជំនួយជាបន្ទាន់ នូវអង្គរ និងអន្តរជាតិមួយចំនួនបានត្រូវអនុញ្ញាតអោយចូលប្រទេសកម្ពុជា ហើយបាននាំចូលប្រាក់ដុល្លារមួយចំនួនតូចជាមួយផងជាលើកទីពីរ ។ ពេលនោះអ្នកដែលមានកាន់ទ្រព្យសម្បត្តិបានខិតខំស្វះស្វែងយកទ្រព្យទាំងនោះទៅដោះដូរយកប្រាក់ដុល្លារ ដើម្បីធ្វើដំណើរទៅរស់នៅបរទេសដែលធ្វើអោយប្រាក់ដុល្លារ មានតំរូវការកើនឡើង ។ ស្របជាមួយនោះ មានអភិជនមួយចំនួនក៏បានចូលស្រុកដើម្បីស្វែងរកបងប្អូនដែលបានបែកបាក់គ្នានៅជំនាន់ពលពត ហើយក៏បាននាំមកជាមួយនៅប្រាក់ដុល្លាមកជាមួយផងដែរ។ ក្រោយមកនៅឆ្នាំ ១៩៨៨ កងទ័ពវៀតណាមត្រូវបានដកចេញ ពេលនោះកម្ពុជាដែលមានសេដ្ឋកិច្ច ទន់ខ្សោយ ផុយស្រួយ និងស្ថានភាពនយោបាយមិនទាន់បានដោះស្រាយរួចរាល់នោះក៏ត្រូវដំណើរការដោយខ្លួនឯង ។ ពេលនោះប្រទេសកម្ពុជាជួបនូវឱនភាពថវិការយ៉ាងខ្លាំង ដែលបង្ខំអោយធនាគារកណ្តាលធ្វើហិរញ្ញប្បទានដោយបោះពុម្ពក្រដាសប្រាក់បន្ថែម ។ ជាលទ្ធផលប្រទេសកម្ពុជាជួបនូវអត្រាអតិផរណាយ៉ាងខ្ពស់ពី ៩០%នៅឆ្នាំ ១៩៨៨ ទៅកាន់១៧៧% នៅឆ្នាំ ១៩៩១ ដែលធ្វើអោយអំនាចទិញរបស់ប្រាក់រៀល និងទំនុកលើប្រាក់រៀលពីមហាជនធ្លាក់ចុះយ៉ាងខ្លាំង ។ ជាមួយ និងបរិមាណប្រាក់ដុល្លាបានធ្វើចរាចរយ៉ាងច្រើន និងបន្តហូរចូលក្នុងប្រទេស ធ្វើអោយប្រជាជនមានទំនោរទន់ទៅប្រើប្រាស់ និងកាន់រូបិយប័ណ្ណដុល្លារជំនួសវិញដើម្បីការពារអំនាចទិញរបស់អំនាចទិញរបស់ពួកគេ ។

រហូតដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩៣ កិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងបទឈប់បាញ់នៅក្នុងប្រទេសកម្ពុជាបានធ្វើអោយប្រទេសមានស្ថេរភាព និងសុវត្ថិភាពកាន់តែខ្ពស់ឡើងៗនៅក្នុងប្រទេនិងលើឆាកអន្តរជាតិ។ ភ្លាមៗនោះ អនិកជនខ្មែរ ប្រជាជនបានភៀសខ្លួន អ្នកវិនិយោគមួយចំនួន និងអង្គការអន្តរជាតិជាច្រើនបានចូលមកក្នុងប្រទេស ជាពិសេសអជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC :United Nation Transitional Authority in Cambodia) ដែលបានចូលមកប្រទេសកម្ពុជា ដើម្បីរៀបចំការបោះឆ្នោតបាននាំមកនូវប្រាក់ដុល្លារយ៉ាងច្រើនសម្បើមមកចាក់នៅកម្ពុជាប្រហែលជា ២០០០លានដុល្លារ (១៧០០លានដុល្លារតាមឯកសារមួយ

ចំនួន) ដែលស្មើនឹង ៧៥% នៃផលិតផលក្នុងស្រុកសរុប GDP នៅឆ្នាំ ១៩៩៣ ។ ទន្ទឹមនឹងការបោះឆ្នោតរៀបចំរដ្ឋាភិបាលថ្មីហើយ ប្រទេសកម្ពុជាបានធ្វើសេរីពហុបនីយកម្មខ្លួនតាមរយៈការ ផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចពីប្រព័ន្ធសេដ្ឋកិច្ចបែបផែនការទៅជាប្រព័ន្ធ សេដ្ឋកិច្ចទីផ្សារ ឬបើកចំហរ ។ ពេលនោះរដ្ឋាភិបាលបានអនុញ្ញាតអោយធ្វើការនាំចូល នូវទំនិញគ្រប់ប្រភេទពីប្រទេសជិតខាងដើម្បីបំពេញតំរូវការប្រជាជនដែលនៅខ្វះខាតខ្លាំង។ ពេលនោះគេឃើញមានការហូរចូលនៃរូបិយប័ណ្ណរបស់ប្រទេសជិតខាងជាច្រើន (បាត និងដុង) តាមរយៈការធ្វើជំនួញ និងជនភៀសខ្លួនដែលត្រឡប់មកកាន់ស្រុកកំណើតវិញនៅតាម បណ្តាលខេត្តជាប់ព្រំដែន។ រហូតមកដល់សព្វថ្ងៃនេះ រូបិយប័ណ្ណទាំងនោះបានធ្វើចរាចរយ៉ាងច្រើននៅតាមខេត្តជាប់ព្រំដែនជាពិសេស គឺប្រាក់បាតដែលមានការប្រើប្រាស់យ៉ាងច្រើននៅតាមតំបន់ខាងលិចនៃប្រទេស។

## ១.៥ ប្រភេទនៃរូបិយវត្ថុ[5]

រូបិយវត្ថុត្រូវបានគេឲ្យនិយមន័យថា ជាវត្ថុទាំងឡាយណាដែលត្រូវបានគេទទួលស្គាល់ជាទូទៅនៅក្នុងការទូទាត់លើថ្លៃទំនិញ និងសេវាកម្ម។ រូបិយវត្ថុត្រូវបានផ្លាស់ប្តូរពីមាស/ប្រាក់ កាក់ទៅជាក្រដាសប្រាក់ និងទៅជាប្រាក់នៅក្នុងម៉ាស៊ីនេឡិចត្រូនិច។ ឧទាហរណ៍ដូចជា៖ សាច់ប្រាក់បានគេដាក់ និងធ្វើប្រតិបត្តិការដកប្រាក់តាមរយៈម៉ាស៊ីនអេឡិចត្រូនិច (ATM) និងវិក័យបត្រត្រូវបានចំណាយនិងធ្វើប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណែត (Online)។ រូបិយវត្ថុត្រូវបានបែងចែកជា ៤ យ៉ាង ៖

- M0: ជារង្វាស់តូចបំផុតនៃការផ្គត់ផ្គង់រូបិយវត្ថុដែលជារួមមានសាច់ប្រាក់កម្តល់នៅក្នុងធនាគារ និងចំនួនទឹកប្រាក់ដែលធ្វើចរាចរនៅក្នុងសេដ្ឋកិច្ច។ M0 រួមមានសាច់ប្រាក់ ឬទ្រព្យសកម្មដែលអាចបម្លែងជារូបិយប័ណ្ណភ្លាមៗ។
- M1 (Currency): ជាប្រភេទនៃកាតផ្គត់ផ្គង់សាច់ប្រាក់ ដែលរួមមាន កាក់ ក្រដាសប្រាក់។ M1 ត្រូវបានគេប្រើប្រាស់ដើម្បីកំណត់នូវបរិមាណសាច់ប្រាក់ដែលធ្វើចរាចរ។ M1 រួមមានសាច់ប្រាក់ ឬទ្រព្យសកម្មដែលអាចបម្លែងជារូបិយប័ណ្ណបានភ្លាមៗដែរ។

**M1 = Bank Notes + Coins**

- M2: ជាប្រភេទមួយនៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុដែរ ដោយរួមបញ្ចូលទាំង M1 និងរាល់ការដាក់សាច់ប្រាក់ ការសន្សំ និងមូលធននៅក្នុងស្ថាប័នមិនមែនទីផ្សាររូបិយវត្ថុ។ M2 មាន

[5] លោកសាស្ត្រាចារ្យ ងួន ហេង, *សៀវភៅរូបិយវត្ថុ និងធនាគារ*, (ឆ្នាំ២០១៥),ទំព័រ៨&៩

លក្ខណៈទូលាយជាង M1 ។ អ្នកសេដ្ឋកិច្ចប្រើប្រាស់ M2 ដើម្បីពិនិត្យមើលទៅលើចំនួនសាច់ប្រាក់ដែលចរាចរនៅក្នុងសេដ្ឋកិច្ច និងដើម្បីបង្ហាញនូវលក្ខខ័ណ្ឌសេដ្ឋកិច្ចរូបិយវត្ថុ។

**M2 = M1 + Deposit**

- M3: ជាប្រភេទមួយរបស់ការផ្គត់ផ្គង់រូបិយវត្ថុ ដែលរួមមាន M2 និងការដាក់ប្រាក់ដែលមាន រយៈពេលវែង មូលធនពីស្ថាប័នទីផ្សាររូបិយវត្ថុ កិច្ចសន្យាទិញរយៈពេលខ្លី នឹងទ្រព្យសកម្មដែលអាចបម្លែងជាសាច់ប្រាក់ដែលមានមួយចំនួនធំ។ M3 មានលក្ខណៈទូលាយជាង M2 ជារង្វាស់នៃការផ្គត់ផ្គង់រូបិយវត្ថុដែលមានលក្ខណៈទូលាយបំផុត ហើយត្រូវបានអ្នកសេដ្ឋកិច្ចប្រើប្រាស់ដើម្បីប៉ាន់ស្មានការផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ចទាំងមូល។

**M3 = M2 + repurchase agreements + money market fund shares + debt securities with a maturity of up to and including 2 years**

❖ **រូបិយវត្ថុមានមុខងារដូចជា៖**

- ជាមធ្យោបាយនៃការផ្លាស់ប្តូរទំនិញ
- ជាមធ្យោបាយនៃការផ្លាស់ប្តូរតម្លៃនៅក្នុងទីផ្សារ
- ជារង្វាស់សម្រាប់កំណត់តម្លៃទំនិញ និងការសន្សំនិងបំណុលនៅក្នុងសេដ្ឋកិច្ច
- ជាមធ្យោបាយនៅក្នុងការសងបំណុល ជាដើម។

❖ **គោលការណ៍សំខាន់របស់រូបិយវត្ថុ មាន៥យ៉ាង៖**

- ពេលវេលាមានតម្លៃ
- ហានិភ័យ
- ពត៌មានគឺជាមូលដ្ឋានគ្រឹះនៃការសម្រេចចិត្ត
- ទីផ្សារជាះអ្នកកំណត់ថ្លៃ និងជាអ្នកបែងចែកធនធាន
- ស្ថេរភាពជំរុញសុខមាលភាព។

## ១.៦. និយមន័យ និងប្រភេទដុល្លាររូបនីយកម្ម[6]

ដុល្លាររូបនីយកម្មត្រូវទទួលស្គាល់ជាទូទៅថា ជាការកាន់កាប់ទ្រព្យសកម្ម ឬប្រើប្រាស់រូបិយប័ណ្ណ ដោយនិវេសជននៅក្នុងអធិបតេយ្យភាពនៃប្រទេសមួយ។ ដុល្លាររូបិយកម្ម មិនសំដៅតែលើការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ជំនួសឲ្យ ឬស្របពេលជាមួយរូបិយវត្ថុនៅក្នុងប្រទេសមួយ

[6] សៀវភៅធនាគារជាតិនៃកម្ពុជា *ការពង្រឹងការប្រើប្រាស់ប្រាក់រៀល* (បោះពុម្ពលើកទី១ ឆ្នាំ២០១៧) ទំព័រ៨&៩

នោះទេប៉ុន្តែសំដៅទៅលើ ការប្រើប្រាស់រូបិយប័ណ្ណនានាផងដែរដូចជាប្រាក់អឺរ៉ូ ប្រាក់ផោនអង់គ្លេស ប្រាក់យ៉េន ជប៉ុន ជាដើម។

ដុល្លារូបនីយកម្មអាចកើតឡើងដោយសារកត្តាសត្យានុម័តិ ឬអត្តនោម័តិ។ តត្តានុម័តិសំដៅលើមូលហេតុដែលនាំឲ្យមានដុល្លារូបនីយកម្ម មិនមែនជាការសម្រេចរបស់អាជ្ញាធរក្នុងការទទួលយករូបិយប័ណ្ណធ្វើជារូបិយវត្ថុនីត្យានុកូល។ ដុល្លារូបនីយកម្មប្រភេទនេះត្រូវបានគេហៅថាដុល្លារូប-នីយកម្មមិនផ្លូវការ (Unofficial Dollarization ឬ De facto dollarization ) ។ មូលហេតុចម្បងដែលបណ្តាលឲ្យមានដុល្លារូបនីយកម្មមិនផ្លូវការនេះ គឺដោយសារកត្តាជំនឿទុកចិត្តទីផ្សារ ឬលទ្ធភាពដែលអាចទទួលបាន និងប្រើប្រាស់រូបិយប័ណ្ណរបស់ភ្នាក់ងារសេដ្ឋកិច្ច។ ក្នុងករណីនេះ រូបិយប័ណ្ណ មិនមែនជាឯកតាថ្លៃរបស់វិស័យសាធារណៈនោះទេ។ រូបិយវត្ថុក្នុងស្រុកនៅតែបន្តចរាចរជាមួយរូបិយប័ណ្ណ នៅក្នុងប្រតិបត្តិការសេដ្ឋកិច្ចនានា ដែលស្ថានភាពនេះក៏ត្រូវបានគេចាត់ថ្នាក់ជាដុល្លារូបិយកម្មមិនទាំងស្រុង (Partial dollarization) ផងដែរ។

ចំណែកឯ កត្តាអត្តនោម័ត គឺសំដៅលើការសម្រេចចិត្តរបស់អាជ្ញាធរក្នុងការទទួលស្គាល់ និងប្រើប្រាស់រូបិយប័ណ្ណណាមួយជាផ្លូវការ (De jure dollarization ឬ Official Dollarization) ដែលអាចបណ្តាមកមពីការសម្រេចចិត្តផ្នែកនយោបាយ ឬកត្តាសេដ្ឋកិច្ច ដូចជាអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពទន់ខ្សោយនៃប្រព័ន្ធហិរញ្ញវត្ថុ។ នៅក្នុងករណីនេះ រូបិយប័ណ្ណគឺជារូបិយវត្ថុនីត្យានុកូល ហើយដុល្លារូបនីយកម្មប្រភេទនេះ ត្រូវបានចាត់ទុកថ្នាក់ជាដុល្លារូបនីយកម្មទាំងស្រុង (Full-dollarization)។

អាស្រ័យទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងបំពេញមុខងាររូបិយវត្ថុ ដុល្លារូបនីយកម្មត្រូវបានបែងចែក ជាបីប្រភេទដូចខាងក្រោម៖

- **ដុល្លារូបនីយកម្មរូបវន្ត (Real Dollarization)** គឺសំដៅលើការប្រើប្រាស់រូបិយប័ណ្ណ ដើម្បីកំណត់ថ្លៃទំនិញនិងសេវា ដែលត្រូវដោះដូរក្នុងប្រទេស។ ដុល្លារូបនីយកម្មប្រភេទនេះ ជាទូទៅកើតឡើងនៅពេលដែលទំនិញភាគច្រើនជាទំនិញនាំចូលពីបរទេស ឬដោយសារការបញ្ចៀសហានិភ័យអត្រាប្តូរប្រាក់ជាដើម។
- **ដុល្លារូបនីយកម្មប្រតិបត្តិការ (Transaction Dollarization)** គឺជាស្ថានភាពដុល្លារូបនីយកម្មក្នុងនោះវិស័យឯកជនប្រើប្រាស់រូបិយប័ណ្ណ ដើម្បីធ្វើការទូទាត់ប្រតិបត្តិការដោះដូរក្នុងស្រុកទៅលើទំនិញនិងសេវា។ ដុល្លារូបនីយកម្មនេះ ក៏ត្រូវបានឲ្យឈ្មោះថា ការជំនួស

រូបិយវត្ថុ (Currency Substitution)។ ភាពងាយស្រួលការចំនេញពីការទូទាត់ និងការរក្សា ឬទទួលបានចំណូលជារូបិយប័ណ្ណ គឺជាមូលហេតុចម្បងនៃដុល្លារូបនីយកម្មប្រតិបត្តិការ ។

- **ដុល្លារូបនីយកម្មហិរញ្ញវត្ថុ (Financial Dollarization)** ឬហៅថាការជំនួសទ្រព្យសកម្ម (Assets Substitution) គឺជាស្ថានភាពដុល្លារូបនីយកម្មដែលកើតឡើងដោយសារវិស័យឯកជនក្នុងប្រទេសមួយរក្សាទុកនូវទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុចារឹកជារូបិយប័ណ្ណ ។ មូលហេតុចម្បងដែលនាំឲ្យមានដុល្លារូបនីយកម្មហិរញ្ញវត្ថុ រួមមានភាពទន់ខ្សោយនៃប្រព័ន្ធហិរញ្ញវត្ថុ អស្ថិរភាពអត្រាប្តូរប្រាក់ និងការបាត់បង់ជំនឿទុកចិត្តរបស់វិនិយោគិនមកលើឧបករណ៍ហិរញ្ញវត្ថុចារឹកជារូបិយវត្ថុ។

## ១.៧. សាវតា និងមូលហេតុនៃដុល្លារូបនីយកម្ម

- ក្រោយពីថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ សេដ្ឋកិច្ចកម្ពុជាបានបាត់បង់មូលដ្ឋានគ្រឹះទាំងស្រុងលើគ្រប់វិស័យខណៈដែលប្រព័ន្ធរូបិយវត្ថុ និងធនាគារត្រូវបានបំផ្លាញ។ ពេលនោះប្រជាជនធ្វើការដោះដូរទំនិញ និងទំនិញដោយផ្ទាល់ហើយមួយរយៈបន្ទាប់មក បានយកវត្ថុមានតម្លៃដូចជា មាស ផ្លាទីនធ្វើជាមធ្យោបាយដោះដូរនិងទូទាត់និងសេវា។ នៅខែតុលា ឆ្នាំ ១៩៧៩ ធនាគារកណ្តាលដែលជាអាជ្ញាធររូបិយវត្ថុ ត្រូវបានបង្កើតឡើងវិញ ហើយរូបិយវត្ថុជាតិក៏ត្រូវបានចេញផ្សាយជាថ្មីនា ខែមីនា ឆ្នាំ១៩៨០ និងដាក់ឲ្យប្រើប្រាស់ជាលើកដំបូង។ ប៉ុន្តែក្នុងអំឡុងពេលទសវត្សរ៍ទី៨០នោះ រាល់លើប្រតិបត្តិការធំៗដូចជាការទិញ រថយន្ត និងម៉ូតូផ្ទះត្រូវបានទូទាត់ជាមាស និងផ្លាទីននៅឡើ-យ។ នៅដើមទសវត្សរ៍ទី៨០ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតសកលជាលើកដំបូង ដោយមានការជួយឧបត្ថម្ភយ៉ាងច្រើនពីសំណាក់អង្គការសហប្រជាជាតិ។ វត្តមាននៃ " **អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ**" (United National Authorities in Cambodia, UNTAC) ព្រមទាំងបានបប្រតិបត្តិការរបស់អាជ្ញាធរនេះនៅកម្ពុជា ក្នុងរយៈពេលពីខែធ្នូ ឆ្នាំ ១៩៩២ ដល់ខែកញ្ញាឆ្នាំ ១៩៩៣ បានចំណាយចំនួនប្រមាណ២ពាន់លានដុល្លាអាមេរិច។ នាខណៈនោះ វិស័យធនាគារនៅកម្ពុជាទើបចាប់កំណើតប៉ុណ្ណោះ។ ប្រព័ន្ធធនាគារមានទំហំតូចជាខ្លាំងដោយក្រៅពី "ធនាគារជាតិនៃប្រជាជនកម្ពុជា" ជាធនាគារកណ្តាលគឺមានធនាគារពាណិជ្ជតែពីរប៉ុណ្ណោះ (ធនាគារពាណិជ្ជក្រៅប្រទេសនៃកម្ពុជា និងធនាគារកម្ពុជាពាណិជ្ជចំកាត់) ដែលមានសកម្មភាពបម្រើសេវាធនាគារ ហើយនៅពេលនោះលទ្ធភាពនៃមធ្យោបាយចេញផ្សាយនូវរូបិយវត្ថុជាតិក្នុងបរិមាណដ៏ច្រើនក៏មានកម្រិតដែរ។ អាស្រ័យ

ហេតុនេះ ប្រាក់ដុល្លារដែលហូរចូលមកយ៉ាងកំហុកនៅពេលនោះបានចរាចរណ៍ទទឹមនឹងរូបិយវត្ថុជាតិ ដែលទើបនឹងមានកំណើតថ្មីៗ ហើយបន្ទាប់មកគ្រឹះស្ថានធនាគារពាណិជ្ជក៏អាចមានប្រតិបត្តិការជារូបិយប័ណ្ណបរទេស។

- ចាប់ពីពេលនោះមកប្រជាជនកម្ពុជា និងអ្នកវិនិយោគក្នុងស្រុក និងបរទេសបានចាប់ផ្តើមផ្លាស់ប្តូរពីការប្រើប្រាស់ លោហធាតុមានតម្លៃទៅជា ការប្រើប្រាស់ក្រដាសប្រាក់ដុល្លាដែលជាកត្តាវាស់តម្លៃរួមទាំងក្នុងប្រតិបត្តិការទូទាត់ វិនិយោគ និងសន្សំ។ ការប្រើប្រាស់នេះកាន់តែមានទំហំច្រើនឡើងៗ ដោយសារតែរូបិយប័ណ្ណដុល្លាត្រូវបានចាត់ទុកជារូបិយប័ណ្ណខ្លាំង និងទទួលស្គាល់ជាមធ្យោបាយទូទាត់ អន្តរជាតិគ្មានហានិភ័យអត្រាប្តូរប្រាក់ គួរផ្សំនឹងកត្តាមួយចំនួនទៀតក្នុងស្រុក រួមទាំងអស្ថិរភាពនយោបាយនៅក្នុងប្រទេសនាពេលនោះ រួមនឹងកម្រិតអតិផរណាខ្ពស់ ហើយការបាត់បង់ទំនុកចិត្តរបស់ប្រជាជនលើរូបិយវត្ថុ។ ដូច្នេះ ដុល្លារូបនីយកម្មនៅកម្ពុជាជា "កត្តាប្រវត្តិសាស្ត្រ" និងមិនមែនជាជម្រើសនយោបាយដោយផ្ទាល់របស់រាជរដ្ឋាភិបាលកម្ពុជាឡើយ។ ប៉ុន្តែ ដុល្លារូបនីយកម្មនឹងចោទជាបញ្ហានៅពេលដែលប្រទេសកម្ពុជាកាន់តែពង្រឹងសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងក្របខណ្ឌសេដ្ឋកិច្ចតំបន់។

**Measurement of Dollarization Ratios in Cambodia**

ក្រាហ្វិកទី: ១




Source: National Bank of Cambodia.

## ១.៨ ស្ថានភាពអត្រាប្តូរប្រាក់[7]

### ១.៨.១ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក

កំណើនប្រាក់រៀលបន្តមានស្ថិរភាពល្អប្រសើរ ដោយអត្រាប្តូរប្រាក់មានកម្រិតជាមធ្យម ៤.០៥០រៀលក្នុងមួយដុល្លាអាមេរិក ប្រហាក់ប្រហែលនឹងឆ្នាំ២០១៥ ( ៤.០៦៨ រៀលក្នុងមួយដុល្លារអាមេរិក ) និងបានប្រែប្រួលជាមធ្យមតែ ០,១% ប៉ុណ្ណោះក្នុងមួយខែៗ។ គួរកត់សម្គាល់ដែលថានៅឆ្នាំនេះ តម្លៃប្រាក់រៀក្នុងខែមួយមានបម្រែបម្រួលតាមគន្លងចាស់ (កត្តារដូវកាល) ប៉ុន្តែបើធៀបឆ្នាំលើឆ្នាំតម្លៃប្រាក់រៀលមានកម្រិតខ្ពស់ជាងមុនបន្តិច ជាពិសេសក្នុងអំឡុងដើមឆ្នាំនិងចុងឆ្នាំដែលឆ្លុះបញ្ចាំងពីកំណើនតម្រូវការប្រាក់រៀល។

ក្រាហ្វិកទី២: ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លាអាមេរិក




ប្រភព: ធនាគារជាតិនៃកម្ពុជា

### ១.៨.២ ស្ថានភាពអត្រាប្តូរប្រាក់រៀល ធៀបនឹងរូបិយប័ណ្ណ នៃប្រទេសនាំចូលចម្បងៗរបស់កម្ពុជា

អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម (NEER) និងអត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត (REER) មានស្ថិរភាព ដែលបង្ហាញថាអំណាចទិញរបស់ប្រាក់រៀល និងភាពប្រកួតប្រជែងក្នុងការនាំចេញទំនិញរបស់កម្ពុជាមានលំនឹងធៀបនឹងដៃគូពាណិជ្ជកម្ម។ ជាក់ស្តែង NEER និង REER បានកើនឡើងបន្តិចនៅដើមឆ្នាំ បន្ទាប់មកមានស្ថិរភាពរហូតដល់ខែតុលា ទើបបានធ្លាក់ចុះបន្តិច ប៉ុន្តែបានងើបឡើងវិញនៅចុងឆ្នាំមកកម្រិតប្រហាក់ប្រហែលនឹងពាក់កណ្តាលឆ្នាំ។ ជារួម NEER និង

---
[7] ធនាគារជាតិនៃកម្ពុជា,*របាយការណ៍ប្រចាំឆ្នាំ២០១៦*, ទំព័រ១៧

REER មានបម្រែបម្រួលតិចតួចក្នុងរង្វង់ ៩១,៦ និង ៨៦,៥ រៀងគ្នា បន្ទាប់ពីបានធ្លាក់ចុះជាលំដាប់ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៤ មក។ ស្ថិរភាពនៃ NEER និង REER ពីដើមឆ្នាំ២០១៦ រហូតដល់ខែតុលាជាចម្បងដោយសារការថមថយមកវិញនៃតម្លៃប្រាក់ដុល្លាអាមេរិក បន្ទាប់មកពីការពន្យារពេលនៃការតម្លើងអ-ត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក។ ដោយឡែក ចាប់ពីខែវិច្ឆិកា NEER និង REER បានចាប់ផ្តើមងើបឡើងវិញ ដោយសារប្រាក់ដុល្លារអាមេរិកបានចាប់ផ្តើមឡើងថ្លៃ បន្ទាប់ពីធនាគារកណ្តាលអាមេរិកតម្លើងអត្រាការប្រាក់គោលនៅចុងឆ្នាំ២០១៦នេះ។

ក្រាហ្វិកទី៣: អត្រាប្តូរប្រាក់កម្ពុជា




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ១.៩ ស្ថានភាពរូបិយវត្ថុ

បរិមាណរូបិយវត្ថុដែលត្រូវបានផ្គត់ផ្គង់នៅក្នុងងសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៦ បន្តកើនឡើងក្នុងកម្រិតសមស្រប ដែលមិនបណ្តាលឲ្យមានសម្ពាធដល់អតិផរណាទេ។ ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សេដ្ឋកិច្ច និងរក្សាភាពរឹងមាំនៃវិស័យធនាគារ។

### ១.៩.១ រូបិយវត្ថុទូទៅ

រូបិយវត្ថុទូទៅ (M2) មានកំណើន ២១% (ឆ្នាំលើឆ្នាំ) ប្រហាក់ប្រហែលនឹងអត្រាកំណើនជាមធម្យម ២០% ក្នុងរយៈពេល៥ឆ្នាំក្រោយដែលបន្តគាំទ្រជាចម្បងដោយការកើនឡើងនៃឥណទានចំពោះវិស័យឯកជន ជាពិសេសឥណទានទៅកាន់វិស័យពាណិជ្ជកម្ម កសិកម្ម និងសំណង់នឹងអច-នទ្រព្យ ទោះបីជាល្បឿនកំណើនឥណទានបានថមថយបន្តិចក្តី (២៣% ធៀបនឹង ២៧% នៅឆ្នាំ២០១៥)។ ស្របនឹងទស្សនវិស័យវិជ្ជមាននៃកំណើនសេដ្ឋកិច្ច រូបិយវត្ថុទូទៅត្រូវបាន

ព្យាករណ៍ថា នឹងបន្តមានកំណើនប្រមាណ ១៩% នៅឆ្នាំ២០១៧ គាំទ្រដោយកំណើនឥណទានចំពោះវិស័យឯកជន (ប្រមាណ ២១%) គួបផ្សំនឹងការរំពឹងទុកនូវភាពប្រសើរនៃជញ្ជីងទូទាត់។

ក្រាហ្វិកទី៤: កំណើនរូបិយវត្ថុទូទៅ ឥណទាន ប្រាក់បញ្ញើជារូបិយប័ណ្ណ និងកម្ចីពីបរទេស




ប្រភព : ធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានកំណើនក្នុងអត្រា ២១% (ឆ្នាំលើឆ្នាំ) និងមានសមាមាត្រប្រមាណ ៨៣% នៃរូបិយវត្ថុទូទៅ ដែលជាកម្រិតមួយថេរចាប់ពីឆ្នាំ២០១២មក។ ប្រាក់បញ្ញើជារៀល (មានសមាមាត្រប្រមាណ ៥% នៃរូបិយវត្ថុទូទៅ) បានបន្តកើនឡើងក្នុងអត្រា ២៨% ស្របពេលដែលរូបិយវត្ថុក្នុងចរាចរណ៍ (១២% នៃរូបិយវត្ថុទូទៅ) មានកំណើន ១៦%។ កំណើនរូបិយវត្ថុក្នុងចរាចរណ៍និងប្រាក់បញ្ញើជារៀលបានបង្ហាញថា ប្រាក់រៀលបាននឹងកំពុងបន្តពង្រឹងតួនាទីនៅក្នុងសេដ្ឋកិច្ចតាមរយៈការដោះដូរ ទូទាត់ និងសន្សំ។

ក្រាហ្វិកទី៥: កំណើន និងសមាសធាតុរូបិយវត្ថុទូទៅ



ក្រាហ្វិកទី៦: ផ.ស.ស រូបិយវត្ថុទូទៅ និងឥណទាន




ប្រភព: ធនាគារជាតិនៃកម្ពុជា

កំណើនរូបិយវត្ថុទូទៅបានបង្កើនភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ ដល់កម្រិត ៧៩% ធៀបនឹង ៦៧% នៅឆ្នាំមុន ដោយសារល្បឿនកំណើនរូបិយវត្ថុទូទៅខ្ពស់ជាងល្បឿនកំណើនផ.ស.ស។ ការកើនឡើងនេះមិនបានដាក់សម្ពាធបន្ថែមដល់អតិផរណាទេ ពីព្រោះគ្រឹះស្ថានធនាគារ និងមីក្រូ-ហិរញ្ញវត្ថុមិនបានបង្កើនការផ្តល់ឥណទានក្នុងល្បឿនលឿនជាងមុន ផ្ទុយមកវិញកំណើនឥណទានបានថយចុះសន្សឹមៗ ដោយសន្ទនីយភាពត្រូវបានរក្សាទុក ដើម្បីឆ្លើយតបទៅនឹងការដាក់ចេញនូវគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ក្នុងគោលដៅពង្រឹងក្របខណ្ឌសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ និងកាត់បន្ថយជាសន្សឹមៗនូវកំណើនឥណទាន សំដៅការពារប្រព័ន្ធធនាគារពីហានិភ័យដែលអាចកើតឡើងជាយថាហេតុ។

ក្រាហ្វិកទី៧: ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុនិងកម្រិតដុល្លារូបនីយកម្ម




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ១.១០. គុណសម្បត្តិ និងវិបត្តិនៃការប្រើប្រាស់ដុល្លារូបនីយកម្មនៅកម្ពុជា

ដោយយោងទៅតាមធនាគារជាតិនៃកម្ពុជាបានលើកឡើង ថាដុល្លារូបនីយកម្មនៅកម្ពុជាបានផ្តល់នៅគុណសម្បត្តិ និងគុណវិបត្តិដូចខាងក្រោម៖

### ១.១០.១. គុណសម្បត្តិ ៖

- ដុល្លារូបនីយកម្មបានជម្រុញប្រជាជន ឲ្យងាកពីការនិយមប្រើប្រាស់ប្រាក់ដុល្លាអាមេរិកវិញក្នុងការទូទាត់ឬមធ្យោបាយរក្សាទ្រព្យសម្បត្តិនៅដើមសតវត្សរ៍ទី៩០។
- ដុល្លារូនីយកម្ម បានជួយទប់ស្កាត់លំហូរចេញនៃដើមទុន និងលើកកម្ពស់អន្តរការីយកម្ម និងភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ។ ដុល្លារូបនីយកម្មបានផ្តល់លទ្ធភាពក្នុងការសន្សំជាប្រាក់ដុល្លានៅក្នុងប្រទេស ដូច្នេះ កាត់បន្ថយការដាក់ប្រាក់បញ្ញើរបស់និវាសជននៅក្រៅប្រទេស ហើយប្រភពទុនទាំងនេះ បានយកទៅប្រើប្រាស់ក្នុងការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគ និងការប្រើប្រាស់នានាដែលជួយអភិវឌ្ឍន៍ប្រព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា។ ភាពអំណោយផលទាំងនេះ គួបផ្សំនឹងការរីកចម្រើនវិស័យសេដ្ឋកិច្ច បានជំរុញភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (រូបិយវត្ថុទូទៅ/ផសស) កើនឡើងពី ៥% នៅឆ្នាំ១៩៩៣ ដល់ ៦១% នៅឆ្នាំ២០១៣ ហើយអនុបាតប្រាក់បញ្ញើ និងឥណទានសរុបវិស័យធនាគារធៀបនឹងផ.ស.ស បានកើនពីកម្រិតដ៏ទាបប្រមាណ ២,១% និង ២,៥% ដល់ ៥៣% និង ៥១% រៀងគ្នា។
- ដុល្លារូបនីយកម្មបានកាត់បន្ថយនូវហានិភ័យប្តូរប្រាក់ និងការកេងរកចំនេញពីការធ្វើឲ្យអត្រាប្តូរប្រែប្រួល។ ដោយសារការប្រើប្រាស់ប្រាក់រៀលមានកម្រិតទាប អាជ្ញាធររូបិយវត្ថុអាចគ្រប់គ្រងលើចរាចរណ៍រូបិយវត្ថុជាតិនិងអត្រាប្តូរប្រាក់ ហើយអ្នកកេងចំនេញលើទីផ្សារប្តូរប្រាក់ ក៏មិនអាចទាញចំនេញច្រើនពីការធ្វើឲ្យប្រែប្រួលលើអត្រាប្តូរប្រាក់ដែរ។ កត្តាទាំងនេះ បានរួមចំណែកធ្វើឲ្យកម្ពុជាអាចគេចផុតពីការប្រឈមនឹងវិបត្តិហិរញ្ញវត្ថុអាស៊ីកាលពីឆ្នាំ១៩៩៧-១៩៩៨។
- ការប្រើប្រាស់ប្រាក់ដុល្លារ បានជួយដល់ដំណើរការសមាហរណកម្មវិស័យពាណិជ្ជកម្មអន្តរជាតិ ដោយសារប្រាក់ដុល្លារត្រូវបានប្រើប្រាស់ក្នុងការដោះដូរអន្តរជាតិ ទាំងក្នុងតំបន់ និងពិភពលោក។ កម្រិតបើកចំហពាណិជ្ជកម្មអន្តរជាតិនៃសេដ្ឋកិច្ចកម្ពុជា (ការនាំចេញនិងនាំចូលសរុបធៀបនឹងផ.ស.ស) បានកើនឡើងពី៣៨% នៅឆ្នាំ១៩៩៣ ដល់១០៧% នៅឆ្នាំ២០១៣។

- ដុល្លារូបនីយកម្មបានចូលរួមចំណែកករក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាស្ថិរភាពថ្លៃ និងការពង្រឹងការគោរពវិន័យសារពើពន្ធ (Fiscal discipline) ជាពិសេសក្នុងដំណាក់កាល ដែលសេដ្ឋកិច្ចកម្ពុជាបានជួបប្រទះនឹងអស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ ប្រាក់ដុល្លារ (Hard currency) ត្រូវបានចាត់ទុកជារូបិយប័ណ្ណដែលមានស្ថិរភាពថ្លៃធៀបនឹងរូបិយប័ណ្ណនានា ដូច្នេះ ការប្រើប្រាស់ដុល្លារក៏បានបន្ថយឥទ្ធិពលអត្រាប្តូរប្រាក់លើអត្រាអតិផរណាផងដែរ ( Pass-through effect of exchange rate on inflation ) ។ ទន្ទឹមនេះ រដ្ឋាភិបាលនឹងមិនពឹងផ្អែកលើការបោះពុម្ពរូបិយវត្ថុ ដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិការដ្ឋដែលធ្វើឲ្យ មានផលវិជ្ជមានដល់ការគ្រប់គ្រងសម្ពាធអតិផរណា និងពង្រឹងគោលនយោបាយសារពើពន្ធ។

### ១.១០.២. គុណវិបត្តិ៖

- ការប្រើប្រាស់ប្រាក់ដុល្លាអាចធ្វើឲ្យបាត់បង់អត្តសញ្ញាណជាតិ។ រូបិយវត្ថុជាតិដើរតួនាទីជាអត្តសញ្ញាណជាតិមួយតំណាងឲ្យប្រជាជននិងប្រទេសជាតិ។ ហេតុដូចនេះ ការប្រើប្រាស់រូបិយវត្ថុជាតិតែមួយ គឺជាមោទនជាតិនិងជាការលើកកម្ពស់ស្មារតីជាតិនិយម ភាពជឿជាក់លើរដ្ឋ និងជាតិ និងសាមគ្គីភាពក្នុងចំណោមប្រជាជននៃសង្គមមួយ។ តាមរយៈរូបភាពនៅលើរូបិយវត្ថុជាតិ ប្រជាជនដែលកាន់រូបិយវត្ថុជាតិ នឹងមើលឃើញជារៀងរាល់ពេលពីទិដ្ឋភាពទាំងផ្នែកប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច ដូចជាវីរៈបុរសជាតិរបស់ខ្លួន ហេតុការណ៍សំខាន់ៗដែលបានកើតឡើងនៅក្នុងប្រទេសក៏ដូចជាភាពរីកចម្រើននៃសង្គមជាតិ ហើយរូបភាពទាំងនេះនឹងរំលឹកជារៀងរាល់ពេលថាប្រជាជនដែលកាន់រូបិយវត្ថុនោះស្ថិតក្នុងសង្គមតែមួយមានភាពទាក់ទងគ្នាយ៉ាងជិតស្និទ្ធ និងមានជោគវាសនាតែមួយ។ លើសពីនេះវត្តមានរូបិយវត្ថុជាតិបានបង្ហាញពីអធិបតេយ្យនៃប្រទេស មួយទាំងផ្នេករូបិយវត្ថុ សេដ្ឋកិច្ច ហិរញ្ញវត្ថុ សង្គម និងនយោបាយ។
- ដុល្លារូបនីយកម្ម បានធ្វើឲ្យមានការប្រើប្រាស់ប្រាក់ច្រើនប្រភេទនៅក្នុងសេដ្ឋកិច្ចកម្ពុជា ដែលធ្វើឲ្យមានការខាតបង់ក្នុងប្រតិបត្តិដោះដូរ។ ការប្រើប្រាស់រូបិយវត្ថុជាតិតែមួយនឹងរួមចំណែកកាត់បន្ថយចំណាយប្រតិបត្តិការ (Transaction Costs) ជាពិសេសការខាតបង់ពីការប្តូរប្រាក់ នៅក្នុងវិស័យសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ។
- ដុល្លារូបនីយកម្មបានដាក់កំហិតដល់ជម្រើសឧបករណ៍ និងប្រសិទ្ធភាពនៃគោលនយោបាយសេដ្ឋកិច្ច ។ ការប្រើប្រាស់រូបិយវត្ថុកាន់តែទូលំទូលាយនៅគ្រប់វិស័យទាំង

កាន់តែទូលំទូលាយនៅគ្រប់វិស័យទាំងអស់ នឹងផ្តល់លទ្ធភាពឲ្យរដ្ឋាភិបាលពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដើម្បីជំរុញ និងរក្សានិរន្តភាពកំណើនដោយសារបរិមាណផ្គត់ផ្គង់រូបិយវត្ថុមានឥទ្ធិពលដោយផ្ទាល់ទៅលើសេដ្ឋកិច្ចរូបវន្ត (ផលិតកម្មនិងការងារ)។

- ដុល្លារូបនីយកម្មធ្វើឲ្យកម្ពុជា ខាតបង់ប្រាក់ចំណូល ពីការបោះពុម្ពក្រដាសប្រាក់ (Seigniorage)។ ចំណូល Seigniorage គឺជាភាពខុសគ្នារវាងតម្លៃរូបិយវត្ថុនិងចំណាយលើការបោះពុម្ព។ នៅពេលដែលមានការប្រើប្រាស់រូបិយវត្ថុជាតិ កាន់តែច្រើនរដ្ឋាភិបាលនឹងទទួលបាននូវប្រាក់ចំណូល Seigniorage កាន់តែច្រើនដែរ ដែលអនុញ្ញាតឲ្យរដ្ឋាភិបាលអាចគរពូនទ្រព្យសម្បត្តិជាតិ ឬយកទៅប្រើប្រាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិសំខាន់ៗ។
- ដុល្លារូបនីយកម្មបានធ្វើឲ្យធនាគារកណ្តាលបាត់ ឬដើរតួនាទីបានតិចតួចជាអ្នកឲ្យខ្ចីចុងក្រោយ ហើយប្រឈមនឹងហានិភ័យសន្ទនីយភាព។ ការប្រើប្រាស់រូបិយវត្ថុជាតិកាន់តែទូលាយនឹងអនុញ្ញាតឲ្យធនាគារកណ្តាលដើរតួនាទី ជាអ្នកឲ្យខ្ចីចុងក្រោយកាន់តែមានប្រសិទ្ធភាពដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ការពង្រឹងតួនាទីនេះនឹងបង្កើនជំនឿទុកចិត្តរបស់ភ្នាក់ងារសេដ្ឋកិច្ចមកលើវិស័យហិរញ្ញវត្ថុ និងលើកកម្ពស់សមត្ថភាពបង្ការវិបត្តិរបស់ធនាគារកណ្តាល។
- ដុល្លារូបនីយកម្ម បានធ្វើឲ្យប្រព័ន្ធធនាគារកម្ពុជាប្រឈមនឹងហានិភ័យតារាងតុល្យការ។ ដោយសារតែដុល្លារូបនីយកម្មមានលក្ខណៈមិនទាំងស្រុង គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជានឹងមានភាពងាយរងគ្រោះ ដែលបណ្តាលមកពីការកាន់នូវទ្រព្យសកម្ម និងអសកម្មជារូបិយវត្ថុខុសគ្នា។ ការប្រើប្រាស់រូបិយវត្ថុតែមួយក្នុងប្រព័ន្ធហិរញ្ញវត្ថុនឹងកាត់បន្ថយនូវហានិភ័យ និងពង្រឹងភាពធន់នឹងវិបត្តិរបស់ប្រព័ន្ធហិរញ្ញវត្ថុ។

# ជំពូកទី២
# ស្ថានភាពទូទៅនៃធនាគារជាតិ នៃ កម្ពុជា

## ២.១ ប្រវត្តិសង្ខេបរបស់ធនាគារជាតិ នៃ កម្ពុជា[8]

ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតនៅទី ២៣ ខែ ធ្នូ ឆ្នាំ១៩៥៤ បន្ទាប់ពីប្រទេសបានទទួលឯករាជ្យពីអាណានិគមនិយមបារាំង និងបន្ទាប់ពីវិទ្យាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ ។ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយប្រាប់រៀលដោយឯករាជ្យរបស់ខ្លួន ដើម្បីបញ្ចប់ជាស្ថាពរនូវ សម្ព័ន្ធភាពជាមួយប្រាក់ វៀតណាម និង ឡាវ។ ពេលនោះប្រព័ន្ធធនាគារក្នុង ប្រទេសត្រូវបានបង្កើតឡើងដោយមានធនាគាររដ្ឋ និងធនាគារឯកជនធ្វើប្រត្តិការ ដោយបានធ្វើការកែទម្រង់ ប្រព័ន្ធធនាគារជាបន្តបន្ទាប់ ដើម្បីតម្រូវទៅតាមសេចក្តីត្រូវការទន្ទឹមគ្នាក្នុងប្រទេសកម្ពុជា។

នៅឆ្នាំ ១៩៦៤ ដើម្បីបំរើឲ្យគោលនយោបាយកសាងជាតិនាសង្គមរាស្ត្រ នៃសេដ្ឋកិច្ចជាតិនាសម័យនោះ ដោយបានប្រែក្លាយធនាគារជាតិនៃកម្ពុជា ពីទម្រង់ស្ថាប័នពាក់កណ្តាលស្វ័យតទៅជាធនាគាររដ្ឋក្រោម ទម្រង់ជាស្ថាប័នសាធារណៈ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្មចំណែកឯ ធនាគារពាណិជ្ជក្នុងប្រទេស និងក្រៅប្រទេសបានបិទទ្វារ ហើយរដ្ឋបានបង្កើតធនាគារដែលកាន់កាប់ដោយរដ្ឋមួយចំនួនដូចជា ធនាគារឥណទានជាតិ ធនាគារអភិវឌ្ឍន៍ និងធនាគារកសិកម្មជនបទ។

ចាប់តាំងពីចុងឆ្នាំ ១៩៧០ រហូតដល់ខែមេសា ឆ្នាំ១៩៧៥រដ្ឋបានធ្វើសេរីភាវូបនីយកម្មជាថ្មីទៅលើប្រព័ន្ធធានាគារ។ ធនាគារឯកជនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាព ទន្ទឹមគ្នានឹកធនាគាររដ្ឋក្រោមការបញ្ជាណែនាំ និងការត្រួតពិនិត្យរបស់ធនាគារជាតិកម្ពុជា ។

ជាអកុសលនៅថ្ងៃ ១៧ ខែមេសា ឆ្នាំ ១៩៧៥ ធនាគារជាតិនៃកម្ពុជា ត្រូវបានបិទទ្វារប្រព័ន្ធធានាគារទូទាំងប្រទេសត្រូវបានលុបបំបាត់ចោល អាគារធនាគារជាតិត្រូវបានកម្ទេចរូបិយប័ណ្ណជាតិត្រូវបានឈប់ប្រើប្រាស់ ។

រហូតមកដល់ឆ្នាំ ១៩៧៥ ទើបធនាគារជាតិត្រូវបានរៀបចំឡើងវិញ ពីកំរិតសូន្យទាំងហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សត្រូវបានប្រមែមូល រួចធ្វើលារកសាងជាបណ្តើរៗ រហូតបង្កើតបានជាធនាគារជាតិមួយដែលមានឈ្មោះថា ″ធនាគារជាតិនៃកម្ពុជា″ ។ ដោយសារអាគារធនាគារ

[8] https://www.nbc.org.kh/about_the_bank/history_of_nbc.php (ចូលថ្ងៃទី ២១ មេសា ២០១៧)

ក្រហមត្រូវវាយកម្ទេចទៅហើយនោះ ធនាគារជាតិកម្ពុជាបានបើកស្នាក់ការកណ្តាលរបស់ខ្លួនជាបណ្តោះអាសន្ននៅលើអគារអតីតធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម ហើយបានរៀបចំរចនាសម្ព័ន្ធក្បាលម៉ាស៊ីនដឹកនាំនិងសកម្មភាពប្រតិបត្តិការនៅទីស្នាក់ការកណ្តាល និងបានពង្រីកបណ្តាញទៅបណ្តាខេត្តក្រុងទាំង២០ ទូទាំងប្រទេស ធនាគារជាតិកម្ពុជាបានបោះផ្សាយប្រាក់រៀលឡើងវិញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដើម្បីជួយសម្រួលដល់ការទូទាត់ក្នុងជីវភាពរស់នៅរបស់ប្រជា-ជន។ ចំណែកឯអាគារធនាគារជាតិដែលបានបែកបាក់ ត្រូវបានរុះរើ និងសាងសង់ជាថ្មីឡើងវិញនៅឆ្នាំ១៩៩០។

ចាប់តាំងពីឆ្នាំ១៩៨៩ ប្រព័ន្ធធនាគារត្រូវបានធ្វើការកែទម្រង់។ ធនាគារខេត្ត-ក្រុង ទាំង២០ ត្រូវបានប្តូរឈ្មោះមកជាធនាគារឯកទេសខេត្ត-ក្រុងវិញ ហើយធ្វើសកម្មភាពនៅលើដែនដីរបស់ខ្លួនតាមរបបស្វ័យភាពសេដ្ឋកិច្ច និងស្វ័យភាពហិរញ្ញវត្ថុ ដោយមានធនាគារជាតិនៃកម្ពុជា ជាអ្នកបញ្ជាណែនាំនិងត្រួតពិនិត្យ។ ក្រោយពីមានសន្និសីទសន្តិភាពទីក្រុងប៉ារីសនាថ្ងៃទ២៣ ខែតុលា ឆ្នាំ១៩៩១ របត់នយោបាយមួយត្រូវបានបង្កើតឡើង របបសេដ្ឋកិច្ចត្រូវបានផ្លាស់ប្តូរពី សេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរី ដែលញាំងឲ្យមានការកែប្រែប្រព័ន្ធ ធនាគារនៅកម្ពុជាពីប្រព័ន្ធធនាគារមួយថ្នាក់មកជាប្រព័ន្ធធនាគារពីរថ្នាក់ ហើយរដ្ឋបានបើកទូលាយចំពោះអាជីវកម្មលើវិស័យធនាគារតាមរយៈ ការអនុញ្ញាតឲ្យមានធនាគារពាណិជ្ជក្រោមច្បាប់ក្នុងស្រុក ឬក្រោមទម្រង់ជាសាខាធនាគារបរទេស។ ប្រការនេះតម្រូវឲ្យធនាគារជាតិនៃកម្ពុជាបានពង្រឹងតួនាទីរបស់ខ្លួន ដើម្បីបង្កើនសមត្ថភាពបញ្ជាំណែនាំ និងត្រួតពិនិត្យដោយបានបង្កើតច្បាប់ និងប្រកាសផ្សេងៗជាបន្តបន្ទាប់រួមមាន៖

- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា រដ្ឋសភាបានអនុម័តនៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦។ ច្បាប់នេះបានកំណត់បេសកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុ-ជាគឺ "កំណត់ និងដឹកនាំ នយោបាយរូបិយវត្ថុ ដើម្បីរក្សាថ្លៃឲ្យមានស្ថេរភាព"
- ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៧។
- ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលរដ្ឋសភាអនុម័ត នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងចុងក្រោយនេះធនាគារជាតិនៃកម្ពុជាបានចងក្រង ឯកសារចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០០១-២០១១ ដែលជាឯកសារទុកជាយុទ្ធ-សាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជាឲ្យមានភាពជឿនលឿន ប្រកបដោយ

ជំនឿទុកចិត្តពីសាធារណជន និងអាចធ្វើសមាហរណកម្មចូលទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុពិភពលោក ដូចនេះក្នុងនាមជាធនាគារកណ្តាល ដើម្បីលើកមុខមាត់ និងកិត្យានុភាពរបស់ខ្លួន ឲ្យសាកសមជាអាជ្ញាធរ អាណាព្យាបាលលើវិស័យធនាគារអគារធនាគារជាតិនៃកម្ពុជា ត្រូវបានកែលំអរផ្នែកសោភ័ណ្ឌភាពនៅឆ្នាំ២០០៣។ សរុបសេចក្តីមក ដើមកំណើតនេស់ធនាគារជាតិនៃកម្ពុជាចែកចេញជា ៤ដំណាក់កាល ៖

- **ឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៦៤** : ប្រទេសកម្ពុជាបានទទួលឯករាជ្យពីអាណានិគមនិយមបារាំងក្នុងឆ្នាំ ១៩៥៤ ហើយធនាគារជាតិនៃកម្ពុជាក៏ត្រូវបានបង្កើតឡើង។ ធនាគារជាតិនៃកម្ពុជាទទួលភារៈផ្តាច់មុខជាអ្នកបោះពុម្ពប្រាក់រៀល ដែលជារូបិយវត្ថុជាតិនិងគ្រប់គ្រងប្រព័ន្ធធនាគារនៅកម្ពុជា។
- **ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩** : ធនាគារជាតិនៃកម្ពុជាត្រូវបានបិទ ដោយសាររបបកម្ពុជាប្រជា-ធិបតេយ្យ (ខ្មែរក្រហម) ។ អគារស្នាក់ការត្រូវបានកម្ទេច រូបិយវត្ថុជាតិត្រូវបានឈប់ប្រើប្រាស់ ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុង។
- **ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣** : ធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញពីចំណុចសូន្យ។ ទទឹមនេះ រូបិយវត្ថុជាតិក៏ត្រូវបានបោះផ្សាយឡើងវិញ។ កម្ពុជាបានប្តូរពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចសេរី។
- **ឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន** : ប្រព័ន្ធធនាគារត្រូវបានពង្រឹង និងធ្វើទំនើបភាវូបនីយកម្មជាលំដាប់ ហើយកម្ពុជាក៏បានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្លាំងជាងគេនៅលើពិភពលោក។

## ២.២. អគាររបស់ធនាគារជាតិ នៃ កម្ពុជា

រូបភាពទី:១



ឯករាជ្យភាពនិងការបង្កើតឡើងវិញ (១៩៥៤-១៩៦៤)



ធនាគារជាតិ នៃ កម្ពុជាពេលដែលបែកបាក់






ធនាគារជាតិ នៃ កម្ពុជានាពេលបច្ចុប្បន្ន

## ២.៣ ទីតាំង និងភូមិសាស្ត្ររបស់ធនាគារជាតិ នៃ កម្ពុជា

### ធនាគារជាតិនៃកម្ពុជា ស្នាក់ការកណ្តាល

- អាសយដ្ឋាន: អគារលេខ២២-២៤ មហាវិថីព្រះនរោត្តម,ភ្នំពេញ,ព្រះរាជាណាចក្រកម្ពុជា
- ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៥៦៣, ៧២២ ២២១
- (៨៥៥) ៧២២ ១៨៩ ( ការិយាល័យឯកឧត្តម ទេសាភិបាល)
- ទូរសារ:(៨៥៥-២៣) ៤២៦ ១១៧
- អ៊ីមែល: info@nbc.org.kh
- គេហទំព័រ: http://www.nbc.org.kh

រូបភាពទី២




ប្រភព:Google Map

## ២.៤ រចនាសម្ព័ន្ធរបស់ធនាគារជាតិ នៃ កម្ពុជា[9]

ក្រុមប្រឹក្សាភិបាល ជាអង្គការគ្រប់គ្រងថ្នាក់ខ្ពស់បំផុតរបស់ធនាគារជាតិនៃកម្ពុជា ហើយដឹកនាំដោយទេសាភិបាល នៅពេលដែលទេសាបាលអវត្តមានទេសាភិបាលរងជាអ្នកជំនួស។ ក្នុងករណីចាំបាច់ទេសាភិបាលអាចតែងតាំងឧបការីមួយរូប ឬច្រើនរូបតំណាងរបស់ខ្លួន។ ក្នុងតំណែងរបស់ខ្លួនទេសាភិបាល និងទេភិបាលរងមិនអាចជាមន្ត្រីរាជការ ទីប្រឹក្សាអង្គភាពសាធារណ: ជាសមាជិករាជរដ្ឋាភិបាល និងសមាជិករដ្ឋសភាទេលើកលែងតែតំណាងឲ្យប្រមុខរាជរដ្ឋាភិបាល និងតំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំងតំណាងមជ្ឈដ្ឋានឧត្តមសិក្សាតែម្នាក់ៗអាចរក្សាលក្ខណ:ជាមន្ត្រីរាជការបាន។

ទេសាភិបាលមានតួនាទី ជាអ្នកដឹកនាំទីមួយនៃធនាគារកណ្តាល និងទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាលើកិច្ចការអនុវត្តនយោបាយរបស់ខ្លួន។ ទេសាភិបាលត្រូវទទួលខុសត្រូវលើការដឹកនាំកិច្ចការរបស់ធនាគារជាតិនៃកម្ពុជា និងមានសិទ្ធិអំណាចធ្វើកិច្ចការទាំងឡាយណាដែលមិនបាន កំណត់សម្រាប់ក្រុមប្រឹក្សានៅក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ឬបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ។

រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា បែងចែកជាក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបា-លនេះត្រូវបានដឹកនាំដោយទេសាភិបាល ហើយមានសមាជិក៧រូប គឺទេសាភិបាល ទេសាភិបាលរង និងសមាជិក៥រូបទៀត ដែល១រូបជំណាងឲ្យប្រមុខរដ្ឋាភិបាល ១រូបតំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូបតំណាងឲ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច ១រូបតំណាងឲ្យមជ្ឈដ្ឋានឧត្តមសិក្សា និង១រូបទៀតតំណាងឲ្យបុគ្គលិកធនាគារជាតិនៃកម្ពុជា ៖

1. ប្រធាន ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគាជាតិ នៃ កម្ពុជា
2. លោកជំទាវ **នាវ ច័ន្ទថាណា** ទេសាភិបាលរងធនាគាជាតិ នៃ កម្ពុជា
3. ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** តំណាងប្រមុខរាជរដ្ឋាភិបាល
4. ឯកឧត្តម **ជូ គឹមឡេង** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
5. ឯកឧត្តម **អ៊ីវ ចុង** តំណាងមជ្ឈដ្ឋានឧត្តមសិក្សា
6. ឯកឧត្តម **ឡាយ ម៉េងស៊ុន** តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច
7. អ្នកស្រី **ម៉ៅ សុន** តំណាងបុគ្គលិកធនាគាជាតិ

[9] ធនាគាជាតិនៃកម្ពុជា,*របាយការណ៍ប្រចាំឆមាសទី១និងទិសដៅការងារឆមាសទី២ឆ្នាំ២០១៦, ទំព័រ៥៥*

រូបភាពទី:៣

## រចនាសម្ព័ន្ធនៃក្រុមប្រឹក្សាភិបាល




ប្រភព:http://www.nbc.org.kh

### ២.៤.១. រចនាសម្ព័ន្ធ និងមុខងារភារៈកិច្ចរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ

ខាងក្រោមនេះ ជាមុខងារសំខាន់ៗរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ៖

- តាមដាន សិក្សា វិភាគអំពីស្ថានភាព ការវិវត្តនៃសេដ្ឋកិច្ចរូបិយវត្ថុ និងវិស័ហិរញ្ញវត្ថុក្នុងប្រទេស និងក្រៅប្រទេស ដែលអាចមានផលប៉ះពាល់ដល់ការអនុវត្តន៍នយោបាយរូបិយវត្ថុ វិស័យធនាគារ និងវិស័យហិរញ្ញវត្ថុរបស់ប្រទេស ។
- ស្រាវជ្រាវលើប្រធានបទ និងបញ្ហាទាំងឡាយ ដែលបម្រើដល់ការបំពេញតួនាទីប្រកបដោយប្រសិទ្ធភាពរបស់ធនាគារជាតិនៃកម្ពុជាដែលជាធនាគារកណ្តាល។
- រៀបចំឯកសារចងក្រងបោះពុម្ព និងបែងចែកព្រឹត្តិបត្រប្រចាំត្រីមាស របាយការណ៍ឆមាស និងប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា ។
- ទទួលបន្ទុកការងារសហប្រតិបត្តិការក្រៅប្រទេសលើវិស័យធនាគារ និងហិរញ្ញវត្ថុ ។
- បំពេញការងារផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន ។
- ចំណែកឯ រចនាសម្ព័ន្ធនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិត្រូវបានរៀបចំឲ្យមានការិយាល័យ៥ នៅក្រោមឱវាទ ដូចមានអង្គការលេខភ្ជាប់ជាឧបសម្ព័ន្ធដូចជា៖

1. **ការិយាល័យគោលនយោបាយរូបិយវត្ថុ គ្រប់គ្រងផ្ទាល់នូវ ៖**
   - ផ្នែកគោលនយោបាយរូបិយវត្ថុ
   - តាមដានស្ថានភាពសាច់ប្រាក់ងាយស្រួល
   - ផ្នែកទីផ្សាររូបិយវត្ថុ-អន្តរធនាគារ
   - ផ្នែកវិភាគម៉ាក្រូហិរញ្ញវត្ថុ ។
2. **ការិយាល័យស្រាវជ្រាវសេដ្ឋកិច្ចក្នុងស្រុក គ្រប់គ្រងផ្ទាល់នូវ៖**
   - ផ្នែកវិភាគរូបិយវត្ថុ
   - ផ្នែកសេដ្ឋកិច្ចទូទៅ
   - ផ្នែកស្រាវជ្រាវសេដ្ឋកិច្ច ហិរញ្ញវត្ថុ
   - ផ្នែកព្យាករណ៍សេដ្ឋកិច្ច ។

3. **ការិយាល័យសេដ្ឋកិច្ចអន្តរជាតិ គ្រប់គ្រងផ្ទាល់នូវ ៖**
   - ផ្នែកវិភាគទីផ្សាររូបិយប័ណ្ណ ឥណទាន និងទីផ្សារទុនអន្តរជាតិ
   - ផ្នែកវិភាគសេដ្ឋកិច្ចអាស៊ាន និងដៃគូពាណិជ្ជកម្មរបស់កម្ពុជា
   - ផ្នែកវិភាគសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ។
4. **ការិយាល័យសហប្រតិបត្តិការអន្តរជាតិ គ្រប់គ្រងផ្ទាល់នូវ៖**
   - ផ្នែកសហប្រតិបត្តិការគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ
   - ផ្នែកសហប្រតិបត្តិការអាស៊ាន និងដៃគូអាស៊ាន
   - ផ្នែកសហប្រតិបត្តិការស៊ាសិន និងស្ថាប័នពហុភាគីមិនមែនហិរញ្ញវត្ថុ
   - ផ្នែកសហប្រតិបត្តិការទ្វេភាគី ។
5. **ការិយាល័យព្រឹត្តិបត្រ និងរដ្ឋបាល គ្រប់គ្រងផ្ទាល់នូវ៖**
   - ផ្នែកព្រឹត្តិបត្រ
   - ផ្នែកប្រមូលផ្តុំ រក្សាទិន្នន័យ និងឯកសារ
   - ផ្នែករដ្ឋបាល ។

## ២.៤.២. រចនាសម្ព័ន្ធ និងមុខងារ ភារៈកិច្ចរបស់នាយកដ្ឋានស្ថិតិ

នាយកដ្ឋានស្ថិតិ ស្ថិតនៅក្រោមចំណុះអគ្គនាយកបច្ចេកទេស នៃធនាគារជាតិនៃកម្ពុជា ហើយមានមុខងារ និងភារៈកិច្ចមួយចំនួនដូចជា ៖

- ប្រមូល រៀបចំ តម្លើង និងវិភាគតារាងស្ថិតិជញ្ជីងទូទាត់ ស្ថានភាពវិនិយោគអន្តរជាតិស្ថិតិស្ថានភាពរូបិយវត្ថុ និងហិរញ្ញវត្ថុ បំណុលក្រៅប្រទេស ទុនបម្រុងអន្តរជាតិ អត្រាប្តូរប្រាក់ អ-ត្រាការប្រាក់ និងព្យាករណ៍ស្ថិតិ។
- អភិវឌ្ឍន៍ និងអនុវត្តការអង្កេតស្ថិតិ និងប្រមូលទិន្នន័យរដ្ឋបាល និងវិភាគទិន្នន័យស្ថិតិ
- ផលិត និងផ្សព្វផ្សាយស្ថិតិធនាគារជាតិនៃកម្ពុជា តាមរយៈការចេញផ្សាយព្រឹត្តិបត្រ ការបោះពុម្ពផ្សាយ និងឯកសារអេឡិចត្រូនិច ក៏ដូចជាតាមរយៈគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជាឲ្យបានទៀងទាត់។
- បង្កើតយន្តការសម្របសម្រួល ដើម្បីបង្កើនកិច្ចសហប្រតិបត្តិ និងការប្រមូលទិន្នន័យពីនាយកដ្ឋាននានារបស់ធនាគារជាតិនៃកម្ពុជា អង្គភាពស្ថិតិនៃក្រសួងរបស់រដ្ឋាភិបាល និងប្រភពផ្សេងៗទៀត។

- តាក់តែង និងរៀបចំផ្តល់ពត៌មានស្ថិតិជូនថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា និងនាយកដ្ឋានដែលពាក់ព័ន្ធរៀបចំទស្សនាទាន ប្រភពទិន្នន័យ និងវិធីសាស្រ្តចងក្រងស្ថិតិ និងឯកសារពាក់ព័ន្ធផ្សេងទៀត។
- រ៉ាប់រងការពិនិត្យពិច័យស្ថិតិពាក់ព័ន្ធ និងធានាគុណភាពទិន្នន័យ ដើម្បីធ្វើឲ្យប្រសើរឡើងនូវវិធីសាស្រ្តចងក្រង និងដើម្បីធ្វើឲ្យស៊ីគ្នាជាមួយនឹងស្តង់ដាអន្តរជាតិ។

ចំណែកឯរចនាសម្ព័ន្ធនៃនាយកដ្ឋានស្ថិតិត្រូវបានរៀបចំឲ្យមានការិយាល័យ ៤ នៅក្រោមឱវាទមានដូចខាងក្រោម៖

1. **ការិយាល័យស្ថិតិជញ្ជីងទូទាត់ គ្រប់គ្រងផ្ទាល់នូវ ៖**
   - ផ្នែកគណនីចរន្ត
   - គណនីដើមទុន និងហិរញ្ញវត្ថុ
   - ផ្នែកបំណុលក្រៅប្រទេស និងស្ថានភាពវិនិយោគអន្តរជាតិ។
2. **ការិយាល័យធ្វើអង្កេតវិស័យក្រៅប្រទេស គ្រប់គ្រងផ្ទាល់នូវ ៖**
   - ផ្នែកប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ
   - ផ្នែកធ្វើអង្កេតស្ថិតិជញ្ជីងទូទាត់
   - ផ្នែកធ្វើអង្កេតវិនិយោគអន្តរជាតិ។
3. **ការិយាល័យស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ គ្រប់គ្រងនូវ ៖**
   - ផ្នែកស្ថិតិរូបិយវត្ថុ
   - ផ្នែកស្ថិតិហិរញ្ញវត្ថុ
   - ផ្នែកសម្របសម្រួល និងទំនាក់ទំនង។
4. **ការិយាល័យរដ្ឋបាល និងផ្សព្វផ្សាយស្ថិតិ គ្រប់គ្រងនូវ ៖**
   - ផ្នែកបោះពុម្ព និងផ្សព្វផ្សាយស្ថិតិ
   - ផ្នែកគ្រប់គ្រងទិន្នន័យ
   - ផ្នែករដ្ឋបាល។

## ២.៥. មុខងារ និងភារៈកិច្ចរបស់ធនាគារជាតិ នៃ កម្ពុជា

ធនាគារជាតិ នៃ កម្ពុជា ឬធនាគារកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាមានមុខងារ និងភារកិច្ចដូចតទៅៈ

- កំណត់គោលនយោបាយរូបិយវត្ថុ ដោយពីគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។
- ត្រិះរិះ អនុវត្ត និងត្រួតពិនិត្យនយោបាយរូបិយវត្ថុ និងប្តូរប្រាក់អោយសំរេចទៅតាមគោលដៅដែលបានកំណត់។
- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតី រួចចេញផ្សាយលទ្ធផល ហើយលើកសំណើរ និងវិធានការជូនរដ្ឋាភិបាល។
- ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារ ហិរញ្ញវត្ថុ និងគ្រឹះស្ថានឯទៀតដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើម ព្រមទាំងចេញបទបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ ។
- ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ ។
- ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- ទទួលខុសត្រូវ និងអនុវត្តក្នុងនាមនៃព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ជាមួយស្ថាប័នអន្តរជាតិសាធារណៈក្នុងកិច្ចការធនាគារឥណទានរូបិយវត្ថុ។
- តម្លើងតារាងជញ្ជីងទូទាត់។
- ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យជាទេយ្យជាមួយប្រទេសក្រៅ។
- ចូលរួមក្នុងការបង្កើត និងការត្រួតពិត្យទីផ្សារហិញ្ញវត្ថុ
- ផ្តល់ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថាន ដែលចូលរួមក្នុងអាជីកម្មទីផ្សារប្តូរប្រាក់សង្ហារឹមប័ណ្ណ ត្បូងថ្ម និងលោហាធាតុមានតម្លៃព្រមទាំងចេញបទបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ ។
- កំណត់អត្រាប្តូរប្រាក់ ។

ធនាគារជាតិអាចបើកគណនីឲ្យស្ថាប័នរដ្ឋ ឬអង្គភាពរដ្ឋបាលកណ្តាលគ្រឹះស្ថានធនាគារហិរញ្ញវត្ថុ ដែលត្រូវបានអនុញ្ញាតឲ្យធ្វើអាជីវកម្ម ធនាគារកណ្តាលបរទេស និងស្ថាប័នហិរញ្ញវត្ថុ

សាធារណៈអន្តរជាតិប៉ុន្តែមិនអាចបើកគណនីឲ្យសហគ្រាសឧស្សាហកម្ម ឬពាណិជ្ជកម្មបានទេ ទោះជារបស់រដ្ឋក៏ដោយ ។

❖ **ភារកិច្ចចម្បងៗរបស់ធនាគារជាតិនៃកម្ពុជាមានដូចតទៅៈ**

- ទទួលបន្ទុកដឹកនាំគោលនយោបាយរូបិយវត្ថុ
- គ្រប់គ្រងនិងរក្សាស្ថេរភាពថ្លៃប្រាក់រៀលបង្គូលក្ខណៈ ងាយស្រួលដល់សកម្មភាពផលិតកម្ម អភិវឌ្ឍន៍និងដំណើរការពង្រឹងឱកាសរកការងារធ្វើឈានទៅបង្កើន និងកែលំអជីវភាពរសើនៅរបស់ប្រជាជន
- គ្រប់គ្រងធនាគារពាណិជ្ជទៅតាមវិធានការណ៍ផ្សេងៗ នៃគោលនយោបាយរូបិយ-វត្ថុដែលជាមធ្យមរក្សានូវសុវត្ថិភាពនៃមូលនិធិ និងប្រាក់សន្សំសាធារណៈជន។

## ២.៦ ប្រព័ន្ធធនាគារ

### ២.៦.១. ធនាគារជាតិ នៃ កម្ពុជា

ធនាគារជាតិនៃកម្ពុជា គឺជាធនាគារមួយដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណា-ចក្រកម្ពុជា ក្នុងគោលដៅរក្សាថ្លៃឲ្យមានស្ថិរភាពសំដៅបង្គូលក្ខណៈងាយស្រួល ដើម្បីធ្វើអោយសេដ្ឋកិច្ច រីកចំរើន ។

សាខាធនាគារជាតិនៃកម្ពុជាមានខេត្ត-ក្រុងចំនួន ២០ សាខាដូចជា៖

- ខេត្តកំពង់ចាម
- ក្រុងព្រះសីហនុ
- ក្រុងសៀមរាប
- ខេត្តកណ្ដាល
- ខេត្តតាកែវ
- ខេត្តពោធិ៍សាត់
- ខេត្តកំពង់ស្ពឺ
- ខេត្តកោះកុង
- ខេត្តក្រចេះ
- ខេត្តមណ្ឌលគិរី
- ខេត្តស្ទឹងត្រែង។

## ២.៦.២. ធនាគារឯកជន

- **ធនាគារពាណិជ្ជមានចំនួន ១៤ ធនាគារ ដូចជា ៖**
  - ធនាគារវឌ្ឍនៈអាស៊ីចំកាច់
  - ធនាគារកម្ពុជាអាស៊ីចំកាត់ធនាគារកម្ពុជាពាណិជ្ជចំកាត់
  - ធនាគារមេគង្គកម្ពុជាមហាជនទទួលខុសត្រូវមានកំរិត
  - ធនាគារសារជីវកម្មសិង្ហបូរីចំកាច់
  - ធនាគារសហពាណិជ្ជកម្មចំកាត់
  - ធនាគារវឌ្ឍនៈ
- **សាខាធនាគាបរទេសមានចំនួន ៣ ដូចជា ៖**
  - ធនាគារពាណិជ្ជទីមួយចំកាត់
  - ធនាគារក្រុងថៃចំកាត់មហាជន
  - ធនាគារមេយប៉ែង
- **ធនាគាររដ្ឋមានចំនួន ១ គឺ ធនាគារពាណិជ្ជកម្មក្រៅប្រទេស**
- **ធនាគារឯកទេសមានដូចជា ៖**
  - ធនាគាររដ្ឋមានចំនួន១ គឺ ធនាគាររដ្ឋអភិវឌ្ឍន៍ជនបទ
  - ធនាគារឯកទេសចំនួន២ គឺ:
    - ធនាគារឯកទេស ប៉េង ហេងគេស អ៊ឹម អ៊ីចំកាត់
    - ធនាគារឯកទេសកសិកម្ម ឧស្សាហាកម្ម កម្ពុជាចំកាត់
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណចំនួន ៥ដូចជា ៖**
  - ឥណទានមូលដ្ឋានជនបទ
  - ហត្ថាកសិករ
  - មីក្រូហិរញ្ញវត្ថុកម្ពុជាចំកាត់
  - ធនាគារភូមិកម្ពុជា
  - ក្រុមហ៊ុនស្ថាបនាសហគ្រិនកម្ពុជា

ជារួម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាអង្គការក្រៅរដ្ឋាភិបាល ដែលបានចុះបញ្ជីចំនួន ២៩ និងមិនទាន់ចុះបញ្ជីប្រហែល ៦០ទៀត។ ម្យ៉ាងទៀត ហេតុផលពីរយ៉ាងដែលត្រូវបានគេជម្រុញសម្រាប់ការបង្កើតធនាគារជាតិ គឺ:

- ដើម្បីផ្តល់ឲ្យធនាគារមានភាពកាន់តែរឹងមាំ និងរូបិយប័ណ្ណមួយមានការធានា ហើយមានលក្ខណៈដូចៗគ្នា។
- ផ្តល់នូវប្រភពកម្ចីដល់រដ្ឋាភិបាល។

## ២.៧ ស្លាកសញ្ញារបស់ធនាគារជាតិនៃកម្ពុជា

រូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា គឺរៀល "រ" ។ ធនាគារជាតិនៃកម្ពុជាបានជ្រើសរើសស្លាកសញ្ញាជាអក្សរ "រ" នេះធ្វើជាស្លាកសញ្ញាសម្គាល់ស្ថាប័នរបស់ខ្លួន ដោយមានកួរស្រូវព័ទ្ធជុំវិញ ហៅថា កម្រងកួរស្រូវរង្វង់ស្វែងក្របី។

ស្លាកសញ្ញានេះមានអត្ថន័យដូចខាងក្រោម៖

- ព្រះរាជាណាចក្រកម្ពុជាជាប្រទេសដែលពឹងផ្អែកលើកសិកម្ម
- រីឯធនាគារមានប្រវត្តិដើមផ្តល់ឥណទានលើវិស័យកសិកម្មនេះ

ប្រភព:http://www.nbc.org.kh

ក្រាហ្វិកទី៨: ចំនួនមន្ត្រី-បុគ្គលិកនឹងកំរិតសមត្ថភាពបុគ្គលិក(ខែមិថុនា ២០១៥)

## បុគ្គលិក




## កំរិតសមត្ថភាព




ប្រភព: https://www.nbc.org.kh/about_the_bank/staff_data.php

# ជំពូកទី៣

# ការលើកកម្ពស់ប្រាក់រៀល

នៅក្នុងជំពូកនេះបានបែងចែកជា ៥ ដំណាក់កាលដែលរៀបរាប់អំពីប្រាក់រៀលដូចជា សារៈសំខាន់នៃប្រាក់រៀល ចក្ខុវិស័យនៃក្របខណ្ឌនយោបាយ គោលនយោបាយជាតិក្នុងការលើកកម្ពស់ប្រាក់រៀល វិធានការនានាក្នុងការពង្រឹងប្រាក់រៀល។

## ៣.១. សារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀល[10]

រូបិយវត្ថុជាតិតំណាងឲ្យអធិបតេយ្យភាពផ្នែករូបិយវត្ថុ និងភាពរឹងមាំរបស់ជាតិ។ កម្ពុជាចាំបាច់ត្រូវបង្កើនភាពឯករាជ្យពីការប្រើប្រាស់រូបិយប័ណ្ណ ដើម្បីធ្វើឲ្យលទ្ធភាពក្នុងការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចកាន់តែមានប្រសិទ្ធភាពខ្ពស់។ ដោយយល់ឃើញពីសារៈសំខាន់នៃតួនាទីរបស់រូបិយវត្ថុជាតិក្នុងការជំរុញកំណើនសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានអនុវត្តយុទ្ធសាស្ត្រជម្រុញការប្រើប្រាស់ប្រាក់រៀល ដូចដែលបានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ ជាឧទាហរណ៍ ការបង់ពន្ធ និងការទឹកនិងថ្លៃអគ្គិសនី ត្រូវធ្វើឡើងជាប្រាក់រៀល រួមនឹងការរក្សាតម្លៃប្រាក់រៀលតាមរយៈការធ្វើឲ្យអត្រាប្តូរប្រាក់មានស្ថិរភាពជាដើម ។ កន្លងមករាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជាមិនបានប្រើប្រាស់វិធានការរដ្ឋបាល ដើម្បីបង្ខំឲ្យសាធារណជនប្រើប្រាស់ប្រាក់រៀលនោះទេ ដោយហេតុថាវិធាននេះអាចជំរុញឲ្យមានទីផ្សារងងឹតប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនិងលំហូរមូលធនចេញពីប្រទេស។

វត្តមាននៃការអនុវត្តន៍គោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាស់រៀល ពុំមានភាពល្អគ្រប់គ្រាន់នោះទេ។ កត្តាសំខាន់ដែលជំរុញឲ្យមានការផ្លាស់ប្តូរទៅរកការប្រើប្រាស់រូបិយវត្ថុជាតិដើម្បីទទួលបានឯករាជ្យភាពផ្នែករូបិយវត្ថុ អាស្រ័យជាចាំបាច់ទៅលើការចូលរួមចំណែកពីសំណាក់ភាគីដែលពាក់ព័ន្ធទាំងអស់គ្នា។ ការរួមចំណែកទាំងនោះអាចត្រូវបានធ្វើឡើងតាមរយៈការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើនក្នុងជីវភាពប្រចាំថ្ងៃ ចាប់តាំងពីការខ្ចីប្រាក់ជារៀលរហូតដល់ការទិញទំនិញនៅតាមផ្សារ ឬការវិនិយោគសោធននិវត្តន៍ជាដើម។

ការចរាចរណ៍ប្រាក់រៀលមានសារៈសំខាន់ដូចជា ៖

- មោនភាពជាតិ និងសាមគ្គីភាពជាតិ
- រក្សារស្ថេរភាពថ្លៃ
- កាត់បន្ថយចំណាយប្រតិបត្តិការ

[10] សៀវភៅធនាគារជាតិនៃកម្ពុជា "*សារៈសំខាន់នៃប្រាក់រៀលសម្រាប់កម្ពុជា*"

- ជំរុញពាណិជ្ជកម្ម
- ជំរុញវិនិយោគ និងបង្កើតការងារ
- លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ និងសុខុមាលភាពសង្គម
- ជំរុញបរិយាប័ន្នហិរញ្ញវត្ថុ
- គរពូនទុនបម្រុងអន្តរជាតិ
- ចំណូលពីការបោះពុម្ពក្រដាសប្រាក់
- បង្ការការក្លែងក្រដាសប្រាក់

## ៣.២ ចក្ខុវិស័យនិងក្របខណ្ឌគោលនយោបាយ

ដោយពិនិត្យឃើញពីភាពចាំបាច់នៃការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ក្នុងការពង្រឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច សំដៅគាំទ្រកំណើនដោយចីរភាពនិងស្របតាមនិន្នាការសកល និងការត្រៀមខ្លួនសម្រាប់សមាហរណកម្មវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យ៉ាងច្បាស់ពីគោលដៅលើកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងយុទ្ធសស្ត្រចតកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ និងវិធានការនៃការលើកម្ពស់ប្រាក់រៀល និងពង្រឹងតួនាទីរបស់រូបិយវត្ថុជាតិលើប្រតិបត្តិការ ក្នុងវិស័យរូបវន្តក៏ដូចជាវិស័យហិរញ្ញវត្ថុប្រកបដោយនិរន្តន៍ភាព ដើម្បីឈានទៅរកការកាត់បន្ថយជាលំដាប់ នូវការពឹងផ្អែកនៃសេដ្ឋកិច្ចទៅលើរូបិយប័ណ្ណ។

វិធានការលើកកម្ពស់ប្រាក់រៀល អាចត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍នៃការធ្វើបដិដុល្លារូបនីយកម្មនៅក្នុងប្រទេសមួយចំនួន ការសិក្សាស្រាវជ្រាវលើស្ថានភាពដុល្លារូបនីយកម្ម នៅកម្ពុជាដោយសេដ្ឋវិទូ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី និងការធ្វើការអង្កេតថ្មីៗរបស់ការិយាល័យស្រាវជ្រាវ ម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ។ ស្មារតីនៃការរៀបចំគោលនយោបាយនេះ គួរអនុឡោមតាមគោលការណ៍ចម្បង ដូចខាងក្រោម៖

- ដុល្លារូបនីយកម្មបានកើតឡើងនៅក្នុងសេដ្ឋកិច្ច ក្នុងរយៈពេលមួយយូរ ហើយបានចាក់ឬសគល់ទៅក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គម។ ម្យ៉ាងទៀត ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាក៏ដូចជាការអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុ ស្ថិត ក្នុងដំណាក់កាល

អភិវឌ្ឍដំបូងនៅឡើយ។ដូចនេះការធ្វើបដិដុល្លារូបនីយកម្មត្រូវតែជាដំណើរការសន្សឹមៗ និងមួយជំហានម្ដងៗ

- ឆន្ទៈនយោបាយ គឺជាកត្តាបឋម និងមូលដ្ឋានក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ការប្ដេជ្ញាចិត្តយ៉ាងមុតមាំនិងខិតខំប្រឹងប្រែង ដែលត្រូវបានសម្របសម្រួល និងព្រមព្រៀងគ្នារវាងភាគីពាក់ព័ន្ធទាំងអស់គឺ មានភាពចាំបាច់បំផុតពីព្រោះភាពជោគជ័យនៃគោលនយោបាយនេះគឺ អាស្រ័យដោយការចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ របស់ភ្នាក់ងារពាក់ព័ន្ធជាច្រើន ទាំងវិស័យសាធារណៈ និងឯកជន។ ហេតុនេះ ដែលវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលចាំបាច់ ត្រូវរៀបចំជាយុទ្ធសាស្ត្រ ដែលនឹងក្លាយជា គោលនយោបាយរួមរបស់រដ្ឋាភិបាលកម្ពុជា។
- ដោយត្រូវភាពស្មុគស្មាញនិងហានិភ័យនៃការធ្វើបដិដុល្លារូបនីយកម្ម ទិសដៅគោលនយោបាយដ៏ត្រឹមត្រូវនិងប្រកបដោយភាពប្រុងប្រយ័ត្ន ពោលគឺ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ក្នុងរយៈពេលខ្លីនិងមធ្យម។ ដូច្នេះ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល មិនសំដៅលើការបញ្ឈប់ការប្រើប្រាស់ប្រាក់ ដុល្លាអាមេរិក (ការធ្វើបដិដុល្លារូបនីយកម្ម) ភ្លាមៗឬដោយគំហុកនៅក្នុងសេដ្ឋកិច្ចជាតិនោះទេ។
- វិធានការរយៈពេលខ្លីនិងមធ្យមនេះផ្ដោតចេញជាចម្បងទោលើការលើកទឹកចិត្ត ចំពោះការ ប្រើប្រាស់ប្រាក់រៀល ជាជាងការដាក់គំនាបទៅលើការប្រើប្រាស់ប្រាក់ដុល្លារ។ គោលនយោបាយនេះ បានដាក់គំនាបអាចបណ្ដាលឲ្យមានការហូរចេញនៃមូលនិធិសេដ្ឋកិច្ចជាតិ និងកាត់បន្ថយអន្តរការីយកម្មហិរញ្ញវត្ថុ។ ការដាក់ចេញវិធានការត្រូវមានការពិចារណាយ៉ាង ម៉ត់ចត់ដើម្បីជៀសវាងបង្កឧបសគ្គ ចំពោះដំណើរការយ៉ាងសកម្មនៃការអភិវឌ្ឍន៍រចនាសម្ព័ន្ធ ទីផ្សារក្នុងប្រទេសនាពេលបច្ចុប្បន្ន។
- វិធានការរដ្ឋបាលមួយចំនួនអាចនឹងចាំបាច់ត្រូវបានយកមកពិចារណា និងដាក់ឲ្យប្រើប្រាស់ សំដៅកែប្រែឥរិយាបថ និងទម្លាប់របស់សាធារណៈជនឲ្យងាកមករកការប្រើប្រាស់ប្រាក់រៀល។ វិធានការរដ្ឋបាលទាំងនោះគួរតែត្រូវបានចាត់ទុកជាឧបករណ៍គាំទ្រ និងបន្ទាប់បន្សំដែលគប្បីត្រូវតែបានអនុវត្តដោយប្រុងប្រយ័ត្ន។
- វិធានការនេះ ក៏បានបញ្ចូលផងដែរនូវទស្សនៈអនាគត ដែលមានទិសដៅទប់ស្កាត់ការកើតមានឡើងនូវសកម្មភាព ឬប្រតិបត្តិការទាំងឡាយណា ដែលអាចប៉ះពាល់ដល់ការខិតខំក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

- ការកើនឡើងនូវការប្រើប្រាស់ប្រាក់រៀល និងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ច ហើយជាសក្យានុម័តនឹងមកនូវការប្រែប្រួលកក្ខខណ្ឌ ដែលធ្វើឲ្យមាការផ្លាស់ប្តូរទិដ្ឋភាពការរៀបចំនិងដំណើរការនៃសេដ្ឋកិច្ចកម្ពុជាទាំងមូល ។ ហេតុនេះ ការសម្រេចបាននូវគោលដៅខាងលើត្រូវការដំណោះស្រាយយូរអង្វែង និងទាមទារនូវគោលនយោបាយ និងផែនការសកម្មភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ
- ផែនការសកម្មភាពនេះក៏មានបញ្ចូលកម្មវិធីកំណែទម្រង់ ដែលត្រូវបានកំណត់សម្រាប់ រយៈពេលខ្លី មធ្យម និងវែង ហើយផ្តោតទៅលើមុខព្រួញសកម្មភាពសំខាន់ៗ ដែលអាចអនុញ្ញាតឲ្យមានការកែប្រែនូវឥរិយាបថ ទម្លាប់ និងការលើកទឹកចិត្តដល់ការផ្លាស់ប្តូរនូវទស្សនៈរបស់សាធារណៈជនឲ្យនិយមប្រើប្រាស់រូបិយវត្ថុជាតិ។ សកម្មភាព និងគំនិតផ្តួចផ្តើមនា នាតាមផ្នែកនិងវិស័យពាក់ព័ន្ធ។ សកម្មភាពនិងគំនិតផ្តួចផ្តើមមួយចំនួន អាចនិងគួរមានអាទិភាពអនុវត្តមុនសកម្មភាពដទៃ ដែលនាំឲ្យដំណើរការអនុវត្តមានលំដាប់លំដោយនិងជំហានបន្តបន្ទាប់សមស្រប។

ដោយសារវិសាលភាពនៃវិធានការគោលនយោបាយ ដែលត្រូវអនុវត្តនិងភាពស្មុគស្មាញនៃបញ្ហា ផុល្លារូបនីយកម្មនេះមានលក្ខណៈ ជាផែនការរំកិល ដើម្បីអាចពិនិត្យវាយតម្លៃ និងកែលំអរតាមការចាំបាច់ ចំពោះវិធានការគោលនយោបាយដែលបានដាក់ចេញ រួមទាំងដំណើរការអនុវត្តដែលពាក់ព័ន្ធដោយផ្អែកលើកម្រិតនៃវឌ្ឍនភាពដែលបានទទួលបាន។ ទទ្ទឹមនេះ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយឲ្យមានសង្គតិភាព និងអនុញ្ញាត ឲ្យមានភាពបត់បែនតាមស្ថានភាពជាក់ស្តែង យុទ្ធសាស្ត្រនេះត្រូវបានបែងចែកជា ២ផ្នែកគឺ គោលដៅនៃគោលនយោបាយ និងផែនការសកម្មភាពលម្អិតដើម្បីឈានទៅសម្រេចគោលនយោបាយនីមួយៗ។

## ៣.៣ ការពិភាក្សាលើគោលនយោបាយជាតិក្នុងការលើកម្ពស់ប្រាក់រៀល

ដើម្បីសម្រេចឲ្យបាននូវគោលដៅរួមលើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ការកំណត់ឲ្យបានច្បាស់នូវទិសដៅនៃគោលនយោបាយចម្បងៗតាមវិស័យ និងការទទួលបន្ទុកដឹកនាំអនុវត្ត និងសហការអនុវត្តមានសារៈសំខាន់ណាស់ ។ លើសពីនេះ គោលនយោបាយគាំទ្រនានាដទៃទៀត នឹងរួមចំណែកឲ្យដំណារការឆ្ពោះទៅកាន់ភាពជោគជ័យមានភាពរលូននិងប្រសិទ្ធភាព។ ខាងក្រោមនេះជាគោលនយោបាយនានាដែលជួយលើកកម្ពស់ប្រាក់រៀល មាន៩គឺៈ

### ៣.៣.១. គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់

ក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ កម្ពុជារក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងល្អប្រសើរដែលឆ្លុះបញ្ចាំងតាមរយៈស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់។ ស្ថិរភាពនេះបានបង្កើនជំនឿទុកចិត្តរបស់សាធារណជននិងភ្នាក់ងារសេដ្ឋកិច្ចនានា មកលើសេដ្ឋកិច្ចនិងការប្រើប្រាស់រូបិយវត្ថុជាតិជាលំដាប់ ព្រមទាំងបានបើកកាលានុវត្តភាពឲ្យអាជ្ញាធរដាក់ឲ្យអនុវត្តវិធានថ្មីៗបន្ថែម ទៀតដើម្បីជម្រុញប្រើប្រាស់រូបិយវត្ថុជាតិឲ្យកាន់តែទូលំទូលាយឡើង។

គោលនយោបាយរូបិយវត្ថុ គួរបន្តអនុវត្តដោយទន់ភ្លន់និងប្រុងប្រយ័ត្នសំដៅធានាឲ្យបានស្ថិរភាពថ្លៃដើម្បីការពារអំណាចទិញរបស់រូបិយវត្ថុជាតិ។ ការសម្រួលចរាចរណ៍ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចមានសារៈសំខាន់ណាស់ ដើម្បីឆ្លើយតបឲ្យបានកាន់តែប្រសើរនូវកំណើនតម្រូវការរូបិយវត្ថុជាតិ។ ដូច្នេះធនាគារជាតិនៃកម្ពុជាបាននឹងពង្រឹងនូវយន្តការបែងចែក និងផ្គត់ផ្គង់ប្រាក់រៀលស្របពេលតម្រូវការទីផ្សារ។ លើសពីនេះធនាគារជាតិនៃកម្ពុជានឹងស្វែងរកឱកាសក្នុងការក្នុងការលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការអភិវឌ្ឍន៍ឧបករណ៍គោលនយោបាយរូបិយវត្ថុ និងពង្រឹងយន្តការចម្លងឥទ្ធិពល នៃការអនុវត្តគោលនយោបាយរូបិយវត្ថុ។

ទន្ទឹមនឹងនេះ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់នៅតែជាគោលនយោបាយចាំបាច់ ដើម្បីពង្រឹងជំនឿទុកចិត្តមកលើប្រាក់រៀលសំដៅបង្កើនតម្រូវការរូបិយវត្ថុជាតិ។ ក្នុងរយៈពេលខ្លី និងមធ្យមការរក្សារបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រងមានសារៈសំខាន់ណាស់ ដើម្បីសម្រេចបានតាមគោលដៅនេះ។ ធនាគារជាតិនៃកម្ពុជានឹងអភិវឌ្ឍក្របខណ្ឌនិងយន្តការការដេញថ្លៃលក់និងទិញរូបិយប័ណ្ណដើម្បីបន្តពង្រឹងប្រសិទ្ធភាព និងកំណត់អត្រាប្តូរប្រាក់ឲ្យកាន់តែឆ្លុះបញ្ចាំងពីស្ថានភាពទីផ្សារ ។ នៅក្នុងរយៈពេលវែងអត្រាប្តូរប្រាក់នឹងអនុញ្ញាតឲ្យមានភាពបត់បែនកាន់តែច្រើនស្របតាមបម្រែបម្រួលស្ថានភាពសេដ្ឋកិច្ច និងធ្វើភ្នាក់ងារសេដ្ឋកិច្ចយល់ពីហានិភ័យ នៃការកាន់រូបិយវត្ថុអន្តរជាតិដោយសារការប្រែប្រួលអត្រាប្តូរប្រាក់។

### ៣.៣. ២ គោលនយោបាយសារពើពន្ធ

គោលនយោបាយសារពើពន្ធ ប្រៀបបានជាស្នូលនៃការជម្រុញការប្រើប្រាស់រូបិយវត្ថុរបស់ភ្នាក់ងារសេដ្ឋកិច្ចទាំងអស់ ដោយសារការទទួលស្គាល់និងប្រើប្រាស់រូបិយវត្ថុនៃប្រទេសមួយ គឺចាំបាច់ត្រូវមានការគាំទ្ររបស់រដ្ឋាភិបាល។ តាមរយៈចំណូលចំណាយរបស់ខ្លួនរដ្ឋាភិបាលនឹងបង្កើនចរន្តនៃលំហូររូបិយវត្ថុឲ្យកាន់តែសកម្ម ដែលក្នុងដំណាលគ្នានោះនឹងបង្កើនទាំងតម្រូវការនិងការផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ ដូច្នេះការកំណត់និងការទូទាត់ជារូបិយវត្ថុជាតិជារូបិយ

វត្ថុជាតិនៅក្នុងគ្រប់ប្រតិបត្តិការចំណូលចំណាយរបស់រដ្ឋ រាប់តាំងពីចំណាយឬចំណូលតូចតាច រហូតដល់ទំហំនៅក្នុងស្រុកលើគ្រប់ទិដ្ឋភាពមានសារៈសំខាន់ណាស់ ក្នុងការរួមចំណែកដោយផ្ទាល់ដល់ការលើកកម្ពស់ការគាំទ្រនិងប្រើប្រាស់រូបិយវត្ថុជាតិ។

រដ្ឋាភិបាលគួរផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយឱនភាពថវិកា តាមរយៈការធ្វើវិចារណកម្មចំណាយព្រមទាំងពង្រឹងមូលដ្ឋានពន្ធនិងបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ។ កម្រិតទាបនៃឱនភាពថវិកានឹងអនុញ្ញាតឲ្យរដ្ឋាភិបាលគ្រប់គ្រងបំណុលល្អប្រសើរ នឹងពង្រឹងជំនឿទុកចិត្តរបស់ភ្នាក់ងារសេដ្ឋកិច្ច មកលើស្ថាប័នសាធារណៈនិងរូបិយវត្ថុជាតិ។ ទន្ទឹមនេះរដ្ឋាភិបាលនឹងប្រមូលផ្តុំចំណូលថវិកាជាតិជារូបិយប័ណ្ណទៅក្នុងធនាគារជាតិនៃកម្ពុជា ដោយអនុវត្តក្រោមរូបភាពប្រាក់បញ្ញើឬលក់ជូនធនាគារជាតិនៃកម្ពុជា។ ការប្រមូលរូបិយប័ណ្ណចូលក្នុងធនាគារជាតិនៃកម្ពុជានឹងបង្កលក្ខណៈងាយស្រួលផងដែរដល់រដ្ឋាភិបាលក្នុងការគ្រប់គ្រង់ចំណូលជា រូបិយប័ណ្ណ និងធ្វើការប្តូរជារូបិយវត្ថុបានគ្រប់ពេលវេលាតាមសេចក្តីត្រូវការ។ ក្នុងករណីត្រូវការហិរញ្ញប្បទានថវិកាជាតិរដ្ឋាភិបាលនឹងនោះផ្សាយមូលបត្របំណុលរបស់រដ្ឋជារូបិយវត្ថុ និងជៀសវាងការបោះផ្សាយនូវរាល់ឧបករណ៍បំណុលជារូបិយប័ណ្ណ។

ម្យ៉ាងវិញទៀត ប្រទេសជាច្រើនដែលបានទទួលជោគជ័យក្នុងការបង្កើនតួនាទីរូបិយវត្ថុ បានខិតខំធានាថាបន្ទុកពន្ធជាក់ស្តែងនៅលើទ្រព្យសកម្មនឹងអកម្ម ដែលចារឹកជារូបិយវត្ថុក្នុងស្រុកមិខ្ពស់ជាងបន្ទុកពន្ធនៅលើទ្រព្យសកម្មនិងអកម្មដែលចារឹកជារូបិយប័ណ្ណឡើយ។ ក្នុងករណីខ្លះទៀត ឧបករណ៍ចារឹកជារូបិយប័ណ្ណត្រូវរងបន្ទុកពន្ធធ្ងន់ជាំងឧបករណ៍ចារឹកជារូបិយវត្ថុជាតិ។ ឧទាហរណ៍៖ ការដាក់ពន្ធលើប្រាក់ចំណូលឬចំណាយជាប្រាក់រៀល ដែលទទួលបានមកពីសកម្មភាពសេដ្ឋកិច្ចនានា ឬប្រាក់បញ្ញើជារៀលក្នុងប្រព័ន្ធធនាគារឬការផ្ទេរនានាជាប្រាក់រៀលជាដើម និងត្រូវលើកទឹកចិត្តតាមរយៈការដាក់កម្រិតអត្រាពន្ធពិតមួយដែលអំណោយផលដល់ រូបិយវត្ថុជាតិ។

### ៣.៣.៣.គោលនយោបាយពាណិជ្ជកម្ម

រូបិយវត្ថុគឺជាប្រេងរំអិលនៃសកម្មភាពពាណិជ្ជកម្ម ទន្ទឹមនេះ ការរីកចម្រើននៃសកម្មភាពពាណិជ្ជកម្មពាណិជ្ជកម្មក៏ជាកត្តាដែលបង្កើនតំរូវការរូបិយវត្ថុដែរ ។ ដូច្នេះការផ្សារភ្ជាប់គោលនយោបាយលើកម្ពស់ប្រាក់រៀល និងគោលនយោបាយពាណិជ្ជកម្មមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីរក្សានិរន្តរភាព នៃការប្រើប្រាស់ប្រាក់រៀលដោយភ្នាក់ងារសេដ្ឋកិច្ចក្នុងសកម្មភាពដោះដូររបស់ខ្លួន។

រដ្ឋាភិបាលគួរកាត់បន្ថយឱនភាពពាណិជ្ជកម្ម តាមរយៈការពង្រឹងការនាំចេញនិងកាត់បន្ថយ ការនាំចូល។ ការបង្កើនការនាំចេញនឹងត្រូវគ្រាំទ្រអោយបង្កើនការផលិតភាពនៃផលិតកម្ម និងពង្រីកទីផ្សារផលិតកម្មក្នុងស្រុក។ ការបង្កើនផលិតផលក្នុងស្រុកមិនត្រឹមតែនិងបង្កើនតម្រូវការរូបិយវត្ថុនៅក្នុងការដោះដូរផលិតផលទាំងនោះទេ តែថែមទាំងជួយដល់ការបន្ថយការនាំចូល ដូច្នេះបន្ថយតម្រូវការរូបិយបណ្ណ ។ កន្លងមករាជរដ្ឋាភិបាលបានខិតខំធ្វើពិធិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងជម្រុញការធ្វើពិធិកម្មការនាំចេញ ។ រាជរដ្ឋាភិបាលគួរបន្តអនុវត្តគោលនយោបាយនេះ និងជួយគាំទ្រការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ។ រដ្ឋាភិបាលក៏បានដាក់ចេញអោយអនុវត្តគោលនយោយអភិវឌ្ឍវិស័យឧស្សាកម្មដែលជំរុញឲ្យមានការរីកដុះដាលនៃសហគ្រាសធនតូច និងមធ្យម និងផលិតកម្មក្នុងស្រុក ដែលទាំងនេះនឹងរួមចំណែកកាត់បន្ថយឱនភាពជញ្ជីងពាណិជ្ជកម្មផងដែរ ។ លើសពីនេះ រដ្ឋាភិបាលគួរបន្តគាំទ្រដល់ការបង្កើនផលិតភាពលើផលិតកម្មនានា តាមរយៈការអភិវឌ្ឍន៍បច្ចេកទេស និងជំនាញនានាឲ្យកាន់តែប្រសើរឡើង ដើម្បីបង្កើនផលិតកម្មក្នុងស្រុក។

ទន្ទឹមនេះការជំរុញផលិតកម្មវិស័យកសិកម្ម ក៏នឹងរួមចំណែកដោយផ្ទាល់ដល់ការកាត់បន្ថយការនាំចូលទំនិញកសិកម្មពីបរទេស ជាំពិសេសប្រទេសជិតខាង និងបង្កើនតម្រូវការប្រាក់រៀល ដោយសារប្រាក់រៀលត្រូវប្រើប្រាស់លើសលុបនៅក្នុងវិស័យកសិកម្ម ។ ទាក់ទងនឹងវិស័យសេវាកម្ម កម្ពុជាមានឧត្តមភាពខ្ពស់ ដោយសារចំណូលដុលពិវិស័យសេវាកម្មមានអតិរេកដែលគាំទ្រដោយវិស័យទេសចរណ៍។ កន្លងមកការទទួលបានរូបិយប័ណ្ណពីទេសចរត្រូវបានប្រើប្រាស់បន្តដោយគ្មានការប្តូរប្រាក់ទៅជារូបិយវត្ថុជាតិទេ ។ ក្នុងបរិការណ៍នេះធនាគារជាតិនៃកម្ពុជាក៏ដូចជាអាជ្ញាធរពាក់ព័ន្ធ ក្រសួងទេសចរណ៍ និងអាជ្ញាធរមានសមត្ថកិច្ច គឺបង្កើនការប្រើប្រាស់ប្រាក់រៀលរបស់ទេសចរណ៍ និងស្រូបយករូបិយប័ណ្ណដែលទទួលបានទៅក្នុងប្រព័ន្ធ។

ចំពោះការដោះដូរក្នុងស្រុក ការកំណត់យករូបិយវត្ថុជាតិជាឯកតាកំណត់និងតាំងថ្លៃ និងជាមធ្យោបាយទូទាត់ និងបង្កើនការប្រើប្រាស់ប្រាក់រៀលដោយផ្ទាល់នៅក្នុងសេដ្ឋកិច្ច ហើយបន្ទាប់មកនឹងអាចមានឥទ្ធិពលវិជ្ជមានដល់ការប្រើប្រាស់ប្រាក់រៀលដោយផ្ទាល់ នៅក្នុងវិស័យហិរញ្ញវត្ថុថែមទៀតផង។

រដ្ឋាភិបាលគួរលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឲ្យកាន់តែមានភាពទូលំទូលាយ ជាឯកតាកំណត់និងដាក់តតាំងថ្លៃ។ ការជំរុញមុខងាររបស់ប្រាក់រៀលជាឯកតាកំណត់ និងដាក់ថ្លៃគួតត្រូវអនុវត្តនៅក្នុងផ្នែក ឬវិស័យជាក់លាក់មួយចំនួន បន្ទាប់មកអាចនឹងជម្រុញ ឬពង្រឹងបន្ថែមទៀតនៅក្នុងផ្នែក ឬវិស័យជាក់លាក់ដទៃទៀត។ យោងតាមទ្រឹស្តីនឹងបទពិសោធន៍អន្តរជាតិ វិធានការ

បែបនេះមានផលប៉ះពាល់តិចតួចបំផុតចំពោះទំនុកចិត្តរបស់សាធារណជន និងដំណើរការសេដ្ឋ-កិច្ច។ ជំហាននេះ ក៏ជាមូលដ្ឋានគ្រឹះដ៏សំខាន់ផងដែរចំពោះ ការលើកកម្ពស់តួនាទីប្រាក់រៀលជាមធ្យោបាយទូទាត់។ ប្រសិនបើមិនមានវឌ្ឍន៍ភាពសម្រាប់ការដាក់ឲ្យប្រើប្រាស់ប្រាក់រៀលសម្រាប់ការកំណត់ និងការដាក់តាំងថ្លៃទំនិញ និងសេវាឲ្យបានទូលំទូលាយទេនោះការលើកស្ទួយប្រាក់រៀលជាមធ្យបាយទូទាត់យ៉ាងទូលំទូលាយនឹងនៅមានកម្រិត។

ដើម្បីឲ្យការអនុវត្តមួយនេះប្រព្រឹត្តទៅដោយប្រសិទ្ធភាព អាជ្ញាធរចាំបាច់ត្រូវអនុញ្ញាតឲ្យមានរយៈ ពេលអន្តរកាលមួយ (ឧទាហរណ៍ ប្រមាណ ១ឆ្នាំ ឬ២ឆ្នាំ) សម្រាប់ត្រៀមលក្ខណៈផ្លាស់ប្តូរពីការកំណត់និងការដាក់តាំងថ្លៃប្រាក់ដុល្លាមកជាប្រាក់រៀលវិញ ។ ក្នុងអំឡុងពេលអន្តរកាលនេះ ផ្អែកលើការស្ម័គ្រចិត្តរបស់វិស័យឯកជន ថ្លៃទំនិញអាចបន្តដាក់តាំងជាប្រាក់ដុល្លាដែលនឹងជួយសម្រួលជាបណ្តើរៗ ចំពោះពាណិជ្ជករក្នុងការរៀបចំចាត់ចែងដាក់ថ្លៃថ្មីទៅលើទំនិញរបស់ពួកគេ។ បន្ទាប់ពីដំណាក់កាលនេះថ្លៃទាំងអស់ត្រូវឈប់បង្ហាញជារូបិយប័ណ្ណ ។ ក្នុងរយៈពេលខ្លីទៅមធ្យម ប្រាក់បៀវត្សរ៍ក៏ត្រូវចារឹកជាប្រាក់រៀលដែរ។ ប៉ុន្តែ ក្នុងអំឡុងពេលអន្តរកាលមួយដោយឡែក ប្រាក់បៀវត្សរ៍ក៏អាចត្រូវបានលើកលែងឲ្យបន្តកំណត់ប្រាក់ដុល្លា ដើម្បីឲ្យនិយោជកនិងធនាគារមានពេលវេលាសម្រាប់កែប្រែការចុះកិច្ចបញ្ជីក្នុងគណនេយ្យរបស់ខ្លួន។

រដ្ឋាភិបាលគួរលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឲ្យកាន់តែមានភាពទូលំទូលាយជាមធ្យោបាយទូទាត់ ។ នៅពេលដែលការកំណត់និងតាំងថ្លៃទំនិញ និងសេវាប្រាក់រៀលនៅក្នុងសកម្មភាពពាណិជ្ជកម្ម មិនមែនមានន័យជាស្វ័យប្រវត្តិថាការទូទាត់ត្រូវតែចាំបាច់ធ្វើឡើងជាប្រាក់រៀលទេ ។ កត្តាជាច្រើនដែលមានឥទ្ធិពលទៅលើជម្រើសមធ្យោបាយទូទាត់ អាចជាប្រភពចំណូល ភាពងាយស្រួល និងការចំនេញទទួលបានពីការទូទាត់ដូចដែលបានបង្ហាញដោយលទ្ធភាពស្រាវជ្រាវរបស់ AMRO និង JICA ។ នៅដំណាក់កាលដំបូង ការប្រើប្រាស់រៀលក្នុងការទូទាត់អាចត្រូវបានលើកទឹកចិត្តនិងពង្រឹង ហើយប្រសិនបើចាំបាច់អាចត្រូវដាក់ឲ្យអនុវត្តចំពោះប្រតិបត្តិការ ដែលទាក់ទងនឹងវិស័យសាធារណៈ និងចំពោះប្រតិបត្តិការដែលមានតម្លៃតូចៗនៅក្នុងវិស័យឯកជន ។ ដូចក្នុងការកំណត់និងតាំងថ្លៃទំនិញជារូបិយវត្ថុ វិធានការលើកកម្ពស់ការទូទាត់ជាប្រាក់រៀលនឹងត្រូវធ្វើជាបណ្តើៗ ស្របតាមការវិវត្តន៍នៃសភាពការណ៍ និងទុករយៈពេលអន្តរកាលមួយជូនភ្នាក់ងារសេដ្ឋកិច្ចដើម្បីអនុវត្ត។ ជារួមអំឡុងពេលអន្តរកាលអាចមានរយៈពេលខុសៗគ្នាអាស្រ័យទៅនឹងប្រភេទទំនិញ ឬសេវា ឬផ្នែក និងវិស័យដែលជាកម្មវត្ថុនៃវិធានការ និងជាពិសេសអាស្រ័យលើភាពងាយស្រួលទទួលយកបានពីសំណាក់មជ្ឈដ្ឋានពាក់ព័ន្ធផ្ទាល់។

### ៣.៣.៤. គោលនយោបាយហិរញ្ញវត្ថុនិងក្របខ័ណ្ឌបទបញ្ញត្តិប្រុងប្រយ័ត្ន

ដុល្លារូបនីយកម្មវិស័យហិរញ្ញវត្ថុ សំដៅលើស្ថានភាពដែលវិស័យឯកជនរក្សាទុករូបិយវត្ថុអន្តរជាតិក្នុងទម្រង់ជាសាច់ប្រាក់និងជាប្រាក់បញ្ញើ ក៏ដូចជាក្នុងករណីដែលស្ថាប័នហិរញ្ញវត្ថុរក្សាទុកទ្រព្យសកម្មនិងទ្រព្យអកម្មហិរញ្ញវត្ថុជារូបិយប័ណ្ណ ។ បទពិសោធអន្តរជាតិបានបង្ហាញថាការប្រើប្រាស់គោលនយោបាយរូបិយវត្ថុកាត់បន្ថយដុល្លារូបនីយកម្មនៅក្នុងវិស័យហិរញ្ញវត្ថុ ដូចជា ការបង្ខំឲ្យប្តូរប្រាក់បញ្ញើដែលជារូបិយប័ណ្ណទៅជារូបិយវត្ថុជាតិ ឬការហាមឃាត់ការដាក់ប្រាក់បញ្ញើជារូបិយប័ណ្ណ[11] នឹងការធ្វើអោយមានការហូរចេញទៅក្រៅ នៃមូលធន និងកាត់បន្ថយការហូរចូលនៃមូលធនបរទេសមកក្នុងសេដ្ឋកិច្ចជាតិ ដែលកត្តាទាំងនេះមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការវិនិយោគ និងកំណើនសេដ្ឋកិច្ច ។

ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ នៅក្នុងវិស័យហិរញ្ញវត្ថុពាក់ព័ន្ធនឹងពហុវិស័យដែលតម្រូវឲ្យមានគោលនយោបាយគាំទ្រដទៃទៀត ទាំងកម្រិតម៉ាក្រូនិងមីក្រូ និងការចូលរួមសកម្មពីសំណាក់ភាគីពាក់ព័ន្ធផ្សេងៗ។ ដូច្នេះ គោលនយោបាយចំពោះដុល្លារូបនីយកម្មវិស័យហិរញ្ញវត្ថុនឹងត្រូវបានពិចារណាដោយប្រុងប្រយ័ត្នបំផុតដើម្បីជៀសវាងផលវិបាក ដែលអាចបង្កភាពមិនល្អដល់ការរីកចម្រើនកន្លងមកក្នុងការប្រើប្រាស់ប្រាក់រៀល។

បច្ចុប្បន្ន វិស័យហិរញ្ញវត្ថុត្រូវបានគ្របដណ្តប់ដោយវិស័យធនាគារ ដែលមានទ្រព្យសកម្មប្រមាណលើសពី៩០% នៃទ្រព្យសកម្មវិស័យហិរញ្ញវត្ថុទាំងមូល។ ទន្ទឹមនឹងនេះ អន្តរការីយកម្មនៅក្នុងវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុប្រមាណជិត ៩០% ធ្វើឡើងជាប្រាក់ដុល្លា។ ទោះជាយ៉ាងណាក៏ការអនុវត្តគោលនយោបាយលើកកម្ពស់ការការប្រើប្រាក់រៀលកន្លងមក បានបង្កើតទាំងប្រាក់បញ្ញើ និងឥណទានជាប្រាក់រៀលជាលំដាប់ ប៉ុន្តែនៅមានកម្រិតទាបនៅឡើយ ក្នុងនោះវិស័យមីក្រូហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសកម្ម។ ទន្ទឹមនេះ ការបង្កើនបរិយាប័ន្នហិរញ្ញវត្ថុជាប្រាក់រៀលដោយការផ្តល់សេវាទាំងប្រាក់បញ្ញើឥណទាន និងការផ្ទេរប្រាក់ជារៀល អាចចូលរួមចំណែកយ៉ាងសំខាន់ដល់ការពង្រីកការប្រើប្រាស់ប្រាក់រៀលនៅគ្រប់មជ្ឈដ្ឋាន។

នៅចំពោះមុខស្ថានភាពខាងលើនេះ វិស័យធនាគារនិងហិរញ្ញវត្ថុនឹងបន្តបង្កើនភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុនិងអន្តរការីយកម្មហិរញ្ញវត្ថុជាប្រាក់រៀលបន្ថែមទៀត ដោយបង្កើតលក្ខណៈអំណោយផល នានាដល់ការប្រើប្រាស់ប្រាក់រៀលជាងរូបិយប័ណ្ណ។ ដូច្នេះ វិស័យធនាគារ និង

[11] ធនាគារកណ្តាលឡាវធ្លាប់បានដាក់ចេញប្រកាសស្តីពីការហាមដកប្រាក់បញ្ញើជារូបិយប័ណ្ណ ហើយថ្ងៃបន្ទាប់មកបានដាក់ចេញវិញដោយឥទ្ធិពលនៃការធ្លាក់ចុះជាគំហុក នៃប្រាក់បញ្ញើ

ហិរញ្ញវត្ថុគួរត្រូវបានលើកទឹកចិត្តនិងជម្រុញឲ្យផ្តល់សេវាហិរញ្ញវត្ថុនានា (ដូចជា សេវាឥណទានប្រាក់បញ្ញើ និងការផ្ទេរប្រាក់ ជាដើម) ជាប្រាក់រៀល។ ទន្ទឹមនឹងនេះ អាជ្ញាធរគួរមានគោលនយោបាយលើកទឹកចិត្តសាធារណជន ដើម្បីឲ្យការប្រើប្រាស់សេវាទាំងនេះមានភាពទាក់ទាញជាងប្រាក់ដុល្លារជាដើម។ ក្នុងទិសដៅនេះ ការសិក្សាពីលទ្ធភាពបង្កើតប្រព័ន្ធធានារ៉ាប់រងលើប្រាក់បញ្ញើជារៀលនឹងក្លាយជាវិធានគាំទ្រដ៏សំខាន់មួយ។

ទន្ទឹមនេះ ក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្នក្នុងវិស័យហិរញ្ញវត្ថុនឹងត្រូវពង្រឹងដើម្បីបន្តរក្សាស្ថិរភាពហិរញ្ញវត្ថុឲ្យបានល្អប្រសើរ។ បទប្បញ្ញត្តិប្រុងប្រយ័ត្នទាំងនេះនឹងត្រូវបញ្ជ្រាបស្មារតីនៃការប្រើប្រាស់ប្រាក់រៀល ដូចជាការកំនត់លក្ខខណ្ឌខុសគ្នារវាងរូបិយវត្ថុនិងរូបិយប័ណ្ណទៅលើអនុបាតសន្ទនីយភាពអត្រាប្រាក់បម្រុងកាតព្វកិច្ច និងស្ថានភាពចំហសុទ្ធ (Net open position) ជាដើម។ ការធ្វើឲ្យមានភាពខុសគ្នានឹងត្រូវសិក្សាយ៉ាងល្អិតល្អន់ ដើម្បីឲ្យការដាក់អនុវត្តវិធានប្រុងប្រយ័ត្នមានលក្ខណៈទទួលយកបានស្របតាមស្ថានភាពជាក់ស្តែង។

ម្យ៉ាងវិញទៀត ការបង្កើនទំនាក់ទំនងប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ និងរវាងគ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់ នឹងមានការចាំបាច់ដើម្បីឲ្យគ្រឹះស្ថានទាំងនេះអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុរវាងគ្នា ដើម្បីបង្កើតទីផ្សារក៏ដូចជាបំពេញសេចក្តីត្រូវការរបស់ប្រាក់រៀលក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ចដែលប្រើប្រាស់រូបិយប័ណ្ណក្នុងសេដ្ឋកិច្ច។

### ៣.៣.៥. គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ

កន្លងមកទីផ្សារហិរញ្ញវត្ថុដែលគាំទ្រ ការប្រើប្រាស់រូបិយវត្ថុជាតិស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ ។ ទីផ្សារទាំងនេះ និងបង្កើតបរិយាកាសអំណោយផលដល់ការប្រើប្រាស់ប្រាក់រៀល និងផ្តល់ភាពងាយស្រួល ដល់គំនិតផ្តួចផ្តើមដទៃទៀតក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល ។ ទីផ្សារសំខាន់ៗដែលត្រូវអភិវឌ្ឍរួមមានដូចជា ៖ ទីផ្សារប្តូរប្រាក់ ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុ និងទីផ្សារមូលបត្រ ។

- **ការអភិវឌ្ឍន៍ទីផ្សារប្តូរប្រាក់** ៖ ទីផ្សារប្តូរប្រាក់ ជាសសរទ្រូងមួយដ៏សំខាន់ក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដែលមានតួនាទីយ៉ាងសកម្មក្នុងការជួយសម្រួលដល់ ការប្រើប្រាស់ប្រាក់រៀល។ ទីផ្សារប្តូរប្រាក់ នៅកម្ពុជានាពេលបច្ចុប្បន្ន មានលក្ខណៈជាទីផ្សាររាយដែលមានអាជីវកម្មប្តូរប្រាក់ដើរតួនាទីដ៏សំខាន់ ហើយប្រតិបត្តិទូទាត់នៅពឹងផ្អែកលើការប្រើប្រាស់សាច់ប្រាក់ជាជាងការបង្វែសាច់ប្រាក់ តាមប្រព័ន្ធធនាគារដែលធ្វើឱ្យទីផ្សារនេះមានភាព មិនទាន់ស៊ីជម្រៅនៅឡើយ ។ កន្លងមក ទីផ្សារនេះបានគាំទ្រការប្រើប្រាស់រូបិយប័ណ្ណអន្តរជាតិ របស់

ភ្នាក់ងារសេដ្ឋកិច្ច ដោយសារវត្តមានស្ទើរគ្រប់ ទីកន្លែងនៃអាជីវករប្តូរប្រាក់ការរីកចម្រើននៃបណ្តាញភ្នាក់ងារប្តូរប្រាក់ក្រៅផ្លូវការ នៅក្នុងតំបន់ និង ថ្នាក់ជាតិ និងការផ្តល់នូវអត្រាប្តូរប្រាក់ក្នុងកម្រិតអំណោយផល ដល់អ្នកប្រើប្រាស់រូបិយប័ននណ្ណ (បច្ចុប្បន្ន គម្លាតអត្រាប្តូរប្រាក់នៅកម្ពុជាមានកម្រិតទាប បើធៀបនឹងប្រទេសដទៃទៀត ហើយមិន ទាន់មានការដាក់ពន្ធលើការប្តូរប្រាក់ទេ) ។ ការអភិវឌ្ឍទីផ្សារប្តូរប្រាក់បន្ថែមទៀតឱ្យក្លាយជាទីផ្សារលក់ ដុំ និងមានគ្រឹះស្ថានធនាគារជាអ្នកដើរតួនាទីស្នូលក្នុងប្រតិបត្តិការប្តូរប្រាក់មានសារៈសំខាន់ ណាស់ ដើម្បីប្រមូលរូបិយប័ណ្ណអន្តរជាតិឱ្យចូលទៅក្នុងវិស័យធនាគារ និងឆ្លើយតបទៅនឹងតម្រូវ ការប្រាក់រៀលនៅក្នុងទីផ្សារឱ្យកាន់តែប្រសើរឡើង ។ ក្នុងទិសដៅនេះ អាជ្ញាធ័រគួរបង្កើនការត្រួត ពិនិត្យ ពង្រឹងក្របខណ្ឌបទប្បញ្ញត្តិ និងសមត្ថភាពស្ថាប័ន ដើម្បីឱ្យទីផ្សារប្តូរប្រាក់ឱ្យកាន់តែប្រសិទ្ធភាពខ្ពស់ និងមានការគ្រប់គ្រងដែលអំណោយផលដល់ការគៀងគររូបិយវត្ថុអន្តរជាតិចូលក្នុងប្រព័ន្ធធនាគារ និងផ្គត់ផ្គង់ប្រាក់រៀលឱ្យបានកាន់តែច្រើននៅក្នុងសេដ្ឋកិច្ច

- **ទីផ្សាររូបិយវត្ថុធនាគារនិងរូបិយវត្ថុ ៖** បច្ចុប្បន្ន ទីផ្សារអន្តរជាតិធនាគារ និងរូបិយវត្ថុ កំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ។ ធនាគាធំៗខ្លះបានបង្កើតទំនាក់ទំនងតាមរយៈការផ្តល់ឥណទាននិងការដាក់ប្រាក់បញ្ញើ ប៉ុន្តែទំនាក់ទំនងតាមរយៈការផ្តល់ឥណទាន និងការដាក់ប្រាក់បញ្ញើ ពុំមានលក្ខណៈសកម្មនៅឡើយទេ ។ កន្លងមកធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍទីផ្សារនេះតាមរយៈការបង្កើតមូលបត្រអាចជួញដូរ បាន ការដាក់ឱ្យដំណើរការ ជាពិសេសសម្រាប់មូលបត្រអាចជួញដូរបានជារូបិយវត្ថុជាតិ ។
- **ទីផ្សារមូលបត្រ ៖** ទីផ្សារមូលបត្រត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១២កន្លងទៅ ហើយមូលបត្រសាជីវកម្មចំនួន ២ កំពុងត្រូវបានជួញដូរ ។ ថ្វីបើការជួញដូរនៅមានកម្រិតទាបនៅឡើយ ការបង្កើតទីផ្សារមូលបត្រគឺជាមូលដ្ឋានដ៏មានសារៈសំខាន់ ក្នុងការអភិវឌ្ឍឧបករណ៍ហិរញ្ញវត្ថុនានា ជាប្រាក់រៀល ។ ការកំណត់តម្លៃមូលបត្រជាប្រាក់រៀ បានបង្ហាញពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការអភិវឌ្ឍទីផ្សារមូលបត្រជាប្រាក់រៀល។

### ៣.៣.៦. ការអភិវឌ្ឍន៍ប្រព័ន្ធទូទាត់

ប្រព័ន្ធទូទាត់ជាផ្នែកស្នូលនៃហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។ ការអភិវឌ្ឍប្រព័ន្ធនេះនឹងជួយសម្រួលដល់ប្រតិបត្តិការទូទាត់ឲ្យមានភាពងាយស្រួល សុវត្ថិភាពឆាប់រហ័ស និងចំណាយតិច ។

បច្ចុប្បន្នការទូទាត់ភាគច្រើនត្រូវបានធ្វើឡើងជាប្រាក់ដុល្លារទាំងក្នុងប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុទាំងក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។ គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ នឹងត្រូវអនុវត្តដោយប្រុងប្រយ័ត្នផ្អែកលើមូលដ្ឋានអាទិភាពនៃការជំរុញកំណើនសេដ្ឋកិច្ច និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ កន្លងមកធនាគារជាតិនៃកម្ពុជាបានបង្កើតប្រាក់ប្រព័ន្ធសម្រាប់សេវាទូទាត់ឆាប់រហ័ស ដើម្បីសម្រួលដល់ការទូទាត់ជាប្រាក់រៀលជាមួយតម្លៃទាបសមរម្យឆាប់រហ័ស និងប្រសិទ្ធភាព។ ការសៀតបញ្ចូលវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាលំដាប់ស្របតាមតម្រូវការទីផ្សារ គឺជាការចាំបាច់បំផុត ។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាគួរបន្តលើកកម្ពស់ការត្រួយពិនិត្យ ក្របខណ្ឌច្បាប់ សមត្ថភាពគ្រប់គ្រងរបស់ស្ថាប័ន ដែលអំណោយផលដល់ដំណើរការទូទាត់ជាប្រាក់រៀល និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជតិនៃកម្ពុជាគួរបង្កើតប្រសិទ្ធភាព និងបន្ទាបចំណាយលើការទូទាត់ជាប្រាក់រៀល ដែលធ្វើឲ្យការទូទាត់ជាប្រាក់រៀលមានភាពទាក់ទាញជាងរូបិយប័ណ្ណ។ អាជ្ញាធរនឹងពង្រឹងគោលនយោបាយក្នុងការទូទាត់ដោយមិនប្រើសាច់ប្រាក់ ដែលនឹងជួយគ្រប់គ្រងចរាចរណ៍រូបិយវត្ថុអន្តរជាតិ និងលើកទឹកចិត្តឲ្យធ្វើការទូទាត់ជារូបិយវត្ថុជាតិ ។ ក្នុងស្មារតីនេះ ធនាគារជាតិនៃកម្ពុជាគួរបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ដោយធ្វើការអភិវឌ្ឍប្រព័ន្ធទូទាត់រាល់អេឡិត្រូនិចជាប្រាក់រៀល ដែលអំណោយផលដល់ប្រតិបត្តិការទូទាត់ឲ្យកាន់តែទូលំទូលាយជាងមុន។

ម្យ៉ាងវិញទៀតសេវា និងឧបករណ៍ទូទាត់ជាប្រាក់រៀលក្នុងទម្រង់ជាមូលប្បទានបត្រអេឡិចត្រូនិច និងទម្រង់ផ្សេងៗគួរត្រូវអភិវឌ្ឍឲ្យកាន់តែសម្បូរបែប ដើម្បីអាចឆ្លើយតបនឹងតម្រូវការរបស់ទីផ្សារ ក្នុងពេលដែលតម្រូវការប្រាក់រៀលសម្រាប់ប្រើប្រាស់ជាមធ្យោបាយទូទាត់កាន់តែច្រើននោះឡើង។ លើសពីនេះ បន្ទាប់ពីអំឡុងពេលមួយដែលប្រាក់រៀលត្រូវបានទទួលស្គាល់កាន់តែខ្លាំងជា ឯកតាកំណត់ និងតាំងថ្លៃ ក្រដាសប្រាក់រៀលពេលមួយដែលមានតម្លៃចារឹកខ្ពស់នឹងចាំបាច់ត្រូវការ ដើម្បីជួយសម្រួលដល់ប្រតិបត្តិការដែលមានតម្លៃធំៗនៅក្នុងវិស័យពាណិជ្ជកម្ម និងហិរញ្ញវត្ថុ។ បច្ចុប្បន្ន ក្រដាសប្រាក់រៀលចារឹកតម្លៃខ្ពស់បំផុតគឺ១០០.០០០រៀលស្មើនឹងប្រមាណ២៥$អាមេរិក ។ ក្រដាសប្រាក់រៀលដែលចារឹកក្នុងតម្លៃខ្ពស់ត្រូវបានពិចារណាបោះផ្សាយនៅពេលដែលសេដ្ឋកិច្ចមាន ការរីកចម្រើនគ្រប់គ្រាន់ក្នុងទិដ្ឋភាពនៃការបង្កើនការប្រើប្រាស់រូបិយវត្ថុជាតិ។

នៅរយៈពេលវែង ធនាគារជាតិនៃកម្ពុជាគួរពិចារណាលើការតម្រូវឲ្យមានការទូទាត់តាមរយៈប្រព័ន្ធធនាគារជាតិ ចំពោះទឹកប្រាក់ធំចាប់ពីកម្រិតសមស្របណាមួយ ដើម្បីកាត់បន្ថយការ

ទូទាត់ជាសាច់ប្រាក់ និងបង្កើនការទាក់ទាញក្នុងការទូទាត់ធំជាប្រាក់រៀល។ គួរត្រូវធ្វើឡើងដើម្បីវិភាគពីគុណសម្បត្តិនិងគុណវិបត្តិនៃការធ្វើកំណែទម្រង់ដល់ការពង្រីកការប្រើប្រាស់ប្រាក់រៀល។

### ៣.៣.៧. ការលើកម្ពស់ការយល់ដឹង និងការចូលរួម

សាធារណៈជន គឺជាមូលដ្ឋានគន្លឹះនៃយុទ្ធសាស្ត្រលើកកម្ពស់ប្រាក់រៀលដោយសារនយោបាយនេះអាចមានឥទ្ធិពលដល់ផលប្រយោជន៍សេដ្ឋកិច្ច ព្រមទាំងទម្លាប់នៃការរស់នៅរបស់ពួកគេ ។ សាធារណជនប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ សម្រាប់ការទិញទំនិញនិងសេវា ការសន្សំ និងការវិនិយោគ ជាដើម។ យោងតាមការសិក្សាកន្លងមកបង្ហាះថា ការប្រើប្រាស់ប្រាក់ដុល្លារបានចាក់ឫសគល់យ៉ាងជ្រៅក្នុងផ្នត់គំនិតរបស់ឲប្រជាជន ហើយការប្រើប្រាស់នឹងការគិតចំនួនទឹកប្រាក់នានាជាប្រាក់ដុល្លារសម្រាប់ប្រជាជនមួយចំនួនបានក្លាយជាទម្លាប់ទៅហើយ។ អាស្រ័យហេតុនេះ ការសម្រចនូវគោលនយោបាយលើកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិមិនអាចធ្វើឡើងដោយអត្តនោម័ត និងដោយគ្មានការចូលរួមពីសំណាក់សាធារណជនឡើយ។ ក្នុងទិសដៅនេះ សាធារណជនចាំបាច់ ត្រូវយល់ដឹងឲ្យកាន់តែច្បាស់ពីអត្ថប្រយោជន៍រូបិយជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងរួមចំណែកក្នុងការដំណើរការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុ។

### ៣.៣.៨. កិច្ចការសហប្រតិបត្តិការដើម្បីអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាព

ការតាមដាននិងការធនាការអនុវត្តដ៏ត្រឹមត្រូវ និងដោយហ្មត់ចត់នូវវិធានការដែលបានដាក់ចេញមានសារៈសំខាន់ណាស់ ជាពិសេស ចំពោះការសម្រេចជោគជ័យនៅលើផែនការដែលបានគ្រោងទុក។ លើសពីនេះ កាលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាការងារងារពាក់ព័ន្ធនឹងផលប្រយោជន៍ជាតិនិងមោទនជាតិ ដែលទាមទារជាចាំបាច់នូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការរៀបចំគោលនយោបាយឬវិធានាការឲ្យមានប្រសិទ្ធភាព។

ដើម្បីសម្របសម្រួលវិធានការនិងសកម្មភាពទាំងឡាយ រវាងគ្រប់វិស័យពាក់ព័ន្ធផ្សេងៗក្នុងការសម្រេចគោលដៅនយោបាយរួមនេះចាំបាច់ត្រូវ បង្កើតក្របខណ្ឌសម្រាប់សម្រួលកិច្ចសហ-ប្រតិបត្តិការរវាងភាគីពាក់ព័ន្ធទាំងឡាយ ។ ការសម្របសម្រួលនេះគប្បីធ្វើឡើងទាំងក្នុងកម្រិតនៃការរៀបចំ និងកំណត់គោលនយោបាយ ទាំងក្នុងដំណើរការអនុវត្តគោលនយោបាយទាំងនោះផងដែរ។

ទន្ទឹមនេះ ក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការតាមដានជាប្រចាំនូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ និងវិធានការដែលបានដាក់ចេញ។ អាជ្ញាធរពាក់ព័ន្ធសំខាន់ៗក្នុង

ការអនុវត្តយុទ្ធសាស្ត្រនេះ រួមមាន៖ ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងមហាផ្ទៃ ក្រសួងពត៌មាន ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជនពាក់ព័ន្ធនានា។ នៅកម្រិតនយោបាយ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាឆ័ត្រទទួលខុសត្រូវ និងផ្តល់ការណែនាំគោលនយោបាយ ព្រមទាំងការសម្របសម្រួលចាំបាច់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។ នៅកម្រិតបច្ចេកទេស ក្រុមការងារអន្តរក្រសួងមួយគួរត្រូវបានបង្កើតឡើងសម្រាប់ជម្រុញនិងតាមដានការអនុវត្តវិធានការដែលបានដាក់ចេញ ព្រមទាំងលើកសំណើរដើម្បីពង្រឹង កែលម្អ ឬដាក់ចេញវិធានការចាំបាច់បន្ថែមទៀត។

### ៣.៣.៩. គោលនយោបាយគាំទ្រនានា

គោលនយោបាយគាំទ្រនានា គួរត្រូវអនុវត្តដើម្បីរក្សានិរន្តរភាពនៃការលើកកម្ពស់ប្រាក់រៀល ។ ជាក់ស្តែងប្រទេសមួយចំនួន ដែលខ្វះខាតនូវគោលនយោបាយគាំទ្រទាំងនេះ បានជួបប្រទះនូវការកើនឡើងវិញនូវកម្រិតដុល្លារូបនីយកម្ម បន្ទាប់ពីបានកាត់បន្ថយដុល្លារូបនីយកម្ម បានមួយរយៈពេល ។

គោលនយោបាយគាំទ្រទាំងនេះ អាចគ្របដណ្តប់ទៅលើការងារជាច្រើន ៖

- អាជ្ញាធរគួរ បញ្ជ្រាបស្មារតីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងរាល់ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដូចជាការប្រើប្រាស់ឯកតារៀលសម្រាប់កំណត់បៀវត្សអប្បបរមាជាដើម
- ការកំនត់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម និងការប្រឆាំងអំពើពុក រលួយ និងរួមចំណែកដោយប្រយោលដល់ការពង្រឹងការប្រើប្រាស់រូបិយវត្ថុជាតិ ដោយសារ សកម្មភាពទាំងនេះ អាចជាបរិយាកាសអំណោយផលដល់ការប្រើប្រាស់រូបិយប័ណ្ណជាតិ និងរូបិយប័ណ្ណអន្តរជាតិ ។
- ប្រែក្លាយពីវិស័យក្រៅផ្លូវការ ទៅជាវិស័យផ្លូវការជាលំដាប់ដូចជា ការចុះបញ្ជីក្រុមហ៊ុន និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាដើម ដើម្បីឱ្យសកម្មភាពសេដ្ឋកិច្ចទាំងនេះអាច ទទួលផលជាច្រើនពីការប្រើប្រាស់ប្រាក់រៀល ក៏ដូចជាជម្រុញតម្រូវការប្រាក់រៀលដូចជាការទទួលបានឥណទានជាប្រាក់រៀល ក្នុងអត្រាសមរម្យ និងការប្រើប្រាសសេវាទូទាត់ ជាប្រាក់រៀលជាដើម ។

- វិនិយោគិននានាត្រូវបានលើកទឹកចិត្តឱ្យធ្វើប្រតិបត្តិការរបស់ខ្លួនជាប្រាក់រៀល ជាលំដាប់ ក្នុងអំឡុងពេលបាននិងកំពុងដំណើរការអាជីវកម្មរបស់ខ្លួន និងជាពិសេសនៅមុនពេល ចាប់ផ្តើមធ្វើប្រតិបត្តិការអាជីវកម្ម ។ ក្នុងរយៈពេលមធ្យម និងវែង ការសិក្សាលើការដាក់កំហិតលើការកាន់រូបិយប័ណ្ណនៅក្នុងប្រតិបត្តិការ ដោយភ្នាក់ងារដែលមិនមានប្រតិបត្តិការជាមួយភ្នាក់ងារនៅក្រៅប្រទេសនឹងត្រូវចាប់ផ្តើម។ ការអនុវត្តវិធានការនេះ ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នបំផុត ជាពិសេស ធានាឲ្យបានថាវិធានការនេះនឹងមិនប៉ះពាល់ដល់លំហូរចេញនៃមូលធនទេ។
- លើកទឹកចិត្តឲ្យគ្រឹះស្ថានធនាគារ និងក្រុមហ៊ុននានាក្នុងការផ្តល់ជាប្រាក់រៀលជូននិយោជិត។ ការងារនេះអាចទាមទារឲ្យមានកិច្ចសហការរបស់រដ្ឋាភិបាល ក៏ដូចជាធនាគារជាតិនៃកម្ពុជា ដើម្បីនិយោជិកអាចប្រើប្រាស់សេវាធនាគារក្នុងប្រតិបត្តិការសេដ្ឋកិច្ចនានា និងបន្ថយការកាន់សាច់ប្រាក់ ដែលបច្ចុប្បន្នអាចមានចំនួនច្រើនចំពោះការទូទាត់ប្រាក់ធំៗ។

## ៣.៤ វិធានការលើកកម្ពស់ប្រាក់រៀល

ដើម្បីសម្រេចគោលបំណងនៃ ការពង្រឹងប្រាក់រៀលក្នុងរយៈកាលដ៏វែងរបស់រាជរដ្ឋាភិបាលបានធ្វើបដិដុល្លារូបនីយកម្ម ហើយរាជរដ្ឋាភិបាលនិងស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់នូវយុទ្ធសាស្ត្រមួយចំនួនជាបន្តបន្ទាប់ សំដៅបង្កើនការប្រើប្រាស់ប្រាល់រៀល និងពង្រឹងជំនឿទុកចិត្តទៅលើរូបិយវត្ថុជាតិ។ ជាក់ស្តែង រាជរដ្ឋាភិបាលមានវិធានការដូចតទៅ៖

### ៣.៤.១. វិធានការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ការកំណត់និងទូទាត់ប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការជាប្រាក់រៀល ត្រូវបានបន្តអនុវត្តរហូតបន្ទាប់ពីបានដាក់ឲ្យប្រើប្រាស់ជាថ្មីនូវរូបិយវត្ថុជាតិ។

- ចាប់តាំងពីឆ្នាំ ២០០០ មក ការបង់ថ្លៃទឹក ភ្លើង ត្រូវទូទាត់ជាប្រាក់រៀល។
- នៅឆ្នាំ ២០០០ គ្រប់អាជីវកម្មទាំងអស់ត្រូវបានតម្រូវឲ្យបង់ពន្ធដារនៅធនាគារជាតិនៃកម្ពុជា ហើយវិធានការនេះក៏ត្រូវបានអនុវត្តផងដែរចាប់តាំងពីឆ្នាំ ២០០៥ មកចំពោះការបង់ពន្ធដារគយ។ ក្នុងអំឡុងពេលឆ្នាំ ២០០៦-២០១១ ការបង់ពន្ធតាមរយៈធនាគារជាតិនៃកម្ពុជាជាមធ្យមប្រចាំឆ្នាំមានចំនួនប្រមាណ ២.៣០៧ពាន់លានរៀល។ នៅឆ្នាំ២០១១ការបង់ពន្ធតាមរយៈធនាគារជាតិនៃកម្ពុជាមានសមាមាត្រ

ប្រមាណ ៦៥% នៃចំណូលពន្ធមានអំណោយផលល្អដល់ការបង្កើនទុនបម្រុង និងស្ថិរភាពអត្រាប្តូរប្រាក់។

- ចាប់តាំងពីឆ្នាំ២០០៥មក ការបើកប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការជាសាច់ប្រាក់ត្រូវបានជំនួសដោយការប្រើប្រាស់គណនីធនាគារវិញ ដែលបាចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ក្នុងចរាចរណ៍ និងលើកកម្ពស់អន្តរការិយកម្មធនាគារជាប្រាក់រៀល។
- ការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានតម្រូវឲ្យគណនីទាំងអស់របស់រដ្ឋាភិបាលប្រមូលផ្តុំនៅក្នុងធនាគារជាតិនៃកម្ពុជា ហើយចំណែកដ៏ធំនៃមូលនិធិទាំងនេះត្រូវបានប្តូរជាប្រាក់រៀលស្របតាមច្បាប់កំណត់។

### ៣.៤.២. វិធានការរបស់ក្រសួងពាណិជ្ជកម្ម

- ចាប់តាំងពីឆ្នាំ២០១៣មក ក្រសួងពាណិជ្ជកម្មបានចេញការណែនាំចំពោះអាជីវករទាំងឡាយឲ្យកំណត់ថ្លៃទំនិញ និងសេវារបស់ខ្លួនជាប្រាក់រៀល។

### ៣.៤.៣. វិធានការធនាគារជាតិ នៃ កម្ពុជា

- ធនាគារជាតិនៃកម្ពុជា បានខិតខំជំរុញការប្រើប្រាស់ប្រាក់រៀលតាមវិធីផ្សេងៗរួមមាន ការពង្រឹងគុណភាពនិងសោភណ្ឌភាពក្រដាស់ប្រាក់រៀល តាមរយៈការប្តូរជំនួសក្រដាស់ប្រាក់ចាស់ ទក់ និងរហែក ដោយក្រដាស់ប្រាក់ថ្មី ដែលទង្វើនេះបានសម្រួលដល់ប្រជាជនក្នុងការប្រើប្រាស់ទូទាត់ប្រចាំថ្ងៃ ក៏ដូចជាលើកទឹកចិត្តដល់ការរក្សារទុកប្រាក់រៀលជាឧបករណ៍សញ្ជ័យ។
- ការបំពេញកាតព្វកិច្ចទទួលការបង់ពន្ធដារ និងពន្ធគយដោយផ្ទាល់ជូនរដ្ឋាភិបាលបានបង្កលក្ខណៈល្អមួយផ្នែកដល់ធនាគារជាតិនៃកម្ពុជា ក្នុងការប្រមូល និងការដកក្រដាស់ប្រាស់ចាស់ចេញពីចរាចរណ៍។
- នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ ខែមីនា ឆ្នាំ ២០១០ ធនាគាជាតិនៃកម្ពុជាបានប្រារព្ធរៀបចំខួបលើកទី៣០ នៃការដាក់ឲ្យប្រើប្រាស់ប្រាក់រៀលឡើយវិញនូវប្រាក់រៀល សំដៅជំរុញការយកចិត្តទុកដាក់ និងទំនុកចិត្តរបស់សាធារណជនលើរូបិយវត្ថុនីត្យានុកូលរបស់ជាតិ។

- ដើម្បីសម្រួលនិងបង្កើនការទូទាត់ប្រតិបត្តិការធំៗ ជារូបិយវត្ថុជាតិ ក្រដាសប្រាក់ចារឹកតម្លៃខ្ពស់រហូតដល់ ១០០.០០០រៀល (ប្រមាណ ២៥ ដុល្លាអាមេរិក) ត្រូវបានចេញផ្សាយ និងដាក់ឲ្យប្រើប្រាស់ក្នុងចរាចរណ៍។
- ធនាគារជាតិនៃកម្ពុជា បានខិតខំគ្រប់គ្រងសាច់ប្រាក់ងាយស្រួលតាមរយៈការកំណត់គោលដៅរូបិយវត្ថុ និងតាមដានយ៉ាងល្អិតល្អន់នូវសូចនាកររូបិយវត្ថុសំខាន់ៗនានាដូចជា ការគ្រប់គ្រងបរិមាណសាច់ប្រាក់រៀលនៅក្រៅប្រព័ន្ធធនាគារ បម្រែបម្រួលទ្រព្យសកម្មក្នុងស្រុកសុទ្ធ កំណើនឥណទានចំពោះវិស័យឯកជនជាដើម។
- ធនាគារជាតិនៃកម្ពុជា បានចាត់វិធានការប្រមូលប្រភេទក្រដាស់ប្រាក់ដុល្លារមានតម្លៃចារឹក តូចៗ ដូចជាក្រដាសប្រាក់ ១ និង ៥ដុល្លារ ចេញពីទីផ្សារក្នុងទិសដៅកាត់បន្ថយការចាយក្រដាសប្រាក់ដុល្លារប្រភេទតូចៗ ហើយដូចនេះជំរុញឲ្យប្រជា-ពលរដ្ឋប្រើប្រាស់ប្រាក់រៀលជំនួសវិញ។
- ធនាគារជាតតិនៃកម្ពុជា បាននឹងកំពុងជំរុញឲ្យបណ្តាធនាគារពាណិជ្ជ តម្លើងបរិ-ធានដកសាច់ប្រាក់សស្វ័យប្រវត្តិ (ATM) ដែលបានចែកចាយធនប័ត្រជាប្រាក់រៀលនិងជំរុញឲ្យមានប័ណ្ណឥណទានជាប្រាក់រៀល។
- ធនាគារជាតិនៃកម្ពុជា តែងធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់បន្តបន្ទាប់តាមការចាំបាច់ ក្នុងគោលដៅរក្សាស្ថេរភាពអត្រាប្តូរប្រាក់ ព្រមទាំងពង្រឹងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ។
- ធនាគារជាតិនៃកម្ពុជា បានកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងកម្រិតផ្សេងៗគ្នាក្នុងទិសដៅទ្រទ្រង់ការប្រើប្រាស់ប្រាក់រៀល។ នៅខែមេសា ឆ្នាំ២០០៨ អត្រាប្រាក់បម្រុងកាតព្វកិច្ចសម្រាប់បញ្ញើជារូបិយប័ណ្ណត្រូវបានតម្លើងពី ៨% ទៅ ១៦% និងបានបន្ថយមកវិញត្រឹម ១២% នាខែមករា ឆ្នាំ២០០៩ ខណៈដែលអត្រាប្រាក់បម្រុងកាតព្វ សម្រាប់ប្រាក់បញ្ញើជារៀលត្រូវបានរក្សាស្មើនឹង ៨%ដោយពុំមានប៉ះពាល់។
- ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឲ្យមានតូបប្តូរប្រាក់នៅតាមតំបន់ទេសចរណ៍ទីប្រជុំជនធំៗ និងមជ្ឈមណ្ឌលពាណិជ្ជកម្មនានា ដើម្បីងាយស្រួលក្នុងការដូរប្រាក់និងជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ។

- ក្នុងគោលបំណងពង្រីកសេវាធនាគារ និងពង្រឹងការប្រើប្រាស់ប្រាក់រៀលនៅតំបន់ជនបទ ធនាគារជាតិនៃកម្ពុជា បានផ្តល់ឥណទានជាប្រាក់រៀលចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយមានប្រាក់បញ្ញើមានកាលកំណត់ជារូបិយប័ណ្ណតម្កល់។
- លើសពីនេះ ការខិតខំត្រូវបានឡើងជាប្រចាំសំដៅពង្រឹងទំនុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ តាមរយៈការពង្រឹងសុខុមាលភាពរបស់គ្រឹះស្ថានធនាគារ ដោយលើកកម្ពស់ការត្រួតពិនិត្យ និងប្បញ្ញត្តិកម្ម។

# ជំពូកទី៤

# ការពិភាក្សា

## ៤.១. លទ្ធផលនៃវិធានការពង្រឹងការប្រើប្រាស់ប្រាក់រៀល[12]

ក្រោយការបោះឆ្នោតសកលលើកទី២ នាឆ្នាំ១៩៩៨ ស្ថិរភាពនយោបាយក្នុងប្រទេសកម្ពុជាកាន់តែមានភាពប្រសើរឡើង ហើយផ្អែកលើបុរេលក្ខខណ្ឌដ៏ល្អប្រសើរនេះស្ថាពភាពម៉ាក្រូសេដ្ឋកិច្ចក៏ត្រូវបានពង្រឹងជាលំដាប់។ ក្នុងរយៈពេល១០ឆ្នាំ ដោយចាប់ពីឆ្នាំ ១៩៩៩-២០០៨ សេដ្ឋកិច្ចកម្ពុជាមានកំណើនពិតក្នុងអត្រាមធ្យម ៩,៥% ក្នុងមួយឆ្នាំ។

ក្រាហ្វិកទី:៩




ប្រភព:ធនាគាជាតិនៃកម្ពុជា

ដោយឡែក អត្រាអតិផរណាជាមធ្យមមានកម្រិតប្រមាណ 3,6% មកដល់ពេលមុនឆ្នាំ២០០៧ ដែលបន្ទាប់ពីនោះ ពិភពលោករងគ្រោះធ្ងន់ធ្ងរនឹងវិបត្តិស្បៀង និងថ្លៃប្រេងឥន្ធនៈ។

12 ធនាគាជាតិនៃកម្ពុជា,២០១៥, "ការពង្រឹងការប្រើប្រាស់ប្រាក់រៀល"ទំព័រ១៥-២២

ក្រាហ្វិកទី:១០




ប្រភព:ធនាគារជាតិនៃកម្ពុជា

ក្នុងអំឡុងពេលបន្ទាប់ពីការបោះឆ្នោតអាណត្តិទី២នោះដែរ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លាអាមេរិកក៏បង្ហាញនូវស្ថេរភាពជាច្រើនដែរ។ ប្រាក់រៀលធៀបនឹងប្រាក់ដុល្លាអាមេរិកបានធ្លាក់ថ្លៃជាមធ្យមប្រមាណ ០.៨% ប៉ុណ្ណោះ ក្នុងមួយឆ្នាំដែលជាកម្រិតមួយដ៏ទាបធៀបនឹងរូបិយប័ណ្ណមួយចំនួនធំ និងជាកម្រិតដែលអាចចាត់ទុកប្រាក់រៀលថាមានស្ថិរភាពយ៉ាងប្រសើរ។

ទទឹមនឹងនោះផងដែរ ប្រព័ន្ធធនាគារក៏មានការរីកចម្រើនជាច្រើនសណ្ឋាន ទាំងវិសាលភាពនៃប្រតិបត្តិការ គុណភាពសេវា ក៏ដូចជាវិស័យធនាគារបានកើនឡើងពី ២.១៣២ ពាន់លានរៀលនៅឆ្នាំ ១៩៩៩ ទៅ ៥.៥៧៩ ពាន់លានរៀល នៅឆ្នាំ ២០០៥ និង ៣២.២១៦ ពាន់លានរៀលនៅឆ្នាំ ២០១១ ដែលឆ្លុះបញ្ចាំងនូវភាពប្រសើរឡើងនៃទំនុកចិត្តរបស់សាធារណៈជនមកលើប្រព័ន្ធធនាគារ។ ជាមួយគ្នានេះ កម្រិតស៊ីជម្រៅនៃអន្តរការិយកម្មធនាគារដែលវាស់ដោយអនុបាតការផ្គត់ផ្គង់រូបិយវត្ថុទូទៅ M2 ធៀបនឹងផលិតផលក្នុងស្រុកក៏ត្រូវបានពង្រឹងដែរ ពី ១០.១% នៅឆ្នាំ ១៩៩៩ ទៅ ១៨.៤% នៅឆ្នាំ ២០០៥ និង ៤១.៨% នៅដំណាច់ឆ្នាំ ២០១១។

ក្រាហ្វិកទី:១១




ប្រភព: ធានាគារជាតិ

ទោះបីជាទទួលបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការពង្រឹងជំនឿទុកចិត្តលើវិស័យធនាគារដូច្នេះក្តី ក៏ស្ថានភាពនេះហាក់មានឥទ្ធិពលតូចប៉ុណ្ណោះ ទៅលើកម្រិតនៃដុល្លាររូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា បើផ្អែកលើរង្វាស់នៃដុល្លាររូបនីយកម្ម ដែលជាទូទៅត្រូវបានកំណត់តាមរយៈអនុបាតសំខាន់ៗដូចជា ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹង ប្រាក់បញ្ញើសរុប រូបិយវត្ថុទូទៅ (M2) ឬផលិតផលក្នុងស្រុកសរុប (GDP) ។ ក្រាហ្វិកខាងក្រោមនេះបានបង្ហាញឲ្យឃើញថា អនុបាតទាំងបីប្រភេទរក្សាកម្រិតខ្ពស់ និងមាននិន្នាការកើនឡើងជាលំដាប់។ ជាក់ស្តែង នៅក្នុងអំឡុងជាងដប់ឆ្នាំកន្លងមក អនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុបនៃប្រព័ន្ធធនាគារមានលំនឹងជាខ្លាំងនិងស្ថិតក្នុងរង្វង់ប្រមាណ ៩២-៩៨% ប៉ុន្តែមាននិន្នាការថយចុះបន្តិច នារយៈពេលពីរឆ្នាំចុងក្រោយនេះ។ ទទឹមនោះ អនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទាត់កាន់តែមានកំណើនខ្ពស់ឡើងៗ ពីមួយឆ្នាំទៅមួយឆ្នាំ និងជារួមកើនពីប្រមាណ ៥៦% នៅដំណាច់ឆ្នាំ ១៩៩៥ ទៅប្រមាណ ៨១% នៅដំណាច់ឆ្នាំ ២០១១។ ធៀបនឹងផលិតផលសរុបក្នុងស្រុក ក្នុង

តម្លៃជានាម (Nominal GDP) អនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណកើនឡើងពីកម្រិតដ៏ទាបត្រឹម ៤,៣% នៅឆ្នាំ ១៩៩៥ ទៅប្រមាណ ៣៦,៨% នា១៦ឆ្នាំក្រោយមក។

ក្រាហ្វិកទី:១២




ប្រភព: ធនាគារជាតិ

ជាមួយគ្នានេះដែរ ការចរាចរណ៍នៃបរិមាណប្រាក់រៀលបានកើនឡើងជាលំដាប់ បើពិនិត្យលើទំហំជាច់ខាត គឺពី ៩៩៥ ពាន់រៀល នៅដំណាច់ឆ្នាំ២០០០ ទៅប្រមាណ៣.៧៧២ ពាន់លានរៀល នៅដំណាច់ឆ្នាំ ២០១១ ដែលបង្ហាញ ថាអ្នកប្រើប្រាស់និង វិស័យឯកជន ក៏មានត្រូវការប្រាក់រៀលកើនឡើងផងដែរ។ ប៉ុន្តែបើពិនិត្យលើការវិស័យឯកជន ក៏មានតម្រូវការប្រាក់រៀលកើនឡើងផងដែរ។ ប៉ុន្តែបើពិនិត្យលើការវិវត្តនៃប្រាក់បញ្ញើជារៀលជាផលធៀបជាមួយប្រាក់បញ្ញើជារូបិយប័ណ្ណនោះប្រាក់បញ្ញើជារូបិយប័ណ្ណមានបម្រែបម្រួលក្នុងល្បឿនលឿនជាង ពោលគឺបានកើនពីកម្រិត ១៥ដងនៃបញ្ញើជារៀល នៅឆ្នាំ ២០០០ ទៅ ៣០ដង នៅឆ្នាំ ២០១០ និងបានធ្លាក់ចុះមក ២៦ដង នៅឆ្នាំ ២០១១ ។

ការវិវត្តខាងលើនេះបានបង្ហាញថាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចគឺជាកត្តាចាំបាច់ និងជាបុរលក្ខខណ្ឌដំចម្បងនៃការកាត់បន្ថយកំរិតដុល្លារូបនីយកម្មនៃប្រទេសនិមួយៗ។ ប៉ុន្តែស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចមិនមានឥទ្ធិពលគ្រប់គ្រាន់ និងជាកម្លាំងចលករទាំងស្រុងសម្រាប់ជំរុញការឈានទៅរកបដិដុល្លារូបិយកម្ម ឬការបង្កើនការប្រើប្រាស់រូបិយវត្ថុជាតិដោយស្វ័យប្រវត្តិឡើយ។ ចំណុចសំខាន់ៗគឺដុល្លារូបនីយកម្ម បានចាក់ឬសជ្រៅនៅក្នុងស្រទាប់អារម្មណ៍និងទម្លាប់របស់សាធារណជនទៅហើយ ជាពិសេសប្រជាជននៅទីក្រុង និងតំបន់ប្រជុំជន។ គួររំឮកដែរថា នៅប្រទេសកម្ពុជាការប្រើប្រាស់ប្រាក់ដុល្លារ សម្រាប់បំពេញតួនាទីគ្រប់យ៉ាងនៃរូបិយវត្ថុមានដំណើរការជាងមួយទសវត្សរ៍មកហើយ។ ទោះបីពុំមែនជា "រូបិយវត្ថុនីត្យានុកូល" ក៏ដោយ ក៏ប្រាក់ដុល្លាបានក្លាយទៅជា "រូបិយវត្ថុក្នុងស្រុកជាក់ស្តែង" (defacto local currency) ចំពោះប្រជាជនវិនិយោគ និងទីផ្សារនៅកម្ពុជា។ អ្នកប្រើប្រាស់ហាក់លែងមានអារម្មណ៍ និងមានគំនិតថាប្រាក់ដុល្លាគឺគ្រាន់តែជា "កូនចិញ្ចឹមនៅក្នុងសេដ្ឋកិច្ចកម្ពុជា" ទៀតដែរ តែមានអារម្មណ៍ជាសភាវគតិចាត់ទុកប្រាក់ដុល្លារជា "កូនបង្កើត" ទៅវិញ។ ដូច្នេះ យោងទៅលើហេតុផលនេះ និងផ្អែកលើទិន្នន័យវិភាគខាងលើយើងអាចសន្និដ្ឋានបានថា ប្រសិនបើពុំមានការខិតខំជាច្រើនពីសំណាក់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចកិច្ចនិហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ស្ថាប័នពាក់ព័ន្ធ និងធនាគារជាតិនៃកម្ពុជានាពេលកន្លងមកដូចបានពិពណ៌នាខាងលើសំដៅពង្រឹងការប្រើប្រាស់ប្រាក់រៀលទេនោះ សេដ្ឋកិច្ចកម្ពុជាអាចនឹងមានកម្រិតដុល្លារូបនីយកម្មខ្ពស់ជាងកម្រិតបច្ចុប្បន្ន ឬអាចនឹងឈានស្ទើរនឹងទៅដល់ "ដុល្លារូបនីយកម្មទាំងស្រុង" ផងក៏បាន ។

នៅចំពោះមុខបញ្ហាប្រឈមប្រកបដោយវិសាលភាពធំធេង ស្មុគស្មាញ និងមានលក្ខណៈដក់ជាប់ជាទម្លាប់បែបនេះ ជាបន្ថែមលើនយោបាយស្ថិរភាវូបនីយកម្មម៉ាក្រូសដ្ឋកិច្ចរាជរដ្ឋាភិបាល

និងអាជ្ញាធរពាក់ព័ន្ធ ចាំបាច់ត្រូវមានវិធានការលើកទឹកចិត្ត និងជំរុញដោយឡែកជាពិសេសទៀត ក្រោមរូបភាពជាកំណែទម្រង់រចនាសម្ព័ន្ធប្រកបដោយការប្រុងប្រយ័ត្នមួយចំនួនដូចជា វិធានការរដ្ឋបាលបញ្ញត្តិកម្ម ការអភិវឌ្ឍ និងការគ្រប់គ្រងស្ថាប័ននិងទីផ្សារហិរញ្ញវត្ថុជាដើម ដែលមិនបង្កការលើកទឹកចិត្តនិងមានទិសដៅកែប្រែទម្លាប់ និងឥរិយាបថអ្នកប្រើប្រាស់បន្តិចៗ ឬដែលមិនបង្កបញ្ហាគ្រោះថ្នាក់ផ្លូវចិត្ត (Moral hazard) ចំពោះសាធារណជននិងវិនិយោគិន។

## ៤.២. វិធានការចម្បងៗនៃការធ្វើបដិដុល្លារូបនីយកម្ម

បទពិសោធន៍នៃបណ្តាប្រទេសជាច្រើនបាន អនុវត្តបដិដុល្លារូបនីយកម្មបានផ្តល់មេរៀនយ៉ាងល្អប្រសើរ ស្តីពីវិធានការសំខាន់ ដែលអាចជួយសេដ្ឋកិច្ចដុល្លារូបនីយកម្មដែលឈានជាជំហាន ឆ្ពោះទៅរកការប្រើប្រាស់រូបិយវត្ថុជាតិរបស់ខ្លួនយ៉ាងទូលំទូលាយនឹងដោយពុំបង្ករឲ្យមានភាពល្អក់កករចំពោះទំនុកចិត្តជាសាធារណៈជន និងវិនិយោគិន ឬសភាពអវិជ្ជមានផ្សេងៗចំពោះទីផ្សារ ទោះបីជាដំបូងមានការលំបាកខ្លះក្តីក្នុងការផ្លាស់ប្តូរឥរិយាបទទម្លាប់ និងអារម្មណ៍របស់សាធារណៈជន។ ដូចនេះ វិធានការចម្បងៗនៃការបដិដុល្លារូបនីយកម្មមានដូចជា៖

- ប្រតិបត្តិការចំណូល ចំណាយរបស់រដ្ឋាភិបាលត្រូវធ្វើឡើងជារូបិយវត្ថុជាតិ និងបង្កើនការអនុវត្តចំណូលចំណាយតាមរយៈប្រព័ន្ធធនាគារទៅតាមលទ្ធភាពដែលអាចធ្វើបាន។
- បំណុលរបស់រដ្ឋាភិបាលត្រូវចារឹកជារូបិយវត្ថុជាតិ ក្នុងនោះរួមមានការខ្ចីរបស់ធនាគារ ឬស្ថាប័នសាធារណៈ ឬរបស់ក្រុមហ៊ុនកម្មសិទ្ធិរដ្ឋជាដើម ពីទីផ្សារឥណទាន និងទីផ្សារទុនក្នុងប្រទេសក្រោមរូបភាព ជាការចេញផ្សាយសញ្ញាប័ណ្ណ ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុនផ្សេងៗ ជារូបិយវត្ថុជាតិ។ ករណីនេះនឹងជួយឲ្យប្រតិបត្តិការរបស់រដ្ឋាភិបាលចារឹកជារូបិយវត្ថុជាតិ ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ហើយទីផ្សារនឹងមានឧបករណ៍ហិរញ្ញវត្ថុក្នុងស្រុករបស់ខ្លួនចារឹកជារូបិយវត្ថុ។
- ជំនួយបរទេសជារូបិយប័ណ្ណ ត្រូវប្តូរជារូបិយវត្ថុជាតិមុននឹងយកមកប្រើប្រាស់
- ចំណូលដែលជារូបិយប័ណ្ណ ដែលទទួលបានពីការនាំចេញ ក្នុងពាណិជ្ជកម្មអន្តរជាតិត្រូវប្តូរនិងរក្សាទុកជារូបិយវត្ថុជាតិ។ ទទឹមនឹងនេះពន្ធដារអាចនឹងកំណត់ពន្ធ ខ្ពស់លើចំពោះចំណូលជារូបិយប័ណ្ណលើវិស័យឯកជន ឬអាជីវកម្មជារូបិយប័ណ្ណ។
- ថ្លៃទំនិញ និងសេវាដែលផ្គត់ផ្គង់នៅលើទីផ្សារក្នុងស្រុកត្រូវកំណត់ និងដាក់តាំងជារូបិយវត្ថុជាតិដើម្បី ជួយជំរុញឲ្យសាធារណជន មានទម្លាប់កាន់តែច្រើនឡើង និងការប្រើប្រាស់

រូបិយវត្ថុជាតិ។ ប្រាក់បៀវត្សរ៍ ទាំងក្នុងវិស័យសាធារណៈ និងក្នុងវិស័យឯកជន គប្បីត្រូវទូទាត់ជារូបិយវត្ថុជាតិ ដែលនឹងជួយបង្កើនចរាចរណ៍ជារូបិយវត្ថុជាតិក្នុសេដ្ឋកិច្ច។

- ជំរុញការចេញផ្សាយឧបករណ៍ហិរញ្ញវត្ថុចារឹកជារូបិយវត្ថុជាតិ ហើយធ្វើឲ្យទីផ្សារប្តូរប្រាក់កាន់តែមានភាពស៊ីជម្រៅ និងទូលំទូលាយដែលរួមចំណែកដល់ស្ថិរភាពនៃ អត្រាការប្រាក់។ ក្រៅពីនេះវានឹងលើកទឹកចិត្តវិនិយោគិនក្នុងស្រុកដូចជាមូលនិធិសោធនិវត្តន៍វិនិយោគិនជាបុគ្គលជាដើម ដែលមានចំណូលជារូបិយវត្ថុជាតិអាចចូលរួមក្នុងទីផ្សារទុនក្នុងស្រុកយ៉ាងសំខាន់ផងដែរ។
- ប្រព័ន្ធទូទាត់ត្រូវចូលរួមចំណែកលើកទឹកចិត្ត និងជម្រុញការប្រើប្រាស់រូបិយវត្ថុជាតិ ដោយជួយធ្វើឲ្យចំណាយចំពោះប្រតិបត្តិការទូទាត់ជារូបិយវត្ថុជាតិ មានកម្រិតតិចជាងចំណាយចំពោះប្រតិបត្តិការទូទាត់ជារូបិយប័ណ្ណនិងការបង្កើនហេដ្ឋរចនាសម្ព័ន្ធទូទាត់ ដែលទ្រទ្រង់ដល់ការទូទាត់ជារូបិយវត្ថុជាតិបានទាន់ពេលវេលា និងប្រកបដោយសុវត្ថិភាព។ ក្នុងនោះរួមមានដូចជា ការដាក់ឲ្យប្រើប្រាស់ទូលំទូលាយនូវម៉ាស៊ីន ATM សម្រាប់រូបិយវត្ថុជាតិ និងការលើកទឹកចិត្តការប្រើប្រាស់មូលប្បទានបត្រជារូបិយវត្ថុជាតិដោយយកពន្ធ ឬសាហ៊ុយទូទាត់លើមូលប្បទានបត្រជារូបិយប័ណ្ណជាដើម។
- កំណត់ឧបករណ៍នយោបាយរូបិយវត្ថុ និងវិធានការត្រួតពិនិត្យប្រុងប្រយ័ត្នដែលមានទិសដៅមិនលើកទឹកចិត្តការប្រើប្រាស់រូបិយប័ណ្ណ។ ក្នុងនោះរួមមានៈការកំណត់ទុនបម្រុងកាតព្វកិច្ច ក្នុងកម្រិតខ្ពស់ ឬមិនផ្តល់ការប្រាក់សម្រាប់ប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ ការរឹតត្បិតលើ Foreign Currency open opposite និងការតម្រូវឲ្យមានកម្រិតសំវិធានធន ឬកម្រិតសាច់ប្រាក់ងាយស្រួលខ្ពស់ ចំពោះប្រតិបត្តិការជារូបិយប័ណ្ណជាដើម។ល។

ដូចនេះចំណុចដែលត្រូវយកចិត្តទុកដាក់ ជាពិសេសក្នុងការដាក់ចុះនូវវិធានការទាំងឡាយដូចបានរៀបរាប់ខាងលើ គឺត្រូវសម្គាល់សភាពការណ៍និងបរិស្ថានជាក់ស្តែង ច្បាស់លាស់ធ្វើការជ្រើសរើសសម្របសម្រួល កំណត់ជាលំដាប់លំដោយ ឬគួបផ្សំវិធានការនានាឲ្យបានសមស្រប និងត្រូវអនុវត្តដោយសន្សឹមៗស្ទាប់ស្ទង់ និងប្រុងប្រយ័ត្ន។ ឧបករណ៍មួយចំនួនចាំបាច់ត្រូវមានការកែលម្អរបន្ថែមតាមការចាំបាច់ ដូចជាការកំណត់ប្រាក់បៀវត្សន៍ ឬបង្កើតឧបករណ៍ហិរញ្ញវត្ថុចារឹកជារូបិយប័ណ្ណត្រូវមានសន្ទស្សន៍ភ្ជាប់ទៅនឹងអតិផរណាជាដើម។

## ៤.៣ លទ្ធផលអង្កេតស្ដីពី ការប្រើប្រាស់ប្រាក់រៀល និងប្រាក់ដុល្លា[13]

ក្រោមគម្រោងសិក្សាលើស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា វិទ្យាស្ថានស្រាវជ្រាវនៃភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA Research Institute ) បានសហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអង្កេតអំពីអត្តចរិតនៃការប្រើប្រាស់ប្រាក់រៀល និងរូបិយប័ណ្ណនៅកម្ពុជា ក្នុងរាជធានី-ខេត្តទាំង ២៥ នៃព្រះរាជាណាចក្រកម្ពុជា។ ការអង្កេតនេះត្រូវបានធ្វើឡើងកាលពីពាក់កណ្ដាលឆ្នាំ២០១៤ ដល់ពាក់កណ្ដាលឆ្នាំ២០១៥ តាមរយៈការសម្ភាសន៍ដោយផ្ទាល់ជាមួយអង្គភាពគ្រួសារ ២.២៧៣ ក្រុមហ៊ុន-សហគ្រាសចំនួន ៨៥៦សាខាគ្រឹះស្ថានធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុចំនួន ១.២៩០ និងអាជីវករប្ដូរប្រាក់ចំនួន ៨៦។

គោលបំណងនៃការធ្វើអង្កេតនេះ គឺដើម្បីទទួលបានទិន្នន័យជាលក្ខណៈមីក្រូបន្ថែមលើទិន្នន័យម៉ាក្រូដែលមានស្រាប់ ចំពោះស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា។ ការសិក្សានេះក៏មានគោលដៅផ្ដល់ជាធាតុចូលក្នុងការរៀបចំជា គោលនយោបាយលើកកម្ពស់ការប្រើប្រាស់រៀលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ បន្ទាប់ពីបានបញ្ចប់ការវិភាគបឋម ក្រុមការងារស្រាវជ្រាវនៃធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវ JICA បានធ្វើសិក្ខាសាលាផ្សព្វផ្សាយពីលទ្ធផលអង្កេតដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល អ្នកស្រាវជ្រាវ អ្នកជំនាញមកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សាកលវិទ្យាល័យក្រុមហ៊ុនសហគ្រាស និងវិស័យឯកជនពាក់ព័ន្ធនានា សរុបប្រមាណ ២៥០ រូប។ ខ្លឹមសារសង្ខេបនៃលទ្ធផលសិក្សានេះ មានដូចតទៅ៖

### ៤.៣.១. ចំពោះអង្គភាពគ្រួសារ

- ក្នុងចំណោមប្រភពចំណូលទាំងអស់របស់អង្គភាពគ្រួសារ ចំណូលដែលទទួលបានពីប្រាក់បៀវត្សភាគច្រើនជាដុល្លារអាមេរិក។
- ផ្ទុយពីការចំណាយរបស់អង្គភាពគ្រួសារតែមួយភាគតូចប៉ុណ្ណោះជាដុល្លារអាមេរិកជាពិសេសការចំណាយទៅលើសេវាទូរសព្ទ និងការជួលផ្ទះ។
- អង្គភាពគ្រួសារតែងតែប្ដូរប្រាក់ដុល្លារអាមេរិកយកប្រាក់រៀល។
- អង្គភាពគ្រួសារភាគច្រើន មិនសូវប្រើប្រាស់ក្រដាសប្រាក់រៀលដែលមានតម្លៃចារឹកខ្ពស់នោះទេ។
- ភាគច្រើន អង្គភាពគ្រួសារខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាប្រាក់ដុល្លារអាមេរិក ដោយសារតែគោលបំណងនៃការប្រើប្រាស់ប្រាក់កម្ចីនោះ តម្រូវឲ្យប្រើប្រាស់ប្រាក់ដុល្លារអាមេរិក។
- ចំពោះទស្សនៈរបស់អង្គភាពគ្រួសារជារួមគាំទ្រការលើកកម្ពស់ប្រាក់រៀល។

[13]ធនាគារជាតិនៃកម្ពុជា *របាយការណ៍ប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧* , ទំព័រ២០-២៣

ក្រាបហ្វិកទី:១៣

**កម្រិតដុល្លារូបនីយកម្មបែងចែកតាមប្រភពនិងកម្រិតចំណូល**




**សមាសភាគនៃរូបិយប័ណ្ណធៀបនឹងចំណាយសរុប**




### ៤.៣.២. ចំពោះក្រុមហ៊ុន-សហគ្រាស

- ក្រុមហ៊ុន-សហគ្រាសដែលស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តនៅតំបន់ខាងជើងភាគខាងលិចនៃប្រទេស ប្រើប្រាស់ប្រាក់ដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងទៀតលើសពី ៦៥% ក្នុងប្រតិបត្តិការប្រចាំថ្ងៃ។
- នៅតំបន់កណ្តាលនៃប្រទេសកម្ពុជា ក្រុមហ៊ុនសហគ្រាសទទួលបានចំណូលជាដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងទៀតតិច ប៉ុន្តែការចំណាយភាគច្រើនជាដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងទៀត។
- នៅពេលដែលទំហំក្រុមហ៊ុន-សហគ្រាស កាន់តែធំការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក និងរូបិយប័ណ្ណក៏កាន់តែច្រើនផងដែរ។
- ក្រុមហ៊ុន-សហគ្រាសច្រើនតែខ្ចីឥណទានពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាដុល្លារអាមេរិក ជាជាងប្រាក់រៀល ដោយសារប្រតិបត្តិការទីផ្សារហិរញ្ញវត្ថុជារៀលមានការអភិវឌ្ឍន៍ទាប ហើយប្រតិបត្តិការរបស់ក្រុមហ៊ុន-សហគ្រាសភាគច្រើនតម្រូវឲ្យប្រើប្រាស់ប្រាក់ដុល្លាអាមេរិក ក៏ដូចជាជួយបញ្ចៀសហានិភ័យអត្រាប្តូរប្រាក់។
- ក្រុមហ៊ុន-សហគ្រាសភាគច្រើន ប្រឈមនឹងហានិភ័យភាពមិនស៊ីគ្នានៃរូបិយវត្ថុ និងរូបិយប័ណ្ណក្នុងចំណូល-ចំណាយ ប៉ុន្តែមិនបានប្រើប្រាស់វិធីសាស្ត្របញ្ចៀសហានិភ័យនោះទេ។

កម្រិតដុល្លារូបនីយកម្មធៀបនឹងចំណូល-ចំណាយរបស់ក្រុមហ៊ុន-
សហគ្រាស បែងចែកតាមទំហំ

| Area | Revenues | Expenditures |
|---|---|---|
| Phnom Penh | 69% | 75% |
| Siem Reap | 66% | 73% |
| North-West Area | 69% | 77% |
| North-East Area | 31% | 41% |
| Central Area | 35% | 56% |
| South-West Area | 52% | 66% |
| South-East Area | 46% | 57% |

| | Revenues | Expenditures |
|---|---|---|
| Micro | 39% | 55% |
| Small | 47% | 67% |
| Medium | 47% | 60% |
| Large | 70% | 67% |

### ៤.៣.៣. ចំពោះគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រើប្រាស់ប្រាក់រៀលក្នុងប្រតិបត្តិការច្រើនជាងគ្រឹះស្ថានធនាគារ
- ប្រាក់បញ្ញើជារូបិយវត្ថុកំពុងមានការកើនឡើងក្នុងប្រព័ន្ធធនាគារ។
- គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ បែងចែកមូលនិធិជាដុល្លារអាមេរិកនិងរូបិយប័ណ្ណផ្សេងៗទៅសាខាដែលខ្វះ ប៉ុន្តែមិនផ្ទេរមូលនិធិជារៀលនោះទេ ទោះជាមានភាពលើសក៏ដោយ
- នៅតំបន់ជនបទ ប្រាក់រៀលត្រូវបានប្រើប្រាស់ក្នុងការដាក់ផ្ញើ និងផ្តល់ឥណទាន។
- សមាមាត្រនៃប្រាក់បញ្ញើជារូបិយប័ណ្ណក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ បានថយចុះទាំងនៅរាជធានីភ្នំពេញនិងនៅជនបទ។
- ទោះជាយ៉ាងនេះក្តី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ កំពុងតែផ្តល់ឥណ-ទានជាដុល្លារអាមេរិកកាន់តែច្រើនឡើងៗ ដើម្បីកាត់បន្ថយហានិភ័យនៃភាពមិនស៊ីគ្នានៃលំហូរចេញ-ចូលរូបិយវត្ថុ (Currency Mismatch Risk)។
- គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ កំណត់អត្រាការប្រាក់លើឥណទានជារៀលខ្ពស់ជាងឥណទានជាប្រាក់ដុល្លារ ដើម្បីកាត់បន្ថយហានិភ័យអត្រាប្តូរប្រាក់។

ក្រាហ្វិកទី:១៤

កម្រិតដុល្លារូបនីយកម្មធៀបនឹងទ្រព្យសកម្មនិងទ្រព្យអកម្មសរុបរបស់
គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ



### ៤.៣.៤. ចំពោះអាជីវកម្មប្តូរប្រាក់

- អតិថិជនប្តូរយកប្រាក់ច្រើនជាងគេ បន្ទាប់មកប្រាក់ដុល្លារអាមេរិក បាតថៃ និងអឺរ៉ូ
- តម្រូវការប្រាក់រៀលមានកម្រិតខ្ពស់នៅតាមបណ្តាខេត្ត ដែលពឹងផ្អែកលើកសិកម្ម ជាពិសេសខេត្តបាត់ដំបង កំពង់ចាម រតនគិរី និងកំពង់ធំ
- ប្រាក់បាតថៃនិងដុងវៀតណាមមានប្រតិបត្តិការខ្លាំងនៅតាមព្រំដែន
- ខេត្តនិមួយៗ មានអត្រាប្តូរប្រាក់ខុសៗគ្នា ដោយអាជីវករនៅតំន់ដែលសកម្មក្នុងសេដ្ឋកិច្ចផ្តល់អត្រាប្តូរប្រាក់ល្អជាងតំបន់ផ្សេងៗទៀត ហើយនៅតំបន់ជនបទនិងដាច់ស្រយាលមានអត្រាប្តូរប្រាក់ខ្ពស់។

សរុបសេចក្តីមក តាមរយៈការសិក្សានិងកិច្ចពិភាក្សាក្នុងសិក្ខាសិលាផ្សព្វផ្សាយលទ្ធផលអង្កេត វិធានការគោលនយោបាយមួយចំនួនត្រូវបានមើលឃើញថា មានភាពសមស្របក្នុងការដាក់ឲ្យអនុវត្ត ដើម្បីពង្រឹងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ប្រកបដោយនិរន្តរភាព។ វិធានការទាំងនេះរួមមានៈ

- លើកទឹកចិត្តនិងជម្រុញឲ្យក្រុមហ៊ុន-សហគ្រាស និងអាជីវករ ដាក់តាំងតម្លៃនិងទូទាត់ទំនិញនិងសេវាជាប្រាក់រៀល ព្រមទាំងបើកប្រាក់បៀវត្សនិងប្រាក់ឈ្នួលរបស់បុគ្គលិកជាប្រាក់រៀល។
- ជម្រុញឲ្យមានការបើកគណនីជាប្រាក់រៀល និងប្រើប្រាស់គណនីជារៀលនោះឲ្យកាន់តែច្រើន។
- ជម្រុញការប្រើប្រាស់ក្រដាសប្រាក់មានតម្លៃចារឹកដែលមានស្រាប់ និងពិចារណាបោះផ្សាយក្រដាសប្រាក់មានតម្លៃចារឹកខ្ពស់នោះបន្ថែម ដើម្បីឆ្លើយតបទៅនឹងប្រតិបត្តិការធំៗ។
- លើកកម្ពស់ឥណទានជារៀលសម្រាប់ក្រុមហ៊ុន-សហគ្រាស។
- លើកទឹកចិត្តឲ្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ផ្ទេរប្រាក់រៀលក្នុងចំណោមសាខារបស់ខ្លួនទៅកាន់សាខាណាដែលមានតម្រូវការប្រាក់រៀល។
- បង្កើនបរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈការពង្រីកបណ្តាញសាខា ដោយសារការពង្រីកនេះនឹងជម្រុញដល់ការប្រើប្រាស់ប្រាក់រៀល។
- បង្កើតឧបករណ៍បញ្ចៀសហានិភ័យដើម្បីឲ្យការផ្តល់ឥណទានជាប្រាក់រៀលមានប្រសិទ្ធភាព ជាពិសេសសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។
- បង្កើនអន្តរកម្មហិរញ្ញវត្ថុ អភិវឌ្ឍន៍ទីផ្សារប្តូរប្រាក់ដុំ និងទីផ្សារអន្តរជាតិធនាគារ។
- ពង្រឹងការត្រួតពិនិត្យនិងបទប្បញ្ញត្តិចំពោះអាជីវករប្តូរប្រាក់ ជាពិសេសអាជីវករប្តូរប្រាក់ធំៗ។

## ៤.៤ ការវិភាគ SWOT

- **ចំណុចខ្លាំងរបស់វិធានការលើកកម្ពស់ប្រាស់រៀល**
  - ធ្វើអោយមានការកើនឡើងប្រាក់បញ្ញើជារូបិយវត្ថុជាតិ។
  - អត្រាប្តូរប្រាក់រៀលធៀបនិងប្រាក់ដុល្លាអាមេរិចបង្ហាញនៅស្ថេរភាព។
  - រាល់ការទូទាត់នូវទំនិញនិងសេវា គឺមានការទូទាត់ជាប្រាក់រៀលច្រើន។
  - រួមចំណែកក្នុងការលើកកម្ពស់រូបិយវត្ថុជាតិ។
- **ចំណុចខ្សោយរបស់វិធានការលើកកម្ពស់ប្រាក់រៀល**
  - វិធានការនេះផ្សព្វផ្សាយមិនបានទូលំទូលាយ។
  - វិធានការនេះមិនទាន់បានអនុវត្តយ៉ាងពេញលេញ ចំពោះអ្នកដែលពាក់ពន្ធ័ជាក់ស្តែង អនុវត្តបានត្រឹមតែពីរស្ថាប័នគឺ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានចុះកម្មសិក្សានិងស្រាវជ្រាវ ទៅលើប្រធានបទ "ការលើកកម្ពស់ប្រាក់រៀល" បានបង្ហាញអោយឃើញថា ធនាគារជាតិនៃកម្ពុជាគឺជាស្ថាប័នមួយ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សារស្ថេរភាពថ្លៃនិងជំរុញឲ្យមានកំណើនសេដ្ឋកិច្ច ។ យ៉ាងណាមិញធនាគារជាតិនៃកម្ពុជាបានជំរុញការលើកទឹកចិត្តក៏ដូចជាការបង្កើតគោលនយោបាយច្បាប់មួយចំនួន ដើម្បីឲ្យប្រជាជនកម្ពុជានិងអ្នកជំនួញក្នុងស្រុកឲ្យប្រើប្រាស់ប្រាក់រៀល។ ព្រមជាមួយគ្នានោះផងដែរ ធនាគារជាតិនៃកម្ពុជា បានបំពេញតួនាទីយ៉ាងសកម្មក្នុងការតាមដាននូវរាល់ការវិវត្តន៍របស់រូបិយវត្ថុជាតិ និងខិតខំរិះរកមធ្យោបាយទប់ស្កាត់នូវរាល់សកម្មភាពដែលអាចជះឥទ្ធិពលដល់តម្លៃប្រាក់រៀល។
តួយ៉ាងមានដូចជា ការបង្កើតនូវច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ និងការផ្សព្វផ្សាយជាសាធារណៈដល់ការទូទាត់នានាដែលអនុវត្តនៅក្នុងប្រទេសត្រូវតែប្រើប្រាស់ប្រាក់រៀល ព្រមទាំងបង្កើតច្បាប់សម្រាប់ការផាកពិន័យនូវរាល់ការដោះដូរណា[14] ដែលបដិសេធមិនទទួលយកប្រាក់រៀលជាមធ្យោបាយដោះដូរ។ លើសពីនេះទៅទៀត ធនាគារជាតិ នៃ កម្ពុជា ដែលជាអាណាព្យាបាលរបស់បណ្តាធនាគារពាណិជ្ជនិងធនាគារឯកទេសទាំងអស់ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានបង្កើនការយកចិត្តទុកដាក់ត្រួតពិនិត្យនិងពង្រឹងរាល់ប្រតិបត្តិការរបស់ធនាគារពាណិជ្ជ ដែលជាអន្តរការិយកម្មផ្តល់ជាសេវាបម្រើឲ្យសាធារណជន ដើម្បីធានាឲ្យបាននូវសុវត្ថិភាព ដែលជាគន្លឹះយ៉ាងសំខាន់សម្រាប់បង្កើតនូវសេចក្តីទុកចិត្តដល់អតិថិជន។

ខណៈពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកាន់តែមានការរីកចម្រើន វាក៏មានបញ្ហាដុល្លារូបនីយកម្មដែលធ្វើឲ្យខាតបង់ចំណូល ថែមទាំងបង្កជាហានិភ័យ និងមានគុណវិបត្តិកាន់តែច្រើនចំពោះសេដ្ឋកិច្ចកម្ពុជា។ ដុល្លារូបនីយកម្មនេះបានក្លាយជាឧបសគ្គមួយក្នុងការជម្រុញសមាហរណកម្មតំបន់ផងដែរ នៅក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលប្រទេសនីមួយៗខិតខំប្រើប្រាស់រូបិយវត្ថុផ្ទាល់ខ្លួនក្នុងប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ដោយកាត់បន្ថយ ការពឹងផ្អែកលើប្រាក់ដុល្លារ។ ការប្រើបាស់ប្រាក់ដុល្លាអាមេរិកយ៉ាងទូលាយនៅក្នុងប្រទេសកម្ពុជា បណ្តាលមកពីកត្តាប្រវត្តិសាស្ត្រ សេដ្ឋកិច្ច នយោយ និង សង្គម ។ នៅក្នុងអំឡុងរបបខ្មែរក្រហមធនាគារជាតិនៃកម្ពុជាត្រូវបានបំផ្លាញ ហើយរូបិយវត្ថុត្រូវបានលុបបំបាត់ចោល ពោលគឺគ្មានទីផ្សារ គ្មានពាណិជ្ជកម្ម និងគ្មានសេរីភាពគ្រប់យ៉ាង ។ ក្រោយការដួលរលំនៃរបបខ្មែរក្រហម នៅថ្ងៃទី៧ ខែ

[14] សូមមើលឧបសម្ព័ន្ធទី២

មកវា ឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាបានចាប់ផ្តើមទទួលបានសន្តិភាពមកវិញ ។ បន្ទាប់ពីរូបិយវត្ថុជាតិត្រូវបានដាក់ឲ្យចរាចរឡើងវិញ ជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលនៅមានកម្រិត និងផុយស្រួយនៅឡើយ ជាពិសេសនៅពេលសង្គ្រាមត្រូវបានអូសបន្លាយរហូតមកដល់ចុងទសវត្សរ៍ឆ្នាំ ១៩៩០ ។ នៅដើមទស្សវត្សរ៍ឆ្នាំ១៩៩០អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNTAC) បានបំពេញភារកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិភាពនៅកម្ពុជា នៅពេលការបោះឆ្នោតជាតិលើកទីមួយ ត្រូវបានរៀបចំឡើង ។ ក្នុងអំឡុងពេលនោះប្រាក់ដុល្លារអាមេរិកយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបាន ប្រើប្រាស់ដើម្បីទូទាត់ការចំណាយប្រតិបត្តិការរបស់ UNTAC នៅកម្ពុជា ។ ប្រាក់ដុល្លារអាមេរិកដើរតួនាទីសំខាន់ទាំង ៣ របស់រូបិយវត្ថុគឺ ជាមធ្យោបាយក្នុងការទូទាត់ ឧបករណ៍កំណត់តម្លៃ និង ឧបករណ៍សន្សំ ។ ដោយការរក្សានូវស្ថិរភាពនយោបាយ និងការបើកចំហនៃសេដ្ឋកិច្ច ប្រាក់ដុល្លាអាមេរិកហូរចូលកម្ពុជាកាន់តែច្រើនឡើងជាពិសេស តាមរយៈកំណើនជាបន្តបន្ទាប់នូវសកម្មភាពពាណិជ្ជកម្មទេសចរណ៍ និងវិនិយោគបរទេស ។ បន្ទាប់មក ប្រាក់ដុល្លារអាមេរិកទទួលបានការពេញនិយមកាន់តែច្រើន និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ស្ទើរគ្រប់សកម្មភាពជំនួញ និងជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសប្រតិបត្តិការដែលមានទំហំទឹកប្រាក់ធំ និងនៅតាមទីប្រជុំជន ។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ប្រាក់រៀលត្រូវបានប្រើប្រាស់យ៉ាងសកម្មនៅតាមទីជនបទ និងកំពុងបន្តកើនឡើងបន្ថែមទៀត ។

ការប្រើប្រាស់ប្រាក់រៀល គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់សេដ្ឋកិច្ច និងសង្គម ។ ប្រាក់រៀលបានជួយលើកស្ទួយអត្តសញ្ញាណជាតិ កសាងជំនឿទុកចិត្ត ជំរុញសាមគ្គីភាព និងបណ្តុះការបង្រួបបង្រួម និងស្មារតីជាតិនិយមនៅក្នុងប្រទេស ។ ចំពោះសេដ្ឋកិច្ចការចរាចរប្រាក់រៀល កាន់តែច្រើននឹងជំរុញឲ្យប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ ។ ការពឹងផ្អែកលើប្រាក់ដុល្លារអាមេរិកបណ្តាលអោយកម្ពុជាងាយទទួលរងផលប៉ះទង្គិចពីសហរដ្ឋអាមេរិច ។ ប្រសិនបើប្រាក់រៀលជារូបិយវត្ថុចម្បង ធនាគារកណ្តាលអាចដើរតួនាទីជាអ្នកអោយខ្ចីចុងក្រោយ ។ ម្យ៉ាងទៀត ការកើនឡើងនៃការប្រើប្រាស់រៀល ក៏នឹងជួយឲ្យរដ្ឋាភិបាលទទួលបានប្រាក់រៀលតែមួយមុខ ត្រូវបានប្រើប្រាស់ក្នុងការបោះផ្សាយរូបិយវត្ថុផងដែរ ។ លើសពីនេះប្រសិនបើប្រាក់រៀលតែមួយមុខត្រូវបានប្រើប្រាស់ក្នុងទីផ្សារចំណាយប្រតិបត្តិការក្នុ ងការប្តូរប្រាក់នឹងត្រូវបានកាត់បន្ថយព្រោះយើងមិនចាំបាច់ប្តូរប្រាក់ ។

សរុបមក បេសកម្មរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់និងដាក់ទិសដៅគោលនយោបាយរូបិយវត្ថុសំដៅរក្សាស្ថេរភាពថ្លៃ និងជួយសម្រួលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច។ លើសពីនេះទៅទៀត ការអនុវត្តន៍គោលនយោបាយ ក៏ដូចជាផែនការសកម្មភាពនានាគួរមានការប្រាស្រ័យទាក់ទងឲ្យមានភាពច្បាស់លាស់ទៅកាន់សាធារណជន ដើម្បីបង្ហាញពីជំហររបស់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងការលើកកម្ពស់ប្រាក់រៀល។ ការលើកកម្ពស់ការយល់ដឹងប្រាក់រៀលនេះ អាចធ្វើទៅបានដោយមានទំនុកចិត្ត និងការស្ម័គ្រចិត្តពីសាធារណជននិងការគាំទ្រនានាតាមស្ថាប័ន ឬរដ្ឋាភិបាលក្នុងការពិចារណាលើការអនុវត្តគោលនយោបាយ និងវិធានាការនានា ដែលពឹងផ្អែកជាបឋមលើយន្តការទីផ្សារដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនេះ។

# ការផ្តល់អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «ការលើកកម្ពស់ប្រាក់រៀល» រួចមកគឺបញ្ជាក់ឲ្យឃើញថា ធនាគារជាតិនៃកម្ពុជា បានកំពុងនឹងអនុវត្តបេសកម្មរបស់ខ្លួនក្នុងការលើកកម្ពស់ប្រាក់រៀល និងជម្រុញឲ្យមានការប្រើប្រាស់ប្រាក់រៀលនៅលើទីផ្សារឲ្យកាន់តែច្រើនឡើងៗ។ ទទ្ទឹមនឹងនោះ ធនាគារជាតិនៃកម្ពុជាគួរតែអនុវត្តវិធីសាស្ត្រដូចខាងក្រោមបន្ថែមទៀត ដើម្បីជម្រុញឲ្យមានការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើនឡើង ដូចតទៅ៖

- ជម្រុញឲ្យមានការទូទាត់ប្រាក់បៀវត្សរបស់បុគ្គលិកឯកជន ក្រោមរូបភាពជាប្រាក់រៀលឲ្យកាន់តែច្រើន។
- ជម្រុញឲ្យមានការប្រើប្រាស់ប្រាក់រៀលលើទំនិញនិងសេវាកម្មគ្រប់ប្រភេទ និងការកំណត់ថ្លៃទំនិញផ្សេងៗគួរតែកំណត់ជាប្រាក់រៀល។
- កែលំអរក្រដាស់ប្រាក់អោយមានភាពស្រស់ស្អាត ធន់ជាងមុន (មិនងាយរហែក ឬទក់) និងមានទំហំប៉ុនគ្នា ព្រោះងាយស្រួលទុកដាក់។
- ពិចារណាបោះពុម្ពក្រដាស់ប្រាក់អោយមានតម្លៃចារឹកធំជាងមុន។
- បង្កើតឲ្យមានម៉ាស៊ីដកប្រាក់នឹងដាក់ប្រាក់ជាប្រាក់រៀល។
- ផ្តល់អត្រាការប្រាក់លើប្រាក់រៀលខ្ពស់ជាងប្រាក់ដុល្លារ។
- រក្សារអត្រាប្តូរប្រាក់ឲ្យនៅថេរ។
- គ្រងគ្រងអភិធរណា។
- ជុំរុញអោយប្រជាពលរដ្ឋកម្ចីជារៀល។
- លើកកម្ពស់ឥណទានជារៀលសម្រាប់ក្រុមហ៊ុន-សហគ្រាស។
- ត្រួតពិនិត្យលើអាជីវករប្តូរប្រាក់ជាពិសេសអាជីវករធំៗ។

# ឯកសារយោង


- គេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា www.nbc.org.kh (ចូលថ្ងៃទី១២ មិថុនា ២០១៧)
- https://www.nbc.org.kh/about_the_bank/history_of_nbc.php

  (ចូលថ្ងៃទី ២១ ឧសភា ២០១៧)
- លោកសាស្ត្រាចារ្យ ងួន ហេង,*សៀវភៅរូបិយវត្ថុ និងធនាគារ*, (ឆ្នាំ២០១៥),ទំព័រ៨&៩
- ហ្សង់ដានីញ៉ែលហ្គារខៃរ *,រូបិយវត្ថុនិងអធិបតេយ្យភាព ដំណើរវែងឆ្ងាយនៃធនាគារជាតិនៃកម្ពុជា"* (ភាគ១) , ធនាគារជាតិនៃកម្ពុជា, ឆ្នាំ២០០៩
- ធនាគារជាតិនៃកម្ពុជា, *យុទ្ធសាស្ត្រនៃការលើកកម្ពស់ប្រាក់រៀល* ,(២០១៥),ទំព័រ២
- សៀវភៅធនាការជាតិនៃកម្ពុជា,*ការពង្រឹងការប្រើប្រាស់ប្រាក់រៀល* (បោះពុម្ពលើកទី១) ឆ្នាំ ២០១៥ ទំព័រ៨,៩
- ធនាគារជាតិនៃកម្ពុជា,*របាយការណ៍ប្រចាំឆ្នាំ២០១៦*,ទំព័រ១៧
- សៀវភៅធនាគារជាតិនៃកម្ពុជា,*សារៈសំខាន់នៃប្រាក់រៀលសម្រាប់កម្ពុជា*

# ឧបសម្ព័ន្ធទី១



២៧ ធ្នូ ១៩៩៥





៩ សីហា ២០១១





២៧ ធ្នូ ១៩៩៥





២៧ ធ្នូ ១៩៩៥





១៨ មករា ១៩៩៥





២៨ ធ្នូ ១៩៩៩






៦ មករា ២០១៦







២៩ មករា ២០១៣







មេសា ២០០៨







៨ វិច្ឆិកា ២០១៣







២៨ មិនា ១៩៩៥







០៦ មេសា ២០០៨






០៦ មិនា ១៩៩៥







០៦ មេសា ២០០៨







០៧ ឧសភា ២០១៥







០២ ឧសភា ២០០៨







២៥ មិនា ១៩៩៥







០៦ មេសា ២០១១






០៦ ឧសភា ២០១៥







២៥ មិនា ១៩៩៥







៣០ មេសា ២០១៣







២៥ មិនា ១៩៩៥






៣០ មេសា ២០១៣



ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

ស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅ

នៃ

# ធនាគារជាតិនៃកម្ពុជា

# ព្រះរាជក្រម

នស/រកម/០១៩៦/២៧

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

. . . . . . . . .

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងឯកឧត្តម ថៅ ប៉េងលាត ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង របស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៤ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១១

## បទបញ្ញត្តិផ្សេងៗ

**មាត្រា ៥៨.-**

ធនធាន ទ្រព្យសម្បត្តិ ប្រាក់លាភ ប្រតិបត្តិការនិងអាជីវកម្មរបស់ធនាគារកណ្តាលត្រូវបាន លើកលែងមិនយកពន្ធនិងអាករឡើយ ។

**មាត្រា ៥៩.-**

ធនាគារកណ្តាលមិនត្រូវចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬក្នុងសហគ្រាសដែល មានលក្ខណៈឧស្សាហកម្មឬពាណិជ្ជកម្មឡើយ លើកលែងតែគ្រឹះស្ថានដែលមានសកម្មភាពផ្សារភ្ជាប់ជាមួយ សកម្មភាពរបស់ធនាគារកណ្តាល ដូចជាការវាយតម្លៃនិងការពិនិត្យកិច្ចសន្យាធានា ប្រព្រឹត្តកម្មនិងការបញ្ជូន ទិន្នន័យ ការបោះពុម្ពឯកសារហិរញ្ញវត្ថុ ការផាត់ទាត់សងគ្នា ការបញ្ជូនសារលិខិតឬការជម្រះបញ្ជី ទ្រព្យសម្បត្តិក្នុងលក្ខខណ្ឌដែលទឹកប្រាក់ចូលហ៊ុនទាំងអស់នោះមិនលើសពី ៥% ( ប្រាំភាគរយ ) នៃ មូលនិធិរបស់ខ្លួនផ្ទាល់ ។

**មាត្រា ៦០.-**

ធនាគារកណ្តាលមិនត្រូវធ្វើលទ្ធកម្មដោយទិញឬដោយភតិសន្យានូវសិទ្ធិពិតប្រាកដលើ អចលនទ្រព្យ លើកលែងតែទ្រព្យសម្បត្តិណាដែលចាំបាច់សំរាប់ធ្វើសកម្មភាពនិងមុខងាររបស់ខ្លួនឬសំរាប់ ការងារសង្គមកិច្ចចំពោះបុគ្គលិករបស់ខ្លួន ។

បទបញ្ញត្តិនៃមាត្រានេះពុំឃាត់ធនាគារកណ្តាលមិនឱ្យធ្វើលទ្ធកម្មក្នុងក្របខ័ណ្ឌនៃការទូទាត់ សងឥណទេយ្យរបស់ខ្លួននូវសិទ្ធិដែលមានចែងក្នុងមាត្រា ៥៨ឬមាត្រានេះទេ ។

**មាត្រា ៦១.-**

រាល់ប្រកាស បទបញ្ជា សារាចរនិងបណ្តាសេចក្តីណែនាំផ្សេងៗដែលចេញដោយធនាគារ កណ្តាលសំរាប់អនុវត្តជាទូទៅចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការផ្សព្វផ្សាយក្នុងរាជកិច្ចហើយ ចូលជាធរមានបញ្ញត្តិចាប់តាំងពីថ្ងៃចេញផ្សាយនោះឬតាមកាលកំណត់ដែលមានចែងក្នុង ប្រកាស បទបញ្ជា សារាចរនិងសេចក្តីណែនាំផ្សេងៗទាំងនោះ ។

**មាត្រា ៦២.-**

ដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ ធនាគារកណ្តាលអាចធ្វើបណ្តឹងទាមទារផ្នែករដ្ឋប្បវេណីភ្ជាប់ជាមួយផ្នែកព្រហ្មទណ្ឌនូវគ្រប់ដំណាក់កាលនៃនីតិវិធី ។

**មាត្រា ៦៣.-**

ការកម្រិតឥណទាននៅក្នុងចំណុច ៣ មាត្រា ២៥ នៃច្បាប់នេះ ត្រូវអនុវត្តចំពោះឥណទានណាដែលត្រូវផ្តល់ឱ្យក្រោយថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**មាត្រា ៦៤.-**

ជនណាពុំព្រមទូទាត់រូបិយវត្ថុដែលមានតម្លៃនីត្យានុកូលនិងមានតេជានុភាពធ្វើសេវាការលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជននោះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដងនៃទឹកប្រាក់ដែលពុំព្រមទូទាត់នោះ ។

**មាត្រា ៦៥.-**

អ្នកក្លែងក្រដាសប្រាក់ឬកាសដែលជារូបិយវត្ថុមានតម្លៃនីត្យានុកូលនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាឬនៅលើដែនដីនៃរដ្ឋដទៃទៀតនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី២០ឆ្នាំដល់អស់មួយជីវិត ។

វត្ថុតាងដែលរឹបអូសបានត្រូវទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

**មាត្រា ៦៦.-**

ជនណាប្រព្រឹត្តដោយចេតនាដោយបញ្ចូលក្នុងចរាចរឬរក្សាទុកសំរាប់ចរាចរនូវក្រដាសប្រាក់ឬកាសក្លែងក្លាយ ជននោះនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។

### មាត្រា ៦៧.-

ជនណាប្រើប្រាស់ឬរក្សាទុកដោយគ្មានការអនុញ្ញាតពីធនាគារកណ្តាលនូវបណ្តាសម្ភារៈ ឧបករណ៍ គ្រឿងយន្តនិងប្រដាប់សំរាប់ផលិតក្រដាសប្រាក់ឬកាស ជននោះនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។ ឯវត្ថុតាងនឹងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

### មាត្រា ៦៨.-

ជនណាទទួលក្រដាសប្រាក់ឬកាសដែលក្រោយមកបានដឹងថាជាក្រដាសប្រាក់ឬកាសក្លែងក្លាយហើយនៅតែយកទៅដាក់ឱ្យធ្វើចរាចរវិញ ជននោះត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដងនៃទឹកប្រាក់នោះ ។

### មាត្រា ៦៩.-

ដើម្បីអនុវត្តនិងបំពេញមុខងារឱ្យបានល្អតាមច្បាប់នេះ ធនាគារកណ្តាលអាចស្នើសុំពត៌មានដែលខ្លួនត្រូវការពីរូបវន្តបុគ្គលឬនីតិបុគ្គលដែលពាក់ព័ន្ធ រួមទាំងពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងអង្គភាពក្រោមឱវាទទៀតផង ។

ជនណាដែលមិនព្រមផ្តល់ពត៌មានដែលធនាគារកណ្តាលបានស្នើសុំស្របតាមមាត្រានេះឬដែលមានចេតនាផ្តល់ពត៌មានខុសឬបំភាន់ ជននោះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ ៛ ( មួយលានរៀល ) ដល់ ១០.០០០.០០០ ៛ ( ដប់លានរៀល ) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

### មាត្រា ៧០.-

ជនណាគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬធ្វើសកម្មភាពមានលក្ខណៈជាធនាគារដូចជាឥណទាន ជំនួញជើងសារូបិយប័ណ្ណ ការប្តូររូបិយប័ណ្ណ ការទទួលប្រាក់ពីសាធារណជន ការគ្រប់គ្រងមធ្យោបាយទូទាត់ ប្រតិបត្តិការលើមូលប័ត្រ អាជីវកម្មមាស លោហធាតុនិងត្បូងថ្មមានតម្លៃដោយគ្មានការអនុញ្ញាតពីធនាគារកណ្តាលត្រូវបញ្ឈប់សកម្មភាពភ្លាមតាមអធិបញ្ញារបស់ធនាគារកណ្តាល ។ ជនដែលប្រព្រឹត្តល្មើសនឹងអធិបញ្ញានេះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០៛ (មួយលានរៀល)ដល់ ១០.០០០.០០០ ៛ (ដប់លានរៀល) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

មាត្រា ៧១.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១៥ ចំណុច ១ និងមាត្រា ១៦ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ ៛ (មួយលានរៀល)ដល់ ១០.០០០.០០០ ៛ (ដប់លានរៀល) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

## ជំពូកទី ១៣
## អវសានប្បញ្ញត្តិ

មាត្រា ៧២.-

បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ ១៩៩៧

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២
អគ្គលេខាធិការរដ្ឋសភាជាតិនៃកម្ពុជា

**ហត្ថលេខា**

**ចៅ ម៉េងឡាត**

លេខ : ៣៦ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៧
...រដ្ឋាភិបាល



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៦-៣៣៣ ប្រ.ក

## ប្រកាស
## ស្តីពី
## ការផ្តល់ឥណទានជារូបិយវត្ថុជាតិ
## របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិកម្ពុជានិងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងជំរុញការផ្តល់ឥណទានជារូបិយវត្ថុជាតិដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលតទៅនេះហៅថា "គ្រឹះស្ថាន" ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅបង្កើនការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងសេដ្ឋកិច្ចសម្រាប់ជាយន្តការក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានដែលស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤.-**

គ្រឹះស្ថានទាំងអស់ត្រូវមានឥណទានជារូបិយវត្ថុជាតិ យ៉ាងតិច ១០% (ដប់ភាគរយ) នៃសំពៀតឥណទានសរុប ដោយត្រូវអនុវត្តចាប់ពីថ្ងៃប្រកាសនេះចូលជាធរមាន និងឲ្យបានពេញលេញយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។

**ប្រការ ៥.-**

ការផ្តល់ឥណទានជារូបិយវត្ថុជាតិត្រូវមានចែងនៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយរបស់គ្រឹះស្ថាន ។

**ប្រការ ៦.-**

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឲ្យគ្រឹះស្ថានបង្កើនការផ្តល់ឥណទានជារូបិយវត្ថុជាតិបន្ថែមទៀតស្របតាមការចាំបាច់ ។

**ប្រការ ៧.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០១៦

**ទេសាភិបាល**

ជា.ចាន់តូ

**<u>កន្លែងទទួល៖</u>**

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**<u>ចម្លងជូន៖</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"